ISSN 1560-7615 / ISBN 978-99950-52-06-5


# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១២ លេខ ២ មេសា - មិថុនា ឆ្នាំ២០០៨ តម្លៃ ១.៥០០រ


## ការកៀរគរធនធានកម្ពុជា មានធនធានមនុស្ស ធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍ កំណើនសេដ្ឋកិច្ច និងវិបុលភាព ប្រកបដោយគុណភាពៈ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨*

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨ ប្រារព្ធធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ២០០៨ ក្រោមកិច្ចសហការ CDRI ជាមួយធនាគារអេអិនហ្សិត្យ៉ូយ៉ាល់កម្ពុជា (ANZ Royal) ដោយ CDRI ជាវិទ្យាស្ថានស្រាវជ្រាវខាងគោលនយោបាយអភិវឌ្ឍន៍ ឈានមុខគេ ហើយ ANZ Royal ក៏ជាធនាគារឈានមុខគេនៅកម្ពុជាដែរ ។ សន្និសីទនេះ មានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំចំនួន ២៥០នាក់ មកពីជួររាជរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍ និងស្រាវជ្រាវនានា ដើម្បីធ្វើការពិភាក្សាពីជោគជ័យ និងបញ្ហាប្រឈមដែលមានក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ដោយធ្វើការសង្កត់ធ្ងន់ជាពិសេសទៅលើបញ្ហាពាក់ព័ន្ធនឹងវិស័យឯកជន និងដើម្បីរួមគ្នាបង្កើតជាអនុសាសន៍សំរាប់គោលនយោបាយ និងគំនិតយោបល់មួយចំនួនសំរាប់សកម្មភាពអភិវឌ្ឍន៍ប្រទេស ។




*សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងសុន្ទរកថាគន្លឹះក្នុងសន្និសីទចក្ខុវិស័យ ខែកុម្ភៈ ឆ្នាំ២០០៨*

ក្នុងសុន្ទរកថាគន្លឹះបើកអង្គសន្និសីទចក្ខុវិស័យលើកទីពីរនេះ សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានសង្កត់ធ្ងន់ថា មួយទសវត្សរ៍នៃសន្តិភាព និងស្ថិរភាព អាចអោយប្រទេសកម្ពុជា ទទួលបានកំណើនគួរជាទីពេញចិត្ត ព្រមជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ចយ៉ាងខ្លាំងក្លា ដូចជាការកាត់បន្ថយភាពក្រីក្របានច្រើន ចំណូលរាជរដ្ឋាភិបាលកើនឡើង និងហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាលនិងការអប់រំ មានភាពប្រសើរឡើង ។ ទោះបីយ៉ាងណាក្តី សម្ដេចនាយករដ្ឋមន្ត្រី ក៏បានទទួលស្គាល់ផងដែរថា អន្តរកាលទៅរកសេដ្ឋកិច្ចទីផ្សារសេរីមានន័យថា ជាការបន្តបញ្ហាប្រឈមសំរាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍របស់ខ្លួន ពិសេសបញ្ហាវិសមភាព និងការបែងចែកផលនៃកំណើនមិនស្មើគ្នា ។ សម្ដេច ក៏បានសង្កត់ធ្ងន់ទៅលើបញ្ហាគ្រប់គ្រងធនធានធម្មជាតិ វិវាទដីធ្លី និងសមត្ថភាពធនធានមនុស្សមានដែនកំណត់ ព្រមជាមួយនឹងការផ្គត់ផ្គង់ជំនាញទៅនឹងតំរូវការទីផ្សារពលកម្ម មិនបានត្រឹមត្រូវផងដែរ ជាពិសេសសំរាប់សន្ទុះសេដ្ឋកិច្ចដ៏ខ្លាំងបែបនេះ វិស័យឯកជននៅតែមិនទាន់មានការអភិវឌ្ឍ ។ បញ្ហាទាំងនេះត្រូវបានផ្ដល់អាទិភាពខ្ពស់សំរាប់ការអភិវឌ្ឍប្រទេសកម្ពុជានៅជំហានបន្ទាប់ ។

ប្រធានបទសន្និសីទចក្ខុវិស័យ ឆ្នាំ២០០៨ គឺ "ការកៀរគរធនធានកម្ពុជា មានធនធានមនុស្ស ធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ កំណើនសេដ្ឋកិច្ច និងវិបុលភាពប្រកបដោយគុណភាព" ព្រមជាមួយប្រធានបទរងរបស់វគ្គចំនួន ៥ៈ

- ប្រទេសកម្ពុជា : ការពិនិត្យពីស្ថានភាពម៉ាក្រូនៅឆ្នាំ២០០៨
- ការទាញប្រយោជន៍អោយបានប្រសើរបំផុតពីធនធានធម្មជាតិនៅកម្ពុជា ១
- ការទាញប្រយោជន៍អោយបានប្រសើរបំផុតពីធនធានធម្មជាតិនៅកម្ពុជា ២
- ការទាញប្រយោជន៍អោយបានប្រសើរបំផុតពីធនធានមនុស្សប្រទេសកម្ពុជា
- ប្រទេសកម្ពុជា ឆ្នាំ២០០៨ និងទៅអនាគត

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជាលេខនេះ ផ្ដោតលើបញ្ហាសំខាន់ៗដែលបានពិភាក្សាក្នុងសន្និសីទចក្ខុវិស័យ និងការជាប់ទាក់ទងរបស់បញ្ហានេះទៅនឹងគោលនយោបាយអភិវឌ្ឍប្រទេសកម្ពុជា ។CDRI និង ANZ Royal ក៏កំពុងធ្វើការសង្ខេបលទ្ធផលរបស់សន្និសីទជាភាសាខ្មែរ និងអង់គ្លេស សំរាប់ដាក់ជូនដល់អ្នកបង្កើតគោលនយោបាយ និងអ្នកមានឥទ្ធិពល ។ កម្មវិធី បទបង្ហាញ និងឯកសារសន្និសីទផ្សេងៗទៀត អាចស្វែងរកបាននៅវែបសាយរបស់ CDRI: www.cdri.org.kh.

### មាតិកា


កម្ពុជាៈ ទិដ្ឋភាពម៉ាក្រូ ឆ្នាំ២០០៨ ........ ២
ការទាញប្រយោជន៍ឱ្យបានប្រសើរបំផុតពីធនធានធម្មជាតិនៅកម្ពុជា........ ៦
ការទាញប្រយោជន៍ឱ្យបានប្រសើរបំផុតពីធនធានមនុស្សប្រទេសកម្ពុជា........ ៩
ភាពជាដៃគូរវាងរដ្ឋ_វិស័យឯកជន........ ១២
ដីធ្លី ទ្រព្យសម្បត្តិ អចលនទ្រព្យ........ ១៥
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស........ ១៧
– ស្ថានភាពក្នុងប្រទេស........ ១៩
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ........ ២៤


* ឡារី ស្រ្តេន្ទ នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI សរុបទិដ្ឋភាពទូទៅនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨ ។

# ប្រទេសកម្ពុជា៖ ការពិនិត្យពីស្ថានភាពម៉ាក្រូនៅឆ្នាំ២០០៨ សូចនាករសំខាន់ៗ បញ្ហាប្រឈមខាងអភិវឌ្ឍន៍ តំបន់យើង វិស័យឯកជន

*បណ្ឌិត Hossein Jalilian* អធិប្បាយត្រួសៗពីបទបង្ហាញទាំងបួនក្នុងវគ្គទី១ នៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨ និងលទ្ធផលសំខាន់ៗនៃការពិភាក្សាជាបន្តមកទៀត ។*

សន្និសីទចក្ខុវិស័យឆ្នាំ២០០៧ មានលក្ខណៈសំខាន់មួយទៀតក្នុងវគ្គស្តីពីទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ចនៅប្រទេសកម្ពុជា ។ ដូចគ្នាដែរ វគ្គដំបូងនៃសន្និសីទឆ្នាំ២០០៨ បានបង្ហាញពីប្រធានបទដ៏សំខាន់ដូចខាងលើ ។ វគ្គនេះត្រូវបានសំរបសំរួលដោយ ឯកឧត្តមបណ្ឌិតហង់ជួនណារ៉ុន[១] ហើយអ្នកធ្វើបទបង្ហាញមានដូចជាលោក John Nelmes[២] ដែលបានលើកពីសូចនាករម៉ាក្រូសំខាន់ៗ បណ្ឌិត Hossein Jalilian បានបូកសរុបពីបញ្ហាប្រឈមខាងអភិវឌ្ឍន៍ លោក Gary Runciman[៣] បានពិភាក្សាពីបញ្ហាមួយចំនួនពាក់ព័ន្ធនឹងវិស័យឯកជន យោងតាមទស្សនៈរបស់វិស័យធនាគារនិងហិរញ្ញវត្ថុ និងសាស្ត្រាចារ្យ Zhang Yuyan[៤] ដែលបកស្រាយពីបញ្ហាទាក់ទងនឹងកត្តាស្ថាប័នក្នុងតំបន់យើង ។ សរុបមក ជាដំបូងមានការបង្ហាញពីខ្លឹមសារសំខាន់ៗនៃវគ្គនេះ បន្ទាប់មកគឺបទបង្ហាញដោយលោក John Nelmes ។

វគ្គនេះផ្តល់ព័ត៌មានថ្មីៗលើ បញ្ហាដែលបានលើកឡើងក្នុងសន្និសីទចក្ខុវិស័យឆ្នាំ២០០៧ ។ លោក John Nelmes ផ្តល់ទិន្នន័យពាក់ព័ន្ធលើប្រធានបទនេះ ហើយបង្ហាញថា ដំណើរការសេដ្ឋកិច្ចដ៏ខ្លាំងក្លានាពេលថ្មីៗបានថយល្បឿនបន្តិចវិញនាបច្ចុប្បន្ន ដោយសារវិស័យកាត់ដេរកម្ពុជា និងសេដ្ឋកិច្ចសហរដ្ឋអាមេរិកបានធ្លាក់ចុះ ។ ស្របពេលជាមួយគ្នា អតិផរណាកើនឡើងយ៉ាងខ្លាំង ដែលអាចមកពីការឡើងថ្លៃម្ហូបអាហារ និងប្រេង នៅទីផ្សារអន្តរជាតិ ។ ទាក់ទិននឹងកត្តាក្នុងស្រុកដែលបង្កកំណើនអតិផរណានេះ លោក Nelmes បញ្ជាក់ថា វាបណ្តាលមកពីកំណើនតំរូវការក្នុងស្រុកដែលបានបង្កើនថ្លៃពលកម្ម ហើយកំណើនថ្លៃពលកម្មបានរួមចំណែកធ្វើអោយទំនិញឡើងថ្លៃ និងបង្កើនចំណាយទ្រទ្រង់ការជីវភាព ។ អត្ថបទទាំងស្រុងនៃបទបង្ហាញរបស់លោក Nelmes មានបង្ហាញជូននៅខាងក្រោយសេចក្តីសង្ខេបនេះ ។

បណ្ឌិត Jalilian បានធ្វើបទបង្ហាញទាក់ទងនឹងបញ្ហាសំខាន់ៗដែលសេដ្ឋកិច្ចប្រទេសកម្ពុជាកំពុងប្រឈម ។ ទោះបីកំណើនជារួមរបស់ប្រទេសកម្ពុជាក្នុងមួយទសវត្សរ៍ចុងក្រោយ មានសន្ទុះខ្លាំងក៏ដោយ ប៉ុន្តែភាពក្រីក្រនៅតែមានសភាពធ្ងន់ធ្ងរ ហើយការកាត់បន្ថយភាពក្រីក្រគួរតែបានច្រើនជាងនេះ ។ លោកបានវែកញែកថា កំណើន និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជានៅមានកំរិតទាបនៅឡើយ បើធៀបនឹងកំណើននិងការកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ និងនៅប្រទេសចិន ។ លោកអះអាងទៀតថា លទ្ធផលមិនសូវល្អបែបនេះ បណ្តាលមកពីមូលដ្ឋាននៃកំណើនមានលក្ខណៈតូចចង្អៀតដោយប្រមូលផ្តុំតែលើវិស័យកាត់ដេរ សំណង់ និងទេសចរណ៍ ។ ចំណែកកំណើនក្នុងវិស័យកសិកម្មដែលសំខាន់បំផុតសំរាប់ការកាត់បន្ថយភាពក្រីក្រ វាមានសភាពមិនទៀងទាត់ និងមានកំរិតទាប ។ ដូច្នេះដើម្បីធ្វើអោយកាន់តែមានប្រសិទ្ធភាព កំណើនត្រូវមានលក្ខណៈរាប់បញ្ចូលបានកាន់តែខ្លាំង និងត្រូវមានចំណងទាក់ទងកាន់តែមានប្រសិទ្ធភាពរវាងវិស័យខុសៗគ្នា និងក្នុងវិស័យនីមួយៗ ។ កំណើនត្រូវចាត់ទុកថា មានលក្ខណៈរាប់បញ្ចូល ប្រសិនបើវាផ្តល់ឱ្យម្នាក់ៗនូវលទ្ធភាពស្មើៗគ្នាក្នុងការទទួលបានឱកាសល្អដែលវាបានបង្កើតឡើង។ លោកបណ្ឌិតបានសង្កត់ធ្ងន់ពីតួនាទីសំខាន់ដែលវិស័យឯកជន រដ្ឋាភិបាល និងរចនាសម្ព័ន្ធអភិបាលកិច្ចល្អប្រសើរ អាចដើរតួក្នុងដំណើរការនេះ ។ ដោយគូសបញ្ជាក់ពីសារៈសំខាន់នៃការកែលំអកសិកម្មអោយដើរតួជាមធ្យោបាយសំរាប់កាត់បន្ថយភាពក្រីក្រ លោកបានលើកពីតួនាទីដ៏សំខាន់នៃ ការចុះបញ្ជីនិងការបែងចែកដីធ្លី សិទ្ធិលើអចលនទ្រព្យកាន់តែច្បាស់លាស់ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍទីផ្សារជាទូទៅ ។ កង្វះខាតស្ថាប័នរឹងមាំព្រមទាំង កង្វះក្របខណ្ឌនិងការដាក់អនុវត្តច្បាប់បទប្បញ្ញត្តិ គឺជាឧបសគ្គដែលបន្តរាំងដល់កំណើន ។ លោកបានបញ្ជាក់ទៀតថា បណ្តាស្ថាប័នក្នុងតំបន់មានតួនាទីសំខាន់ក្នុង ការជំរុញអោយមានការបង្កើតស្តង់ដារ និងការពង្រឹងអនុវត្តព្រមទាំងជួយគាំទ្រដល់ការអភិវឌ្ឍទីផ្សារសេរី ។

លោក Gary Runciman បានធ្វើបទបង្ហាញផ្តោតទៅលើតួនាទីរបស់វិស័យធនាគារ និងលំហូរមូលធន។ លោកបានលើកថា វិស័យហិរញ្ញវត្ថុបានកើនខ្លាំងអស្ចារ្យដោយចាប់ផ្តើមពីមូលដ្ឋានមួយដ៏ទាប ហើយប្រាក់បញ្ញើបានកើនឡើងខ្ពស់ជាងការផ្តល់កំចី ។ ដោយទំនុកចិត្តលើវិស័យធនាគារកាន់តែប្រសើរឡើង វិនិយោគផ្ទាល់ពីបរទេស (FDI) នៅកម្ពុជា ត្រូវបានវិនិយោគិនយកមកតំកល់នៅក្នុងធនាគារ ហើយប្រាក់នៅសល់របស់អាជីវកម្ម ក៏ផ្ញើទុកនៅធនាគារដែរ ។ ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) មិនទាន់ប្រមូលបានប្រាក់បញ្ញើទេ ហើយក៏មិនមែនជាមធ្យោបាយពិតជាក់ស្តែងសំរាប់ចូលទៅក្នុងវិស័យផ្លូវការដែរ ។ លោក Runciman បានលើកថា ការផ្តល់កំចីបានកើនសន្ទឹកណាស់ ហើយកំចីទាំងនោះភាគច្រើនមានដាក់អចលទ្រព្យធានា ដែលធ្វើឱ្យប្រជាជនព្យាយាមបង្កើនមូលធនជាអចលនទ្រព្យ ។ ដោយយោងដល់ស្ថាប័នធនាគារទាំង ២២ ដែលកំពុងប្រកួតប្រជែងគ្នាធ្វើអាជីវកម្ម លោកអះអាងថាវិស័យធនាគារមានលក្ខណៈប្រកួតប្រជែង ដូច្នេះសហគ្រាសនានាអាចទទួលផលចំណេញពីស្ថានភាពនេះ ។

លោក Runciman បានបញ្ជាក់ថា កំណើនយ៉ាងលឿននាពេលថ្មីៗក្នុងវិស័យធនាគារ បង្ហាញយ៉ាងច្បាស់ពីទំនុកចិត្តកាន់តែច្រើនលើប្រាក់បញ្ញើនឹងការផ្តល់ឥណទាន រួមទាំងទំនុកចិត្តយ៉ាងខ្លាំងពីអាជីវកម្មក្នុងស្រុក និងកំណើនវិនិយោគផ្ទាល់ពីបរទេស ។ ទោះយ៉ាងនេះក្តី ក៏កំចីភាគច្រើននៅតែត្រូវធានាដោយដីធ្លី ដូច្នេះហើយការផ្តល់កំចីមានដែនកំណត់ ពីព្រោះការធ្វើប័ណ្ណកម្មសិទ្ធិដីត្រូវចំណាយច្រើន និងមានការលំបាកក្នុងការដាក់ជាវត្ថុធានា ។ ឧបសគ្គផ្សេងៗទៀតចំពោះការទទួលបានហិរញ្ញវត្ថុ គឺកង្វះខាតការពង្រឹងអនុវត្តក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្ម ការលំបាកនឹងទទួលបានកំចីដោយសារកង្វះឯកសារបញ្ជាក់ និងកង្វះខាតលទ្ធភាពក្នុងការប្រើទ្រព្យផ្សេងទៀត (ដូចជាទ្រព្យអាជីវកម្មជាដើម) ដើម្បីធានាកំចី ។ ហានិភ័យក្នុងវិស័យធនាគារមានដូចជា ប្រាក់ចំណូលទាបក្នុងវិស័យនេះជាទូទៅដោយសារមានកំចីមិនដំណើរការ(ពិបាកទារ)ច្រើន និងទំនុកចិត្តទាប ដោយសារគ្មានការពង្រឹងអនុវត្តច្បាប់ ។

បញ្ហាធំៗដែលត្រូវយកចិត្តទុកដាក់ជាអាទិភាព មានដូចជា៖

- ប្រាក់ចំណូលទាប៖ កំចីមិនដំណើរការកំពុងកើនឡើង ។ ទោះបីប្រាក់ចំណូលរបស់ធនាគារកើនឡើងក៏ដោយ ក៏វានៅមានកំរិតទាបខ្លាំងណាស់សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ ។

* លោក Hossein Jalilian ជានាយកខាងស្រាវជ្រាវនៃវិទ្យាស្ថាន CDRI

- វិស័យហិរញ្ញវត្ថុរឹងមាំ ជាកត្តាសំខាន់បំផុតសំរាប់កំណើន ។
- កង្វះខាតរបាយការណ៍ហិរញ្ញវត្ថុ និងទិន្នន័យអាចទុកចិត្តបានធ្វើអោយប្រតិបត្តិការមានបន្ទុកចំណាយខ្ពស់: ប្រជាជនមិនអាចបង្ហាញពីមធ្យោបាយដែលពួកគេនឹងសងកំចីវិញបានទេ ហើយចំណុចនេះបង្កើនហានិភ័យ និងថ្លៃឥណទាន (ការប្រាក់) ។
- ការពង្រឹងការប្រមូលពន្ធ របាយការណ៍ពន្ធ និងលិខិតប្រកាសបង់ពន្ធ ធ្វើអោយការកំណត់ហានិភ័យកាន់តែធ្វើបានត្រឹមត្រូវ ប៉ុន្តែពិតមានទាំងនេះមិនមែនបើកចំហឱ្យគ្រប់អាជីវកម្មនោះទេ ។ អាជីវកម្មដែលធ្វើការជាមួយធនាគារយូរមកហើយអាចទទួលបានកំចី ពីព្រោះធនាគារបានដឹងពីស្ថានភាពរបស់ពួកគេ ។
- ចំណាយដ៏ខ្ពស់ដើម្បីទទួលបានឯកសារប័ណ្ណកម្មសិទ្ធិដី រាំងស្ទះដល់ការទទួលបានឥណទាន ព្រោះមានធនាគារតែមួយចំនួនតូចដែលអាចផ្តល់កំចីដោយមានការដាក់ដីធ្លីធានា ។
- ពង្រឹងការអនុវត្តច្បាប់ពាណិជ្ជកម្ម: បើគ្មានការពង្រឹងអនុវត្តច្បាប់នោះទេការមិនជឿទុកចិត្តនឹងកើនឡើង ។ កំណែលំអការពង្រឹងអនុវត្តច្បាប់ អាចកាត់បន្ថយការយកដីធ្វើជាវត្ថុធានា ដោយយកទ្រព្យដទៃ មកជំនួសវិញ ។

លោក Zhang Yuyan បានធ្វើការពិនិត្យជាលក្ខណៈតំបន់ដោយប្រៀបធៀបកំណើន និងការអភិវឌ្ឍរបស់ប្រទេសមួយចំនួនក្នុងតំបន់។ លោកបានលើកឡើងថា កំណើន ផសស ដ៏ខ្លាំងក្នុងប្រទេសចិន បានមកពីកំណែទំរង់ការបើកចំហប្រទេសចិន និងដំណើរការកាន់តែល្អនៃទីផ្សារ ។ លោកបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃសមាហរណកម្មក្នុងតំបន់ ក្នុងការជំរុញអោយទីផ្សារនានាក្នុងតំបន់បើកចំហកាន់តែច្រើន និងមានដំណើរការកាន់តែប្រសើរ ។

លោក Zhang Yuyan បានបញ្ជាក់ថា ប្រទេសចិនស្វាគមន៍ចំពោះការចូលរួមរបស់ប្រទេសកម្ពុជា ក្នុងការរៀបចំស្ថាប័នកិច្ចតំបន់ដូចជា អាស៊ាន និងសហប្រតិបត្តិការកិច្ចអនុតំបន់ (ដូចជា អនុតំបន់ទន្លេមេគង្គជាដើម) ។ ប៉ុន្តែដើម្បីទទួលបានផលប្រយោជន៍ពីសមាហរណកម្មតំបន់នេះ ប្រទេសជាសមាជិក គួរតែអនុវត្តវិធានការមួយចំនួនដូចតទៅ:

- ការពង្រឹងអនុវត្តច្បាប់អចលនទ្រព្យអោយបានតឹងរឹង មានសារៈសំខាន់ណាស់សំរាប់ការអភិវឌ្ឍទីផ្សារ ។ បញ្ហាចោទមួយគឺ តើស្ថាប័នណាទទួលខុសត្រូវធ្វើការពង្រឹងអនុវត្តច្បាប់នេះ ។
- កំណើនសកម្មភាពតំបន់ភាវូបនីយកម្ម ទំនងនាំអោយមានស្តង់ដារនីយកម្មនៃច្បាប់ពាណិជ្ជកម្ម ដែលនឹងជួយទ្រទ្រង់ការពង្រឹងអនុវត្តច្បាប់អចលនទ្រព្យ ។
- ដើម្បីពង្រឹងតួនាទីស្ថាប័នក្នុងតំបន់ ប្រទេសទាំងអស់ត្រូវមានសិទ្ធិស្មើគ្នា ហើយកិច្ចព្រមព្រៀងនានា ត្រូវបំរើផលប្រយោជន៍គ្នាទៅវិញទៅមក ។ ការពង្រឹងសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ទាមទារការអត់ធ្មត់ ព្រោះទំនាក់ទំនងរវាងប្រទេសចូលរួមមានភាពស្មុគស្មាញ ។

ខាងក្រោមនេះ ជាសេចក្តីសង្ខេបទស្សនៈរួមនៃការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច ដែលលោក John Nelmes បានបង្ហាញជូនអង្គសន្និសីទ ។

## ប្រទេសកម្ពុជា: ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច

លោក Nelmes បានដកស្រង់ការលូតលាស់សេដ្ឋកិច្ចនាពេលថ្មីៗមួយចំនួន ព្រមទាំងលើកជាជំរើសគោលនយោបាយខ្លះៗ ដើម្បីពង្រឹង និងរក្សាកំណើនអោយបានយូរអង្វែង ។ ផ្អែកតាមទំរង់នៃបទបង្ហាញ ផ្នែកនេះចែកចេញជាពីរភាគគឺ ភាគទី១ បង្ហាញពីការលូតលាស់នាពេលថ្មីៗ ព្រមទាំងចក្ខុវិស័យ រីឯភាគទី២ ធ្វើការពិចារណាពីជំរើសគោលនយោបាយមួយចំនួន ។

## ការលូតលាស់នាពេលថ្មីៗ និងចក្ខុវិស័យ

បទបង្ហាញរបស់លោក Nelmes ជាទូទៅកោតសរសើរពីស្ថានភាព និងការគ្រប់គ្រងសេដ្ឋកិច្ចកម្ពុជា ។ លោកបានលើកឡើងថា នៅឆ្នាំ២០០៧ ប្រទេសកម្ពុជាមានអត្រាកំណើន ៩.៥% ។ ប៉ុន្តែអត្រាកំណើននេះ ទំនងធ្លាក់ចុះបន្តិចវិញក្នុងរយៈពេលខ្លីខាងមុខ ដូចមានបង្ហាញជូនខាងក្រោម ដោយសារហេតុផលមួយចំនួន ដូចជាកំណើនអតិផរណាជាដើម ។

ទោះបីមានជោគជ័យល្អដូច្នេះក្តី លោក Nelmes បានក្រើនរំលឹកថា នៅមានបញ្ហាប្រឈម និងហានិភ័យធំៗមួយចំនួន ក្នុងរយៈពេលមធ្យមដូចជា ការបន្តធ្លាក់ចុះក្នុងវិស័យកាត់ដេរ និងកំណើនអតិផរណាដែលបណ្តាលមកពីកត្តាអន្តរជាតិ ។ ក្នុងបរិបទបែបនេះ កម្ពុជាពិបាកនឹងបន្តទទួលបានការលូតលាស់ខ្លាំងក្លា និងការកាត់បន្ថយភាពក្រីក្រដ៏ច្រើនៗ ។



ប្រភព: NIS and IMF est. and proj.

ក្នុងអំឡុងពេលនេះ សេដ្ឋកិច្ចកម្ពុជាមានអតិផរណាកើតខ្ពស់ដែលឆ្លុះបញ្ចាំងជាសំខាន់ ការឡើងថ្លៃប្រេង និងឡើងថ្លៃម្ហូបអាហារអន្តរជាតិ ។ ការ ធ្លាក់ថ្លៃប្រាក់ដុល្លារUS ក៏ជួយបង្កើនអតិផរណាដែរ ។ ម្យ៉ាងទៀត ក៏មានសញ្ញាខ្លះនៃសំពាធអតិផរណាក្នុងស្រុកដែរ ដែលបង្កជាសំខាន់ដោយសារកំណើនតំរូវការកំលាំងពលកម្ម ។



ប្រភព: NIS's CPI



ប្រភព: NIS's CPI

ទោះបីជាអតិផរណារំពឹងថានឹងថយចុះក្នុងឆ្នាំ២០០៨ក្ដី ក៏ហានិភ័យអតិផរណាបានកើនឡើង ។ ហានិភ័យទាំងនេះ មានប្រភពចំបងមកពីខាងក្រៅ ប៉ុន្ដែកត្ដាខាងក្នុងក៏ដើរតួនាទីសំខាន់ដែរ ។



*ប្រភព: NIS's CPI and IMF's projection*

មូលហេតុមួយនៃកំណើនសំពាធអតិផរណានេះគឺ នៅកម្ពុជាប្រព័ន្ធធនាគារបានរីកលូតលាស់យ៉ាងខ្លាំង ដែលនាំអោយមានកំណើនរូបិយវត្ថុយ៉ាងខ្លាំងដែរ ។ ក្រាហ្វិកខាងក្រោមបង្ហាញថា ការផ្ដល់ឥណទានបានកើនឡើងជាប់រហូតក្នុងអំឡុងពេលថ្មីៗនេះ ដែលជះឥទ្ធិពលដល់អត្រាកំណើនរូបិយវត្ថុ ។ ប្រសិនបើគ្មានការទប់ស្កាត់ទេ អត្រាអតិផរណានឹងកើនឡើងថែមទៀត ។ បើសិនកំណើនរូបិយវត្ថុមិនដើរស្របគៀកគ្នានឹង កំណើនពិតក្នុងសេដ្ឋកិច្ចទេ វាអាចនាំអោយមានកំណើនអតិផរណា ។



*ប្រភព: NBC's Monetary Survey*



*ប្រភព: NBC's Monetary Survey*

រដ្ឋាភិបាលកម្ពុជាមានកំណើនចំណូលខ្ពស់ តែមានកំណើនចំណាយទាប ។ ជាសញ្ញាសំគាល់នៃកំណែលំអក្នុងការងារគ្រប់គ្រងសេដ្ឋកិច្ច លោក Nelmes បានលើកថា ប្រាក់ចំណូលរបស់រដ្ឋកើន ២២% ក្នុងឆ្នាំ២០០៧ ដែលបញ្ជាក់ថាការប្រមូលពន្ធបានធ្វើឡើងយ៉ាងល្អ ។ កំណើនចំណូលនេះ មានផលវិជ្ជមានចំពោះចំណាយលើហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងសេវាថែទាំសុខភាព ។ ប៉ុន្ដែការទ្រទ្រង់ស្ថានភាពអោយនៅតែល្អតទៅទៀត អាចកាន់តែលំបាកប្រសិនបើកំណើនថយចុះក្នុងរយៈពេលមធ្យម ។ លោកបានបង្ហាញថា កំណើនចំណាយមានអត្រាទាបជាងកំណើនចំណូល ដូច្នេះរដ្ឋាភិបាលអាចបង្កើនប្រាក់បញ្ញើ និងកាត់បន្ថយឱនភាព (ក្រាហ្វិកខាងក្រោម) ដែលអាចធ្វើអោយអតិផរណាថយចុះខ្លះ ។ ប៉ុន្ដែដូចមានពិភាក្សាតាមក្រោយទៀត ចំណាយជាមូលធនរបស់រដ្ឋាភិបាលត្រូវកើនឡើងជាសំខាន់ ដើម្បីបង្កើនសក្ដានុពលនៃការរីកលូតលាស់ ។



*ប្រភព: MEF and IMF (Excl. MDRI in 2006)*



*ប្រភព: MEF and IMF (excl. MDRI in 2006)*

## បញ្ហាគោលនយោបាយ

តាមរយៈការពិនិត្យត្រួសៗពីសេដ្ឋកិច្ចដូចខាងលើ បញ្ហាជំរើសគោលនយោបាយមួយចំនួនបានផុសឡើង ក្នុងនេះមានមួយចំនួនបានលើកយកមកពិភាក្សាដូចខាងក្រោម ។

ដោយសារហេតុផលមួយចំនួន ជាពិសេសដើម្បីលើកកំពស់កំរិតជីវភាព ការរក្សាកំណើនអោយមានកំរិតខ្ពស់ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ជាកត្ដាសំខាន់បំផុត ។ តួលេខខាងក្រោមបង្ហាញពីប្រាក់ចំណូលសក្ដានុពលក្នុងមនុស្សម្នាក់ ដោយផ្អែកលើអត្រាកំណើនថេរក្នុងអំឡុងពេល ២២ឆ្នាំខាងមុខ ។ ដូចមានបង្ហាញក្នុងក្រាហ្វិក បំរែបំរួលអត្រាកំណើនតែបន្ដិច អាចធ្វើអោយកំរិតផសស ក្នុងមនុស្សម្នាក់ ប្រែប្រួលខុសគ្នាយ៉ាងច្រើន ក្នុងរយៈពេលដ៏ខ្លី ។ ភាពខុសគ្នារវាងសេណារីយ៉ូដែលបានបង្ហាញជូន វាជាប់ទាក់ទងជាសំខាន់នឹងភាពខុសគ្នារវាង គោលនយោបាយដែលបានអនុវត្ត ។ ចំពោះជំរើសគោលនយោបាយសំរាប់កំណើនខ្ពស់ ប្រទេសកម្ពុជាគួរអនុវត្តវិធានការមួយចំនួនដែលក្នុងនោះវិធានការសំខាន់ៗជាងគេមានដូចខាងក្រោម ។

ដើម្បីរក្សាបានអត្រាកំណើនខ្ពស់ រដ្ឋាភិបាលត្រូវចំណាយច្រើនថែមទៀតលើហេដ្ឋារចនាសម្ព័ន្ធ ការថែទាំសុខភាព និងអប់រំ ។ យោងតាមលក្ខណៈផ្ទាល់នៃសេវាកម្មទាំងនេះ ហើយនិងការរារែកនិងការលំបាកជាទូទៅរបស់វិស័យឯកជន ដើម្បីធ្វើវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ដ/សង្គមកិច្ច រដ្ឋាភិបាលត្រូវដើរតួនាទីប្រកបដោយប្រសិទ្ធភាពក្នុងវិស័យទាំងនោះ ។ ប្រទេសកម្ពុជានិងប្រទេសជិតខាង មានគំលាតគ្នាយ៉ាងខ្លាំង យោងតាមសូចនាករខាង







សេដ្ឋកិច្ច/សង្គមកិច្ច ដូចខាងក្រោម ហើយគំលាតទាំងនេះ ត្រូវតែកាត់បន្ថយ ។ ប៉ុន្តែដើម្បីអោយមានចីរភាព ចំណាយបែបនេះត្រូវតែដោះស្រាយតាមរយៈការប្រឹងប្រែងរកចំណូលយ៉ាងខ្លាំងក្លាជាបន្តទៀត ។ ក្រាហ្វិកខាងក្រោមបង្ហាញពី កំណើនប្រាក់ចំណូលរដ្ឋាភិបាលមជ្ឈិមដ៏ល្អមួយក្នុងពេលថ្មីៗនេះ ប៉ុន្តែតួលេខចុងក្រោយ នៅតែទាបជាងតួលេខមធ្យមសំរាប់ប្រទេសប្រហាក់ប្រហែលគ្នាឯទៀតនៅអាស៊ី ។










ដើម្បីអោយមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ជាការសំខាន់ដែរដែលត្រូវគ្រប់គ្រងអតិផរណាអោយបាន ហើយអតិផរណាកំរិតទាបជាកត្តាគន្លឹះសំរាប់កំណើន និងការកាត់បន្ថយភាពក្រីក្រ ។ ក្រាហ្វិកខាងក្រោមបង្ហាញពីចំណងទាក់ទាក់រវាងអតិផរណា និងកំណើន ផសស ក្នុងទសវត្សរ៍ចុងក្រោយនេះ ដែលជាទូទៅរយៈពេលមានអតិផរណាខ្ពស់ តែងមានកំណើន ផសស កំរិតទាប (១៩៩៥-២០០០) ហើយរយៈពេលមានអតិផរណាទាប តែងមានកំណើន ផសស ខ្ពស់ (២០០១-២០០៧) ។ កត្តាសំខាន់មួយទៀតដែលជួយជំរុញកំណើន គឺការត្រួតពិនិត្យវិស័យធនាគារយ៉ាងខ្លាំងក្លាជាបន្តទៀត ។ កំណើនលទ្ធភាពទទួលបានឥណទាន និងសេវាហិរញ្ញវត្ថុ មានសារៈសំខាន់ណាស់សំរាប់សេដ្ឋកិច្ចដែលកំពុងរីកលូតលាស់ ។ ការពឹងផ្អែកលើសេវាទាំងនេះទំនងជាពាក់ព័ន្ធដោយផ្ទាល់ទៅនឹង ទំនុកចិត្តរបស់អ្នកប្រើប្រាស់ទៅលើវិស័យធនាគារ ហើយការត្រួតពិនិត្យយ៉ាងខ្លាំងក្លាលើ សេវាកម្មធនាគារ អាចជាមធ្យោបាយមួយសំរាប់បង្កើនទំនុកចិត្តនេះ ។

## សេចក្ដីសន្និដ្ឋានសំរាប់វគ្គ

សារដែលផុសចេញពីវគ្គនេះគឺ សេដ្ឋកិច្ចជាទូទៅមានស្ថានភាពល្អ ហើយចក្ខុវិស័យខាងម៉ាក្រូសេដ្ឋកិច្ចក៏ល្អប្រសើរដែរ ។ ប៉ុន្តែយោងតាមកំរិតអភិវឌ្ឍន៍ប្រទេសយ៉ាងទាប ដូចបញ្ជាក់ឡើងដោយតួលេខ ផសស ក្នុងមនុស្សម្នាក់ យុទ្ធសាស្ត្រដើម្បីសំរេចកំណើនកំរិតខ្ពស់គឺសំខាន់ខ្លាំងណាស់ ។ ដើម្បីទ្រទ្រង់យុទ្ធសាស្ត្រនេះ វិធានការមួយចំនួនត្រូវអនុវត្ត ដើម្បីការពារស្ថិរភាពសេដ្ឋកិច្ចកុំអោយមានការប៉ះពាល់អវិជ្ជមាន ហើយក្នុងនេះត្រូវសង្កត់ធ្ងន់លើការគ្រប់គ្រងអតិផរណា ។ ចំណុចសំខាន់មួយទៀតគឺត្រូវធានាថា កំណើនសេដ្ឋកិច្ចមានលក្ខណៈ "រាប់បញ្ចូល" និងផ្ដល់ផលចំណេញស្មើភាពគ្នាដល់អ្នកចូលរួមទាំងអស់។ ក្នុងបរិបទនេះ បញ្ហាចោទខាងស្ថាប័ន និងអភិបាលកិច្ចត្រូវតែដោះស្រាយប្រកបដោយប្រសិទ្ធភាព ។ បញ្ហាមួយដែលកម្ពុជាកំពុងប្រឈមមុខគឺ ភាពក្រីក្រកំរិតខ្ពស់ និងល្បឿនកាត់បន្ថយភាពក្រីក្រយឺត ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះអោយកាន់តែមានប្រសិទ្ធភាព ចាំបាច់ត្រូវធ្វើអោយកសិកម្មកាន់តែមានសន្ទុះឡើង ហើយរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៧-០៨ បោះពុម្ពផ្សាយដោយ CDRI[៥] មានផ្ដល់ព័ត៌មានលំអិតមួយចំនួនពីមធ្យោបាយដើម្បីទទួលបានជោគជ័យនេះ ។

## កំណត់សំគាល់

១. អគ្គលេខាធិការនៃឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានក្រុមប្រឹក្សាភិបាលនៃ CDRI
២. តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំប្រទេសកម្ពុជា
៣. ប្រធានផ្នែកសេវាកម្មហិរញ្ញវត្ថុសំរាប់សហគ្រាសនៃធនាគារ ANZ Royal
៤. សាស្ត្រាចារ្យ និងនាយកវិទ្យាស្ថានសិក្សាអាស៊ីប៉ាស៊ីហ្វិក បណ្ឌិតសភាវិទ្យាសាស្ត្រសង្គមចិននៃសាធារណរដ្ឋប្រជាមានិតចិន
៥. CDRI (២០០៨) សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៧-០៨

# ការទាញផលប្រយោជន៍ឱ្យបានប្រសើរបំផុតពីធនធានធម្មជាតិនៅកម្ពុជាៈ ព្រៃឈើ ជលផល រ៉ែ

*បណ្ឌិត Brett M. Ballard សង្ខេបពីខ្លឹមសារសំខាន់ៗនៃបទបង្ហាញទាំង៤ ក្នុងវគ្គទី២ នៃសន្និសីទចក្ខុវិស័យឆ្នាំ២០០៨ ហើយនិងលទ្ធផលនៃការពិភាក្សាជាបន្តមកទៀត ។ **

ក្នុងសុន្ទរកថាបើកសន្និសីទ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកត់សំគាល់ថា ភាពសំបូរធនធានធម្មជាតិ គឺជាផ្លូវឆ្ពោះទៅរកការអភិវឌ្ឍ ការរីកលូតលាស់ និងវិបុលភាព ប៉ុន្តែការធ្វើអោយធនធានក្លាយជាពរជ័យគឺជាបញ្ហាប្រឈមមួយ ។ សម្តេចបានបន្តទៀតថា កម្ពុជាបានមើលឃើញបញ្ហាមួយចំនួន ទាក់ទងនឹងការប្រើប្រាស់ ការគ្រប់គ្រងដីធ្លី ព្រៃឈើ និងជលផល ហើយការប្រើប្រាស់ដីមិនអស់លទ្ធភាព ការកាប់ទន្ទ្រានព្រៃឈើយកដី និងទំនាស់លើការកាន់កាប់ដីធ្លីនិងធនធានធម្មជាតិ នៅតែជាបញ្ហាប្រឈមសំរាប់រដ្ឋាភិបាល ។ សម្តេចបានបញ្ជាក់ថា ការរកឃើញប្រេងកាតនិងឧស្ម័នធម្មជាតិ បានធ្វើអោយមានការជជែកដេញដោលលើការគ្រប់គ្រងចំណូលពីធនធានទាំងនេះ ប៉ុន្តែបញ្ហាចំបងបំផុតរបស់កម្ពុជាក្នុងរយៈពេលមធ្យម គឺ តើប្រេងកាត និងចំណូលផ្សេងៗ អាចជំរុញអោយមានចំរុះកម្មសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រកាន់តែច្រើន រឺយ៉ាងណា ។

## សេចក្តីផ្តើមៈ សារគន្លឹះ

វាគ្មិនទាំង ៤ ក្នុងវគ្គនេះ បានបញ្ជាក់ឡើងវិញពីបញ្ហាជាច្រើនទាក់ទងនឹងជលផល និងព្រៃឈើ ដែលគេបានដឹងជាទូទៅហើយ ។ ព្រៃឈើ និងជលផល គឺជាធនធានធម្មជាតិដ៏សំខាន់សំរាប់កម្ពុជា ។ វាបានចូលរួមយ៉ាងច្រើនក្នុងខ្ទង់កសិកម្មនៃ ផសស ជួយបង្កើតការងារ និងផ្តល់ស្បៀងអាហារ និងអុស-ធ្យូង សំរាប់ប្រជាជនកម្ពុជាភាគច្រើន ។ ទោះបីជាមានក្របខណ្ឌច្បាប់ នឹងគោលនយោបាយសំរាប់ការពារធនធានព្រៃឈើនិងជលផលក្តី ប៉ុន្តែកំណើនប្រជាជន ការប្រើប្រាស់យ៉ាងច្រើនទូវ របៀបខុសច្បាប់ដើម្បីប្រមូលយកផលពីធនធានធម្មជាតិ និងការដាក់អនុវត្តច្បាប់នៅខ្សោយ បានធ្វើអោយវត្តមាន និងលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ ធ្លាក់ចុះយ៉ាងលឿន ។ របៀបអនុវត្តបែបនេះ បានចោទបញ្ហាយ៉ាងច្រើនដល់ការគ្រប់គ្រងធនធានធម្មជាតិអោយមានប្រសិទ្ធភាពដើម្បីកាត់បន្ថយភាពក្រីក្រ ។

រដ្ឋាភិបាលដឹងច្បាស់ថា ធនធានធម្មជាតិដើរតួនាទីសំខាន់ណាស់ ព្រោះវាជាប្រភពចំណូលចំបង សំរាប់ប្រជាជនកម្ពុជារាប់លាននាក់នៅតាមជនបទ ហើយបានចាត់ទុកការគ្រប់គ្រងធនធាននេសាទ និងព្រៃឈើប្រកបដោយប្រសិទ្ធភាព ជាកត្តាចំបងមួយសំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍចតុកោណ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ (រាជរដ្ឋាភិបាលកម្ពុជា ២០០៦) ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលផ្សព្វផ្សាយដោយក្រសួងផែនការ បានបញ្ជាក់ច្បាស់ថា ប្រសិនបើអាចបញ្ឈប់ការខូចខាតធនធានធម្មជាតិបាន គោលដៅជាទូទៅនៃការកាត់បន្ថយភាពក្រីក្រ គឺអាចសំរេចបានយ៉ាងងាយ ។ វាគ្មិនទាំង ៤ យល់ស្របថា កិច្ចខំប្រឹងប្រែងរួមគ្នាគួរតែធ្វើឡើងដើម្បីកែប្រែនិន្នាការថយចុះ/ខូចខាតធនធានធម្មជាតិ អោយទៅជាការរីកលូតលាស់ធនធាននេះវិញ ដើម្បីផ្តល់ផលប្រយោជន៍ជាអតិបរមាដល់ប្រជាជនក្រីក្រនៅជនបទ ។ រីឯធនធាននេសាទក៏ដូចគ្នាដែរ បើសិនមានការគ្រប់គ្រងយ៉ាងត្រឹមត្រូវ វាអាចរួមចំណែកបានច្រើនថែមទៀតដល់ការកាត់បន្ថយភាពក្រីក្រ ។

វាគ្មិនក៏បានសង្កេតឃើញថា ទិដ្ឋភាពមួយចំនួននៃកំណែទំរង់គោលនយោបាយ ដូចជា ការដកហូតយកដីព្រៃមកវិញ ការដាក់បំរាមកាប់ព្រៃឈើ និងការបង្កើតសហគមន៍ព្រៃឈើនិងនេសាទ គឺកំពុងអនុវត្តហើយនាបច្ចុប្បន្ន ។ ប៉ុន្តែការដាក់អនុវត្តច្បាប់ និងបទបញ្ញត្តិមានស្រាប់ រួមទាំងការការពារ និងដាក់ពិន័យចំពោះការនេសាទ និងកាប់ព្រៃឈើខុសច្បាប់ នៅតែចោទបញ្ហាខ្លាំង ។ ការទន្ទ្រានយកដី ការកែប្រែដីព្រៃ ការរំលោភយកដី និងទំនាស់ដីធ្លីបានកើនឡើង រួមទាំងនៅតំបន់ការពារ ។ របៀបរបបអនុវត្តមួយចំនួន ដូចជាការយកឈើធ្វើអុស-ធ្យូង និងសំណង់ ក៏ជាឧបសគ្គធំមួយដល់ការអភិរក្សដែរ ។

សម្បទានដីសេដ្ឋកិច្ច (ELCs) មិនបានជំរុញការអភិរក្ស និងការគ្រប់គ្រងធនធានឱ្យបានសក្តិសិទ្ធិនោះទេ ពីព្រោះវាបានរឹតបន្តឹងការប្រើប្រាស់ដីប្រកបដោយផលិភាព និងក្លាយជាខែលការពារការកាប់ព្រៃឈើខុសច្បាប់ ។ វាគ្មិន ២រូប បានលើកមតិថា ELCs គួរពិចារណាឡើងវិញពីបញ្ហាសម្បទានដីសេដ្ឋកិច្ច និងហើយក្នុងករណីខ្លះគួរបញ្ចប់វាតែម្តង ។

ការស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI និងការសិក្សាមួយចំនួនទៀត បានបង្ហាញថា ផលប្រយោជន៍នៃអាជីវកម្មលើធនធានធម្មជាតិ ពុំបានបែងចែកទៅដល់ប្រជាជនភាពស្មើគ្នាល្អទេ ប៉ុន្តែបានបង្កើនវិសមភាពខាងសេដ្ឋកិច្ច និងការប្រមូលផ្តុំទ្រព្យសម្បត្តិទៅក្នុងដៃអ្នកធូរធារ និងអ្នកមានអំណាច ។ សេដ្ឋកិច្ចនយោបាយនៃ ការធ្វើអាជីវកម្មធនធានធម្មជាតិ ទាមទារការស្រាវជ្រាវបន្ថែមទៀត ។

## ការរីកលូតលាស់ និងអានិភាព

ឯកឧត្តម ច័ន្ទ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បានកត់សំគាល់ថា ជលផលជាធនធានចំបងមួយ និងជាប្រភពស្បៀងអាហារដ៏សំខាន់សំរាប់ប្រជាជនកម្ពុជា ។ ម៉្យាងទៀត ២៤.៩% នៃ ផសស ខាងកសិកម្ម គឺបានមកពីជលផល ។ នេសាទបំរើតំរូវការស្បៀងអោយប្រជាជន ៦លាននាក់ និងបង្កើតការងារជាច្រើន ។ ប្រជាជនកម្ពុជាប្រមាណ ៤៥% ពឹងផ្អែកលើការនេសាទក្នុងរូបភាពណាមួយ ។ រដ្ឋាភិបាលបានជឿនលឿនយ៉ាងច្រើនក្នុងការថែរក្សាស្តុកត្រី តាមរយៈការបង្កើតសហគមន៍នេសាទ ។

ឯកឧត្តម ច័ន្ទ តុងអ៊ីវ បានកត់សំគាល់ទៀតថា គោលនយោបាយទាក់ទងនឹងការគ្រប់គ្រងធនធានជលផល និងព្រៃឈើ គឺមានស្រេចហើយ ។ វិស័យព្រៃឈើតំណាងអោយ ៧% នៃ ផសស ដូច្នេះការកាប់ព្រៃឈើ នឹងជះឥទ្ធិពលដល់ចំណែកព្រៃឈើ ក្នុង ផសស ។ នាបច្ចុប្បន្ន មានការដាក់វិធានការមួយចំនួនដើម្បីទប់ស្កាត់ការកាប់ និងការបំផ្លាញព្រៃឈើខុសច្បាប់ រួមទាំង

* បណ្ឌិត Brett M. Ballard គឺជាទីប្រឹក្សាស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថាន CDRI

ការប្រើឧបករណ៍ខុសច្បាប់ផងដែរ ។ សព្វថ្ងៃរដ្ឋាភិបាលកំពុងដកហូតយកព្រៃឈើមកវិញ និងដាក់ព្រៃមួយចំនួនជាព្រៃបំរុងទុក ។ ប្រទេសកម្ពុជាបានចូលរួមក្នុង អង្គការព្រៃឈើអន្តរជាតិជាច្រើន ។គណៈកម្មាធិការសហគមន៍ព្រៃឈើជាច្រើនក៏បានបង្កើតឡើងដែរ ដើម្បីជួយគ្រប់គ្រងធនធានព្រៃឈើ ។

បណ្ឌិត តុប នេត នៃវិទ្យាស្ថាន CDRI បានលើកថា ការពឹងផ្អែកលើធនធានធម្មជាតិ គឺជាលក្ខណៈសំគាល់ដ៏សំខាន់មួយរបស់ ប្រជាជននៅតាមជនបទ ហើយការបញ្ឈប់ការបំផ្លិចបំផ្លាញធនធានធម្មជាតិគឺចាំបាច់ខ្លាំងណាស់ ដើម្បីកាត់បន្ថយភាពក្រីក្រ ។ ប្រជាជនកម្ពុជាជាង ៨០% រស់នៅតាមតំបន់ជនបទ ។ ពួកគេភាគច្រើនជាកសិករ ហើយពឹងអាស្រ័យលើផលិតផលនេសាទ និងព្រៃឈើ ដើម្បីទ្រទ្រង់ជីវភាព ។ ឯកសារបោះពុម្ពផ្សាយមួយរបស់ UNDP (២០០៧) បានរាយការណ៍ថា សំរាប់ប្រជាជនកម្ពុជា ត្រី និង ផលិតផលត្រី រួមចំណែកដល់ទៅ ៧៥% នៃការហូបប្រូតេអ៊ីនសរុបពីប្រភពសត្វ ហើយ ប្រជាជនជាង ១លាននាក់ សព្វថ្ងៃរកចិញ្ចឹមជីវិតដោយការនេសាទ ។

ជំរឿនប្រជាជនទូទាំងប្រទេសឆ្នាំ១៩៩៨ បានបង្ហាញថា ប្រមាណ ៩២% នៃប្រជាជនសរុបពឹងអាស្រ័យលើអុស-ធ្យូងដើម្បីចំអិនអាហារ[1] ។អនុផលព្រៃឈើក៏ជាប្រភពដ៏សំខាន់មួយនៃស្បៀង និងប្រាក់ចំណូលសំរាប់គ្រួសារជាច្រើន នៅជនបទ ។ ឧទាហរណ៍ ការសិក្សាថ្មីមួយ (Hansen and Neth 2006) លើ ៥០២គ្រួសារ ក្នុង ១៦ភូមិ នៅខេត្តកំពង់ធំ ពោធិ៍សាត់ មណ្ឌលគិរី និងក្រចេះ បាន រកឃើញថា គ្រួសារក្រីក្ររកបានពីព្រៃជាមធ្យម ៤២% (២៨០ដុល្លារ) នៃតំលៃ ទ្រទ្រង់ជីវភាព រីឯគ្រួសារមានចំណូលមធ្យមរកបាន ៣០% (៣៨៥ដុល្លារ) ។

> *ការកាប់បំផ្លាញព្រៃឈើទ្រង់ទ្រាយធំក្នុងដែនរងទឹកភ្លៀងនៃស្ទឹង-ទន្លេនានា បានធ្វើឱ្យប្រែប្រួលលំហូរទឹក និងគុណភាពទឹកនៅខ្សែទឹកខាងក្រោម ដែលប៉ះពាល់ដល់ការពងកូនរបស់ត្រី និងស្តុកត្រី ។ ម្យ៉ាងទៀត ព្រៃលិចទឹក នៅជុំវិញបឹងទន្លេសាបកំពុងរងការកាប់បំផ្លាញ ហើយបានប៉ះពាល់អវិជ្ជមានដល់តំបន់ត្រីពងកូនដ៏សំខាន់ៗជាច្រើន ។*

ផ្ទៃដីព្រៃឈើនៅកម្ពុជា បានថយចុះ ២,៦លាន ហ.ត ក្នុងអំឡុងពេល ៣០ឆ្នាំ (១៩៧០-២០០២) រឺស្មើនឹងការបាត់បង់ប្រចាំឆ្នាំ ៨១.០០០ហ.ត (CMDGs ២០០៥) ។ បន្ទាប់ពីការលុបចោលសម្បទានព្រៃឈើ ដែលតំណាងឱ្យជាង ៥០% នៃផ្ទៃដីស្ថិតក្រោមរបបសម្បទាន និងការផ្អាកការកាប់ឈើចាប់ពីឆ្នាំ២០០២ មក ការកាប់ឈើទ្រង់ទ្រាយធំ បានថយចុះគួរអោយកត់សំគាល់ ។ ប៉ុន្តែការកាប់ឈើខុសច្បាប់នៅតែជាក្តីបារម្ភ នៅតាមតំបន់ជាច្រើនក្នុងប្រទេសកម្ពុជា ។ ម្យ៉ាងទៀត កំណើនប្រជាជននៅជនបទ ការទន្ទ្រានយកដី និងការរំលោភយកដី បានក្លាយជាការគំរាមកំហែងដ៏ធំមួយ ។ ដីព្រៃកាន់តែច្រើនត្រូវបានកែប្រែទៅបំរើគោលដៅផ្សេងៗ ដូចជា ការដាំស្វាយចន្ទី ដំឡូងឈើ សណ្តែកសៀង ពោត និងកៅស៊ូ ហើយការយកឈើធ្វើអុស-ធ្យូង គ្មានថយចុះទេ ។ ការឡើងថ្លៃដី ក៏ជំរុញឱ្យមានការកាប់ឆ្ការព្រៃយកដីកាន់តែច្រើន ហើយទំនាស់លើការកាន់កាប់ដីក៏ផុសឡើងនៅតាមតំបន់ជាច្រើន ។

ប្រភពមួយទៀតនៃការបាត់បង់ព្រៃឈើគឺការផ្តល់សម្បទានដីសេដ្ឋកិច្ច ។ នៅខែកុម្ភៈ ២០០៧ ដីស្ថិតក្រោមរបប សម្បទានដីសេដ្ឋកិច្ច មាន ០.៩៤លាន ហ.ត ដោយមានការចុះកិច្ចព្រមព្រៀងជាមួយ ៥៧ក្រុមហ៊ុន (MAFF 2007) ។ ប៉ុន្តែនៅចុងឆ្នាំ២០០៥ ផ្ទៃដីដែលក្រុមហ៊ុនបានដាំដុះហើយ មានតែ ១.៨% នៃផ្ទៃដីសម្បទានសរុប (UNDP 2007) ។ វិភាគសង្ខេបមួយធ្វើឡើងដោយវិទ្យាស្ថាន CDRI លើដីសម្បទាន ៨កន្លែង ដោយធៀបនឹងគំរបព្រៃឈើនៅឆ្នាំ១៩៩៧ បង្ហាញថា ៧០% នៃផ្ទៃដីរបស់ពួកគេ គឺជាព្រៃ (Hansen and Neth 2006) ។ របាយការណ៍ UNDP (២០០៧) បានបញ្ជាក់ថា ដីមួយចំនួនក្នុងគំរោងនេះ កំពុងតែប្រើប្រាស់សំរាប់កាប់យកឈើលក់ ។ សម្បទានដីសេដ្ឋកិច្ច មិនបាន បំរើដល់ការអភិរក្សទេ ។ មានតែ ២% នៃផ្ទៃដីប៉ុណ្ណោះដែលមានការដាំដុះ ហើយការកាប់ឈើដោយខុសច្បាប់នៅតែបន្ត ។

ការសិក្សារបស់វិទ្យាស្ថាន CDRI លើការវាយតំលៃភាពក្រីក្រដោយមានការចូលរួមនៅតំបន់ទន្លេសាប បានរកឃើញថា ការធ្លាក់ចុះធនធានជលផលកើតមាននៅក្នុងភូមិនេសាទបានអង្កេតទាំង ៥ (ព្រែកស្រមោច និងទ្រាយនៅខេត្តសៀមរាប ដែរនាត នៅខេត្តពោធិ៍សាត់ កោះតាពៅ និងពេជ្រចក្រីនៅខេត្តកំពង់ធំ) ។UNDP (២០០៧) ក៏បានរាយការណ៍ដែរថា ស្តុកត្រីទឹកសាបដែលអ្នកនេសាទតូចតាចអាចទៅនេសាទបាន គឺបានធ្លាក់ចុះជាបន្តបន្ទាប់ ។

ជនចំណាកស្រុកកាន់តែច្រើនចូលទៅក្នុងតំបន់នេសាទ និងការខូចខាតប្រព័ន្ធអេកូឡូស៊ី បានធ្វើអោយធនធានជលផល ធ្លាក់ចុះក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ។ ការកាប់បំផ្លាញព្រៃឈើទ្រង់ទ្រាយធំក្នុងដែនរងទឹកភ្លៀងនៃស្ទឹង-ទន្លេនានា បានធ្វើឱ្យប្រែប្រួលលំហូរទឹក និងគុណភាពទឹកនៅខ្សែទឹកខាងក្រោម ដែលប៉ះពាល់ដល់ការពងកូនរបស់ត្រី និងស្តុកត្រី ។ ម្យ៉ាងទៀត ព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាបកំពុងរងការកាប់បំផ្លាញ ហើយបានប៉ះពាល់អវិជ្ជមានដល់តំបន់ត្រីពងកូនដ៏សំខាន់ៗជាច្រើន ។ អ្នកនេសាទតូចតាចជាច្រើនបានធ្វើនេសាទដោយខុសច្បាប់ និងប្រើរបៀបនេសាទ ដែលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី ដូចជា ការប្រើគ្រឿងផ្ទុះ និងឧបករណ៍ឆក់ត្រី ដើម្បីចាប់ត្រីជាដើម ។ អ្នកនេសាទទាំងអស់ ហាក់ដូចព្យាយាមចាប់ត្រីឱ្យតែបានច្រើនបំផុត ដោយពុំគិតគូរពីអនាគតយូរអង្វែងនៃការនេសាទត្រីក្នុងតំបន់នីមួយៗនោះទេ ។

លោក ឈិត សំអាត នាយកប្រតិបត្តិនៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានកត់សំគាល់ថា សង្គមស៊ីវិល បានចាប់អារម្មណ៍កាន់តែច្រើនឡើងហើយលើការគ្រប់គ្រងធនធានធម្មជាតិ ។ លោកបានលើកពី គ្រោះថ្នាក់នៃការធ្វើអាជីវកម្មគ្មានការគ្រប់គ្រងនិងការបែងចែកផលប្រយោជន៍មិនស្មើភាពគ្នា រួមទាំងបញ្ហាចំណូលដ៏ស្តួចស្តើងបានមកពីវិស័យព្រៃឈើសំរាប់ថវិកាជាតិ ។ លោកក៏បានបញ្ជាក់ពីសារៈសំខាន់នៃការថ្លឹងថ្លែងឱ្យមានតុល្យភាពរវាងសម្បទានដីសេដ្ឋកិច្ច ហើយនិងតំរូវការការពារបរិស្ថាន និងកាត់បន្ថយភាពក្រីក្រ ។ នាបច្ចុប្បន្ន ការវាយតំលៃពីផលប៉ះពាល់លើបរិស្ថាន នៅខ្វះខាតនៅឡើយ ហើយមធ្យោបាយក៏ខ្វះខាតដែរដើម្បីដោះស្រាយបណ្តឹងតវ៉ាស្តីពីផលប៉ះពាល់អវិជ្ជមាននៃសម្បទានដីសេដ្ឋកិច្ច ទៅលើជីវភាពរស់នៅក្នុងមូលដ្ឋាន ព្រមទាំងការរស់នៅរបស់ជនជាតិភាគតិច ។ កំណែទំរង់ថ្មីៗ ក្នុងវិស័យជលផលទទួលបានការគាំទ្រច្រើន ប៉ុន្តែការអនុវត្តជាក់ស្តែងនៅតែចោទបញ្ហា ពីព្រោះការពង្រឹងអនុវត្តច្បាប់ មានទំនោរអនុគ្រោះដល់អ្នកនេសាទទ្រង់ទ្រាយធំ ។

## បញ្ហាប្រឈមចំបងៗ

ឯកឧត្តម ច័ន្ទ តុងអ៊ីវ បានលើកថា ការបន្តប្រើប្រាស់ឈើដើម្បីសាងសង់ផ្ទះ

មានន័យថា តំរូវការធនធានព្រៃឈើ នៅតែមានកំរិតខ្ពស់ ។ កម្ពុជាមានច្បាប់ជាស្រេចហើយ ប៉ុន្តែការយល់ដឹង និងការអនុវត្តនៅខ្សោយនៅឡើយ ។ បញ្ហាប្រឈម មានជាអាទិ ការទន្ទ្រានយកដីព្រៃ ការកាប់បំផ្លាញព្រៃឈើ ការពង្រឹងអនុវត្តច្បាប់ខ្សោយ និងសមត្ថភាពមានកំរិតនៃមន្ត្រីព្រៃឈើតាមមូលដ្ឋាន ។ ការលើកស្ទួយផលិតផលព្រៃឈើដើម្បីកាត់បន្ថយភាពក្រីក្រ ក៏ជាតំរូវការមួយដែរ ។ ប្រជាជនធម្មតាត្រូវការមានលទ្ធភាព និងសុវត្ថិភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ព្រៃឈើ ។ បញ្ហាព្រៃឈើគួរតែដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ ហើយការគ្រប់គ្រងព្រៃឈើក៏ត្រូវមានតម្លាភាពផងដែរ ។

ការធ្លាក់ចុះស្តុកត្រីធម្មជាតិ វាជាប់ទាក់ទងនឹងការបាត់បង់ព្រៃលិចទឹក ការនេសាទហួសកំរិត កំណើនប្រជាជន និងការប្រើប្រាស់ឧបករណ៍នេសាទទំនើបនិងខុសច្បាប់ ។ ធនធានទឹកបានថយចុះ ជាពិសេសទឹកជំនន់ទន្លេមេគង្គ ដែលប៉ះពាល់ដល់គុណភាព និងបរិមាណត្រី ។ ដូច្នេះត្រូវតែពង្រឹងអនុវត្តច្បាប់អោយខ្លាំងឡើងទៀត ដើម្បីការពារស្តុកត្រីធម្មជាតិ និងបញ្ឈប់ការនេសាទខុសច្បាប់ ។ ផលប៉ះពាល់នៃទំនប់វារីអគ្គិសនីលើគុណភាពទឹកនៃតំបន់ខ្សែទឹកខាងក្រោម ក៏ជាការបារម្ភដ៏ធំមួយដែរ ។

លោក ឡាយ ឃីម មកពី UNDP បានលើកឡើងពីចំណុចសំខាន់មួយពាក់ព័ន្ធនឹងវិធីវាស់វែងតំលៃធនធានធម្មជាតិ (មូលធនធនធានធម្មជាតិ) និងជាពិសេសតំលៃបាត់បង់ធនធានគិតតាម ផសស និងប្រព័ន្ធគណនេយ្យជាតិ ។ ធនធានធម្មជាតិ ក៏ជា ទ្រព្យសកម្មមូលធន ដែរ ប៉ុន្តែពុំមានបង្ហាញនៅក្នុងគណនេយ្យជាតិទេ រួមទាំងការបាត់បង់របស់វាផង ។ បញ្ហានេះនាំឱ្យអ្នកធ្វើផែនការមិនបានដឹងច្បាស់ពីតំលៃសេដ្ឋកិច្ចពិតប្រាកដ និងអត្រានៃការខូចខាតព្រៃឈើ ។ ដើម្បីបញ្ឈប់ការហិនហោចធនធាននេះ ប្រាក់ចំណូលទទួលបានគួរតែគ្រប់គ្រង និងចែកចាយយ៉ាងប្រយ័ត្នប្រយែងបំផុត ហើយយកទៅប្រើប្រាស់ដើម្បី បង្កើតមូលធនក្នុងទំរង់ផ្សេងទៀត ដើម្បីកុំឱ្យត្រូវពឹងផ្អែកជានិច្ចជាកាលទៅលើធនធានដែលកំពុងថយចុះ និងមានការតវ៉ានេះ។ នាបច្ចុប្បន្ន ប្រាក់ចំនូលដែលរដ្ឋាភិបាលទទួលបានពីការធ្វើអាជីវកម្មព្រៃឈើ វាមានមិនច្រើនទេ និងមានតម្លាភាពតិចតួចពេក ក្នុងបែបបទប្រមូលវាមក និងយកវាទៅចំណាយ ។

លោក ឡាយ ឃីម ក៏បានសង្កេតឃើញថា ប្រទេសក្រីក្រមានទំនោរពឹងផ្អែកលើធនធានធម្មជាតិ សំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច រីឯប្រទេសអភិវឌ្ឍខ្ពស់ជាងនោះ តែងពឹងផ្អែកច្រើនជាងទៅលើមូលធនបែបអរូបី ។ ធនធានធម្មជាតិក៏ពិបាកស្តារឱ្យល្អឡើងវិញដែរៈ កាលណាវាបាត់បង់ហើយ វានឹងបាត់បង់រហូត ។ វាគ្មិនបានផ្តល់មតិថា គេចាំបាច់ត្រូវបែរចេញពីការពឹងអាស្រ័យលើធនធានធម្មជាតិ មកពឹងផ្អែកលើទ្រព្យសកម្មអរូបី ដូចជា អភិបាលកិច្ចល្អ ធនធានមនុស្ស និងកំរិតជំនាញការងារ ជាដើម ។ បច្ចុប្បន្ននេះវាជារឿងសំខាន់ណាស់ដែលត្រូវបែងចែកចំណូលបានមកពីធនធានធម្មជាតិ យកទៅអភិវឌ្ឍមូលធនផ្សេងៗទៀត ។

លោក តុប នេត បានបង្ហាញថា វាជាអាទិភាពខ្ពស់បំផុតមួយដែលត្រូវធានាឱ្យមាន ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើដែននេសាទសហគមន៍ និងព្រៃឈើសហគមន៍ ។ ការនេសាទជាច្រើនប្រើប្រាស់មធ្យោបាយខុសច្បាប់ ដូចជា គ្រឿងផ្ទុះ និង ឧបករណ៍ឆក់ត្រីជាដើម ។ ទង្វើនេះនាំអោយស្តុកត្រីធម្មជាតិធ្លាក់ចុះយ៉ាងខ្លាំង ។ ដូច្នេះត្រូវមានការប្រឹងប្រែងរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ ។ ម្យ៉ាងទៀត ត្រូវធ្វើការវាយតំលៃពីការនេសាទត្រីដែលអនុវត្តបានយូរអង្វែង និងត្រូវរក្សាបរិមាណត្រីចាប់បានឱ្យស្ថិតនៅត្រឹមកំរិតមួយដែលមានចីរភាព ។

ការពង្រីកផ្ទៃដីស្ថិតក្រោមរបបព្រៃឈើសហគមន៍ (CF) និងកំណែលំអការគ្រប់គ្រង គឺជាវិធីសាស្ត្រមួយដ៏ល្អ ដើម្បីឱ្យមានការចូលរួមគ្រប់គ្រងព្រៃឈើ ការធានាពីជីវភាពរស់នៅរបស់ប្រជាជនក្រីក្រដែលពឹងអាស្រ័យលើព្រៃឈើ និងការសំរេចបានការប្រើប្រាស់មានចីរភាពនូវធនធានព្រៃឈើ ។ មកដល់ឆ្នាំ២០០៧ ផ្ទៃដីស្ថិតក្រោមរបបព្រៃឈើសហគមន៍ មានប្រហែល ០,១៨លាន ហ.ត (២៦៤ សហគមន៍) រឺស្មើនឹង ១,៦% នៃផ្ទៃដីព្រៃឈើសរុប ។ គួរកត់សំគាល់ថា ព្រៃឈើសហគមន៍ភាគច្រើនស្ថិតក្នុងតំបន់ព្រៃឈើខូចគុណភាព ។ ប្រសិនបើចង់ឱ្យសហគមន៍ព្រៃឈើអាចរស់រាន ដោយខ្លួនឯងបាន រដ្ឋាភិបាលគួរតែលៃចែកព្រៃឈើដែលមានតំលៃជាងនេះ ទៅឱ្យគំរោងព្រៃឈើសហគមន៍ ។

សព្វថ្ងៃសម្បទានដីសេដ្ឋកិច្ចមួយចំនួន កំពុងតែប្រើប្រាស់ដើម្បីកាប់យកឈើ ។ ដូច្នេះគេចាំបាច់ត្រូវសើរើពិនិត្យនូវ កិច្ចព្រមព្រៀងដែលមានស្រាប់នានា ហើយអាចបញ្ចប់សម្បទានណាដែលបំពានកិច្ចព្រមព្រៀង ។ នៅពេលសើរើពិនិត្យឡើងវិញនេះ គួរយកចិត្តទុកដាក់ច្រើនថែមទៀតលើផលប្រយោជន៍ដែលបានដល់ប្រជាជនមូលដ្ឋាន និងតំលៃខូតខាតធនធានធម្មជាតិ ។

ការពង្រឹងកិច្ចការពារព្រៃឈើ និងការលើកកំពស់ការងារអភិរក្ស ក៏សំខាន់ណាស់ដែរ ។ នៅឆ្នាំ១៩៩៣ មានការកំណត់តំបន់ព្រៃការពារចំនួន ២៣ នៅកម្ពុជា ដែលគ្របដណ្តប់លើផ្ទៃដីជាង ៣,១៣លាន ហ.ត ។ ប៉ុន្តែនៅតែមានរបាយការណ៍ពីការកាប់ឈើខុសច្បាប់ និងការរំលោភយកដី ក្នុងតំបន់ការពារមួយចំនួន ។ ដូច្នេះ ការដាក់អនុវត្តន៏ច្បាប់ និងសកម្មភាពប្រយុទ្ធប្រឆាំងនឹងការកាប់ឈើខុសច្បាប់ និងការរំលោភយកដី គឺចាំបាច់បំផុត ។

លោក ឈិត សំអាត បានអំពាវនាវឱ្យមានការសើរើពិនិត្យសម្បទានដីសេដ្ឋកិច្ចឡើងវិញ និងមានតម្លាភាព ច្រើនថែមទៀតទាក់ទងនឹងចំណូលរបស់រដ្ឋាភិបាលដែលបានមកពីព្រៃឈើ និងធនធានធម្មជាតិផ្សេងទៀត និងការប្រើប្រាស់ចំណូលទាំងនេះ ។ គោលនយោបាយ និងច្បាប់នានាទោះបីល្អយ៉ាងណាក្តី ក៏មិនមែនចប់ត្រឹមអនុមតិចេញមកនោះទេ ។ ការងារសំខាន់បំផុតគឺធានាឱ្យមានការប្រតិបត្តិតាម ការពង្រឹងអនុវត្តច្បាប់ និងដាក់ទោសទណ្ឌឱ្យបានសមស្រប ។ កត្តាគន្លឹះមួយក្នុងការគ្រប់គ្រងធនធានធម្មជាតិ គឺអាជ្ញាធរមូលដ្ឋានគួរមើលឱ្យឃើញនូវ ផលប្រយោជន៍បានពីការប្រើប្រាស់ធនធានធម្មជាតិ ។ ដើម្បីគ្រប់គ្រងធនធានប្រេងកាត និងឧស្ម័ន ឱ្យមានប្រសិទ្ធភាព ការដាក់អនុវត្តជាមុននូវ ក្របខ័ណ្ឌគណនេយ្យភាពមួយ គឺមានសារៈសំខាន់ណាស់ ។ ម្យ៉ាងទៀតក៏ត្រូវមាន តម្លាភាពលើចំណូល-ចំណាយជាប់ទាក់ទងនឹងធនធានប្រេងកាត និងឧស្ម័នធម្មជាតិដែរ ។

## កំណត់សំគាល់

១. ពេលនេះតួលេខអាចចុះទាបបន្តិចវិញដោយសារមានឧស្ម័ននាំចូល ប៉ុន្តែការពឹងផ្អែកលើអុស-ធ្យូងនៅតែមានកំរិតខ្ពស់ ដោយសារការឡើងថ្លៃឧស្ម័ន ។

## ឯកសារយោង

សូមមើលឯកសារយោងក្នុងអត្ថបទភាសាអង់គ្លេស

# ការទាញប្រយោជន៍ឱ្យបានប្រសើរបំផុតពីធនធានមនុស្សប្រទេសកម្ពុជា

*លោក ច័ន្ទ សុផល ធ្វើការសង្ខេបពីបទបង្ហាញក្នុងវគ្គទី៣ នៃសន្និសីទចក្ខុវិស័យឆ្នាំ២០០៨ និងប្រមើលមើលពីការរីកចំរើននៃជំនាញ ផ្គូផ្គងទៅនឹងតំរូវការទីផ្សារ*

ប្រធានបទវគ្គទីបីនៃសន្និសីទចក្ខុវិស័យ គឺធនធានមនុស្សប្រទេសកម្ពុជា ។ ផ្នែកនេះដឹកនាំ និងសំរបសំរួលដោយ លោកជំទាវបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ឯកឧត្ដម ពេជ សោភ័ន រដ្ឋលេខាធិការក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានធ្វើបទបង្ហាញពី "ការឆ្លើយតបនឹងតំរូវការទីផ្សារពលកម្មដែលប្រែប្រួលចុះឡើង" ។ បន្ទាប់មក លោកបណ្ឌិត ជា សាន ច័ន្ទថន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ ធ្វើការបកស្រាយពី "ការអប់រំមានគុណភាពខ្ពស់ និងអនាគតប្រទេសកម្ពុជា" ។ លោកស្រី Sandra D'Amico នាយកគ្រប់គ្រងក្រុមហ៊ុន H.R. Inc. បានធ្វើបទបង្ហាញពី "តើវិស័យឯកជនត្រូវការអ្វីខ្លះ" ។ នៅចុងបញ្ចប់វគ្គនេះ លោក ច័ន្ទ សុផល អ្នកគ្រប់គ្រងស្រាវជ្រាវជាន់ខ្ពស់ វិបសអ-CDRI បានធ្វើបទបង្ហាញពី "បញ្ហាប្រឈមខាងគោលនយោបាយទីផ្សារពលកម្ម" ។ សេចក្ដីសង្ខេបខាងក្រោមនេះបង្ហាញពីចំណុចនានាដែលបានលើកមកពិភាក្សា ។

## សារសំខាន់ៗ

ប្រទេសកម្ពុជា ប្រឈមនឹងបញ្ហាធំៗជាច្រើនទាក់ទងនឹងការអភិវឌ្ឍមូលធនមនុស្ស និងកំលាំងពលកម្មមានជំនាញ ។ បញ្ហាមានជាអាទិ ផលិតភាពទាប និងយុវជនអត់ការងារធ្វើដ៏ច្រើនរួមទាំងក្នុងចំណោមនិស្សិតបញ្ចប់ឧត្ដមសិក្សាទៀតផង ។ ប្រជាពលរដ្ឋភាគច្រើនរស់នៅជនបទដាច់ស្រយាល និងក្រីក្រ ហើយពលករនៅជនបទភាគច្រើនត្រូវការតែជំនាញមូលដ្ឋានប៉ុណ្ណោះ ប៉ុន្តែនៅតាមទីក្រុងមានតំរូវការជំនាញខ្ពស់ជាងនេះមួយចំនួនតូច ។ វាគ្មិនជាច្រើនបានសង្កត់ធ្ងន់ពីតំរូវការឈានទៅកាន់សេដ្ឋកិច្ចផ្អែកលើជំនាញ ជាជាងសេដ្ឋកិច្ចផ្អែកលើធនធាន ។

ការផ្គូផ្គងជំនាញទៅនឹងតំរូវការ មានការជឿនលឿនខ្លះៗហើយ ជាពិសេសតាមរយៈការកសាងក្របខ័ណ្ឌអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងបច្ចេកទេសជាតិ (Technical and Vocational Education and Training: TVET) និងការអនុមតិប្រើស្តង់ដារជំនាញផ្អែកលើសមត្ថភាព ។ ការផ្គូផ្គងការងារដែលធ្វើឡើងតាមរយៈមជ្ឈមណ្ឌលការងារ និងទីភ្នាក់ងារជាតិរកការងារអោយធ្វើ ក៏ជាផ្នែកមួយនៃវិធីសាស្ត្រនេះដែរ ។ ប៉ុន្តែការបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលផ្ដល់ដោយរដ្ឋ វិស័យឯកជន និងនិយោជកនៅមានកំរិត ហើយក៏មិនសូវស្របតាមតំរូវការរបស់និយោជកទេ ។ តួយ៉ាងជាក់ស្តែង សិស្សភាគច្រើនរៀនវិទ្យាសាស្ត្រសង្គម មិនមែនរៀនបច្ចេកវិទ្យា វិស្វកម្មទេ ។

ចំនួនអ្នកផ្គត់ផ្គង់សេវាអប់រំកំរិតឧត្ដមសិក្សា បានកើនឡើងច្រើនណាស់ ប៉ុន្តែគុណភាពអប់រំនៅតែជាបញ្ហាគួរបារម្ភដដែល ។ ជំហានសំខាន់ៗមានដូចជា ការកំណត់កំរិតសិក្សាត្រូវមានដើម្បីបានចូលរៀន ការបង្កើតទីភ្នាក់ងារផ្ដល់ការទទួលស្គាល់ និងការដាក់អនុវត្តឆ្នាំទីមួយស្តង់ដារនៅឧត្ដមសិក្សាដើម្បីផ្ដល់ជំនាញមូលដ្ឋាន ។ និស្សិតភាគច្រើនដែលបញ្ចប់ឧត្ដមសិក្សានៅតែគ្មានជំនាញគ្រប់គ្រាន់សមស្របទេ ដូច្នេះក៏ផុសឡើងនូវកង្វះខាតអ្នកមានសមត្ថភាព និងតំរូវការវគ្គសិក្សាខាងផ្នែកការងារសង្គមកិច្ច ។ ម្យ៉ាងទៀត ក៏មានកង្វះខាតជំនាញទូទៅមួយចំនួនដែលនិយោជកកំពុងត្រូវការដូចជា ជំនាញវិភាគពិចារណា ជំនាញសរសេរ និងជំនាញដឹកនាំ ជាដើម ។

និយោជកលំបាកច្រើនណាស់ក្នុងការជ្រើសរើសបុគ្គលិកដែល សមស្រប ហើយបញ្ជាក់ពីការខកចិត្តចំពោះកំរិតជំនាញទាប សមត្ថភាពតិចតួច ការទាមទារមិនប្រាកដនិយម និងកង្វះខាតជាទូទៅនូវលក្ខណៈត្រៀមខ្លួនអាចធ្វើការបានរបស់និស្សិតបញ្ចប់ឧត្ដមសិក្សា ។ បច្ចុប្បន្ន ការបញ្ជាក់ទទួលស្គាល់នូវជំនាញ/បទពិសោធន៍ ជាចំណុចខ្វះខាតមួយធំណាស់ ហើយពួកយុវជនក៏ត្រូវយល់ដឹងអោយបានច្បាស់ថែមទៀតពីទីផ្សារពលកម្ម និងជំនាញត្រូវមានដើម្បីទទួលបានការងារ និងរក្សាការងារនោះបាន ។ កង្វះអ្នកមានជំនាញធ្វើអោយមានកំណើនប្រាក់បៀវត្សរ៍ និងការផ្លាស់ប្តូរបុគ្គលិកញឹកញាប់ ដោយពួកគេស្វែងរកប្រាក់បៀវត្សរ៍ខ្ពស់ និងលក្ខខ័ណ្ឌការងារល្អថែមទៀត ។

ចំពោះបញ្ហាទីផ្សារពលកម្មជាទូទៅ និងយុវជនអត់ការងារធ្វើ គេបានលើកឡើងនូវវិធីសាស្ត្រពីរៈ ១-បង្កើនតំរូវការជំនាញមូលដ្ឋានដោយកែលំអសន្តិសុខស្បៀង និងបំពេញតំរូវការចាំបាច់នានារបស់អ្នកក្រីក្រនៅជនបទ តាមរយៈការដកយកដីកសិកម្ម (រួមទាំងដីនៅក្នុងសម្បទានដីសេដ្ឋកិច្ចផង) មកបំរើសកម្មភាពបង្កបង្កើនផលវិញ និង ២-កាត់បន្ថយបន្ទុកចំណាយពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកទៅបរទេស និងបង្កើតយន្តការការពារខាងសង្គមកិច្ច ដើម្បីទទួលបានផលចំណេញច្រើនបំផុតពីការងារទាំងនោះ ។

## បទបង្ហាញ និងការពិភាក្សា

នៅពេលអត្រាកំណើនប្រជាជនសរុប បានថយចុះមកត្រឹម ១,៩៦%/ឆ្នាំ ក្នុងប៉ុន្មានឆ្នាំនេះ ក្រុមយុវជនក្នុងអាយុពី ១៥-២៤ឆ្នាំ បានកើនឡើងតាមអត្រា ៣,២% ។ ប្រជាជនប្រហែល ២៥០.០០០នាក់ បានចូលបន្ថែមក្នុងកំលាំងពលកម្មជារៀងរាល់ឆ្នាំ ។ នៅឆ្នាំ២០០៤ អត្រាយុវជនអត់ការងារធ្វើ (អ្នកអត់ធ្វើការ តែអាចធ្វើការងារបាន) នៅភ្នំពេញ គឺ ២០,១% ដែលជាចំនួនមួយគួរអោយបារម្ភ ។ អត្រាអត់ការងារធ្វើ ក្នុងក្រុមយុវជនអាយុ ១៥-១៩ឆ្នាំ មាន ២៧,៨% និងក្នុងក្រុមអាយុ២០-២៤ឆ្នាំ មាន ១៦,៦% ។ កំណើនយុវជនដែលត្រូវការឱកាសការងារ និងជំនាញសមស្រប គឺជាបញ្ហាត្រូវប្រឈមតទៅទៀត ។

អត្រាយុវជនអត់ការងារធ្វើកំរិតខ្ពស់បែបនេះ អាចបណ្ដាលមកពីឱកាសការងារមិនគ្រប់គ្រាន់ ធៀបនឹងកំណើនកំលាំងពលកម្ម ។ ឱកាសការងារមានកំរិតកំណត់ ជាពិសេសក្នុងវិស័យកសិកម្ម ។ ប៉ុន្តែនៅចំពោះមុខតំរូវការ

---

* លោក ច័ន្ទ សុផល គឺជាអ្នកគ្រប់គ្រងស្រាវជ្រាវជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិអន្តរជាតិ នៃវិទ្យាស្ថាន CDRI

ការងារដ៏ច្រើនដូចសព្វថ្ងៃ អ្នកវិនិយោគ និងអ្នកជំនួញ នៅតែត្អូញត្អែរពីកង្វះខាតជំនាញដែលពួកគេត្រូវការ ។ សេវាកម្មបណ្តុះបណ្តាល និងអប់រំ នៅទន់ខ្សោយនៅឡើយ ហើយយុវជនជាច្រើនមិនអាចទៅចូលរួមក្នុងការបណ្តុះបណ្តាលបានទេ ព្រោះមានតំរូវការចំបងក្នុងរយៈពេលខ្លីដើម្បីរកបានស្បៀងអាហារ និងវត្ថុចាំបាច់ផ្សេងៗទៀត ។

ការបង្កើតការងារមិនគ្រប់គ្រាន់ អាចបណ្តាលមកពីបរិយាកាសវិនិយោគទុនមិនអំណោយផលកាលពីមុន ទោះបីនាពេលសព្វថ្ងៃមានការប្រឹងប្រែងជាច្រើនដើម្បីកែលំអវាក្តី ។ នៅជនបទមានកង្វះខាតការងារយ៉ាងធ្ងន់ធ្ងរ ដែលនាំអោយប្រជាពលរដ្ឋជាច្រើនធ្វើចំណាកស្រុកទៅទីក្រុង រឺប្រទេសផ្សេងទៀត ជាពិសេសប្រទេសថៃ ។ កម្ពុជាមានគោលនយោបាយចំរូងចំរាសមួយសំដៅរក្សាទុកព្រៃឈើដល់ ៦០% នៃផ្ទៃដីក្នុងប្រទេស ។ សំនួរមួយបានចោទឡើងថា តើរឿងនេះប្រាកដនិយមដែររឺទេ នៅពេលប្រជាជនជាច្រើននៅជនបទត្រូវការចិញ្ចឹមជីវិត ហើយព្រៃឈើជាច្រើនត្រូវខូចខាតរួចទៅហើយនោះ ។ វាមានការដោះដូរគ្នារវាងដីព្រៃឈើ និងដីកសិកម្ម ។ នៅក្រោមគោលនយោបាយរក្សាទុកផ្ទៃដីព្រៃ ៦០% ដីជាច្រើនដែលបានបាត់បង់ព្រៃឈើទៅហើយ នៅតែមានស្ថានភាពមិនច្បាស់លាស់ ហើយដីទាំងនោះមិនបានប្រើប្រាស់អោយមានផលិតភាពទេ ដែលនាំអោយខាតបង់ដល់សក្តានុពលផលិតកម្ម និងឱកាសការងារ ។

ស្របជាមួយគ្នានេះ ការទាញយកផលចំណេញពីចំណាកស្រុកពលករឆ្លងដែន បានជួបឧបសគ្គធ្ងន់ធ្ងរ ។ ចំណាយដើម្បីទៅធ្វើការដោយស្របច្បាប់នៅថៃ វាខ្ពស់ហួសពេក ដល់ទៅ ៦០០-៧០០ដុល្លារក្នុងមនុស្សម្នាក់ ហើយត្រូវរង់ចាំពី ៣-៦ខែ រីឯការធ្វើចំណាកស្រុកមិនស្របច្បាប់អស់ចំណាយតែ ១០០ដុល្លារ និងត្រូវរង់ចាំតែ ៣ថ្ងៃ ។ ពលករប្រមាណ ៦០០០នាក់បានជ្រើសយកមធ្យោបាយស្របច្បាប់ រីឯពលករជាង ១៨០.០០០នាក់ទៀតបានប្រើមធ្យោបាយមិនស្របច្បាប់ ។ ប៉ុន្តែការធ្វើចំណាកស្រុកមិនស្របច្បាប់មានហានិភ័យ និងទទួលបានបៀវត្សរ៍ទាប ។ នៅឆ្នាំ២០០៥ ប្រាក់ផ្ញើមកអោយគ្រួសារមានប្រហែល ២០០លានដុល្លារ/ឆ្នាំ ។ ប្រាក់នេះអាចឡើងដល់ ៥០០លានដុល្លារ/ឆ្នាំ ប្រសិនបើការធ្វើចំណាកស្រុកទៅថៃអាចគ្រប់គ្រងបានប្រសើរជាងមុន (វៀតណាមទទួលបាន ៤ពាន់លានដុល្លារ ឯថៃទទួលបាន ១,៥ពាន់លានដុល្លារ) ។

ការងារនៅក្រៅប្រទេសទំនងនឹងកើនឡើងបន្តទៀត ។ ចាប់ពីឆ្នាំ១៩៩៨ មក កម្មករ ១០.៩៣២នាក់ ត្រូវបានបញ្ជូនដោយស្របច្បាប់ទៅប្រទេសម៉ាឡេស៊ី ៣៩៨៤នាក់ទៅកូរ៉េខាងត្បូង និង ៦១១៤នាក់ទៅថៃ។ ថៃបានព្យាករណ៍ថា ថៃនឹងមានឱនភាពពលកម្ម ៦លាននាក់ ក្នុងមួយរយៈពេលខ្លី ដូច្នេះតំរូវការពលករនៅថៃ រំពឹងថានឹងកើនឡើងថែមទៀត ។ ប្រជាពលរដ្ឋកម្ពុជាក៏មានឱកាសកាន់តែច្រើនដើម្បីទៅធ្វើការនៅម៉ាឡេស៊ី កូរ៉េខាងត្បូង ជប៉ុន និង សិង្ហបុរី ផងដែរ។ តំរូវការនៅពេលនេះគឺ ការកាត់បន្ថយបន្ទុកចំណាយលើចំណាកស្រុក ជាពិសេសទៅកាន់ប្រទេសថៃ ។ ក្នុងនេះត្រូវកាត់បន្ថយថ្លៃលិខិតឆ្លងដែនមកត្រឹម ៤០ដុល្លារ រឺតិចជាង និងរយៈពេលធ្វើលិខិតឆ្លងដែនមកត្រឹម ១០ថ្ងៃ រឺតិចជាង ។ រដ្ឋាភិបាលថៃ និងកម្ពុជា គួរកាត់បន្ថយចំណាយសរុប ក្នុងការបញ្ជូនពលករទៅធ្វើការនៅថៃពី ៧០០ដុល្លារ មកត្រឹម ៣០០ដុល្លារវិញ ។ ម្យ៉ាងទៀត ត្រូវមានការយកចិត្តទុកដាក់ជាពិសេសចំពោះនារីចំណាកស្រុក ដែលងាយទទួលរងគ្រោះដោយអំពើហិង្សា និងការជួញដូរ ។

កំណែលំអការអប់រំ និងកិរិតជំនាញ ទាមទារនូវតុល្យភាពរវាងការផ្គត់ផ្គង់ និងតំរូវការ ។ នៅឆ្នាំ២០០៧ ថវិកាអប់រំមានចំនួន ១៣៦លានដុល្លារ ។ ប្រជាជនតែងដោះស្រាយសន្តិសុខស្បៀង និងតំរូវការមូលដ្ឋាន អោយបានសិនទើបស្វែងរកការអប់រំ ។ ដូច្នេះត្រូវមានគោលនយោបាយរឹងមាំដើម្បីបង្កើនប្រាក់ចំណូលអ្នកក្រ ដោយកែលំអផលិតភាពកសិកម្ម និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ការងារនេះតំរូវអោយបង្កើនថវិកាជាតិ សំរាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកសិកម្ម ។ នៅឆ្នាំ២០០៧ ថវិកាបែងចែកអោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតែ ១៥លានដុល្លារ រីឯក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៧លានដុល្លារ ប៉ុណ្ណោះ ។ ប្រាក់ចំណូលអាចកើនឡើងក្នុងរយៈពេលពី ១ ទៅ ២ឆ្នាំ តាមរយៈកំណែលំអផលិតភាពកសិកម្ម រឺការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ការបង្កើតការងារប្រកបដោយផលិតភាព ទាមទារការកែលំអបរិយាកាសវិនិយោគ (ក្នុងនេះរដ្ឋាភិបាល និងធនាគារពិភពលោក កំពុងធ្វើការងារដើម្បីកែលំអការសំរបសំរួលពាណិជ្ជកម្ម) ការកាត់បន្ថយថ្លៃថាមពល និងដឹកជញ្ជូន និងការគិតគូរឡើងវិញពីគោលនយោបាយដីធ្លី និងព្រៃឈើ ។ ការកំណត់ព្រំដែនច្បាស់លាស់នៃដីរដ្ឋ និងព្រៃឈើ ពិតជាចាំបាច់ខ្លាំងណាស់ ។ តាមគោលការណ៍បច្ចេកទេស ផ្ទៃដីកម្ពុជា ៨០% ជាដីរបស់រដ្ឋ ។ តើទំហំនេះមិនធំពេកទេរឺ? ប័ណ្ណកម្មសិទ្ធិ និងការកាន់កាប់ដី មិនអាចធ្វើលើដីថ្មីបានទេ សំរាប់ប្រជាជនធម្មតា នៅពេលដែលរដ្ឋបាលព្រៃឈើនៅតែកាន់កាប់លើ ៦០% នៃផ្ទៃដីប្រទេសកម្ពុជា ។ សម្បទានដីសេដ្ឋកិច្ចដែលមិនដំណើរការ ក៏គួរតែប្តូរជាសម្បទានដីសង្គមកិច្ចវិញដែរ ។

សាកលវិទ្យាល័យនានា មានមុខវិជ្ជាជាច្រើនទាក់ទងនឹងការគ្រប់គ្រងគណនេយ្យ និងទីផ្សារ ។ ផ្ទុយទៅវិញ ជំនាញខាងការសាងសង់ផ្លូវ-ស្ពានការសាងសង់អាគារ ធារាសាស្ត្រ ការជួសជុលអគ្គិសនី បំពង់ទឹក និងមេកានិកដែលកំពុងមានតំរូវការយ៉ាងខ្លាំង គឺមានសិក្សាតិចតួចណាស់នៅតាមសាកលវិទ្យាល័យ ។

ប្រជាជនវ័យក្មេងជាបញ្ហាប្រឈមផង និងជាឱកាសល្អផង ។ ដើម្បីធានាអោយបាននូវកំណើនខ្ពស់ក្នុងរយៈពេលមធ្យម និងវែង ត្រូវតែធ្វើការផ្លាស់ប្តូរពីកំណើនផ្អែកលើធនធាន ទៅជាកំណើនផ្អែកលើជំនាញវិញ ហើយក្នុងនេះ ត្រូវមានការកែលំអគុណភាពកំលាំងពលកម្ម ។ ដើម្បីសំរេចគោលដៅនេះ ត្រូវមានតុល្យភាពរវាង វិនិយោគលើការអប់រំរយៈពេលវែង និងវិនិយោគដើម្បីបង្កើនប្រាក់ចំណូល/ជំនាញរយៈពេលខ្លី ។ វិនិយោគលើការអប់រំនឹងអាចផ្តល់ផលចំណេញក្នុងរយៈពេលវែង លុះត្រាតែតំរូវការរយៈពេលខ្លីអាចដោះស្រាយបាន ។ ដូច្នេះការពង្រឹងសន្តិសុខស្បៀង និងការបង្កើនប្រាក់ចំណូល តាមរយៈការកែលំអផលិតភាពដីនិងកសិកម្ម និងការបង្កើនការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស មានសារៈសំខាន់ខ្លាំងណាស់ ។ ដូចនេះគួរផ្តល់ធនធានច្រើនថែមទៀតដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ក្រុមហ៊ុន H.R. Inc. កម្ពុជា បានគូសបញ្ជាក់ថា និយោជកមានការលំបាក

ក្នុងការជ្រើសរើសធនធានមនុស្សមានសមត្ថភាពល្អ ។ អ្នកដាក់ពាក្យក្មេងៗជាច្រើននាក់គ្មានជំនាញទេ ហើយសព្វថ្ងៃមានកង្វះខាតអ្នកគ្រប់គ្រងសញ្ជាតិខ្មែរ និងអ្នកមានជំនាញគ្រប់គ្រង និងជំនាញឯកទេសផ្សេងៗទៀត ។ ការរក្សាទុកបុគ្គលិកក៏លំបាកដែរ រីឯការផ្តល់ប្រាក់បៀវត្សរ៍ខ្ពស់វាមិនមែនដោយសារជំនាញខ្ពស់ទេ ប៉ុន្តែដោយសារគ្មានជំរើសផ្សេង ។ ការជ្រើសរើសជួបការលំបាក ពីព្រោះសញ្ញាប័ត្រមិនឆ្លុះបញ្ចាំងពីជំនាញពិតប្រាកដ ។ គ្រប់ៗគ្នាចង់ធ្វើជាអ្នកគ្រប់គ្រង ។ តែបច្ចុប្បន្នខ្វះខាតខ្លាំងណាស់នូវជំនាញគិតគូរវិភាគច្នៃប្រឌិត ។ ការធ្វើអង្កេតធំមួយពីតំរូវការរបស់និយោជក និងជំនាញរបស់យុវជន រកឃើញថា យុវជន ៧៦% ពុំមានជំនាញត្រឹមត្រូវ ហើយមានតែនិយោជក ១២% ប៉ុណ្ណោះដែលពេញចិត្តនឹងសមត្ថភាពនិយោជិកខ្លួន ។

និស្សិតបញ្ចប់ការសិក្សាម្នាក់ៗចំណាយពេលជាមធ្យម ៩ខែ ដើម្បីរកបានការងារធ្វើ ។ប៉ុន្តែសព្វថ្ងៃគេពិបាករកបានអ្នកធ្វើការដែលសកម្មគ្រប់គ្រង ។ សំរាប់ការងារជាមូលដ្ឋាន ចំណុចខ្វះខាត គឺអកប្បកិរិយាការងារល្អ ជំនាញបច្ចេកទេស ភាសាបរទេស និងសមត្ថភាពធ្វើការសំរេចចិត្ត ។ គេលំបាកខ្លាំងណាស់នឹងរកបានពលករមានជំនាញឯកទេស រឺអ្នកមានជំនាញវិភាគខ្ពស់ ។ នៅកំរិតអាជីព គេពិបាករកបានអ្នកមានជំនាញវិភាគ/សំរេចចិត្ត និងមានបទពិសោធន៏ពាក់ព័ន្ធនឹងការងារ ។ ការរំពឹងទុកអំពីបៀវត្សរ៍ ជាបញ្ហាធំមួយដែលនាំអោយបុគ្គលិកចេញទៅធ្វើការងារផ្សេង ។

ក្រុមហ៊ុន H.R. Inc. សុំអោយបង្កើនការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស ពង្រឹងការអប់រំកំរិតឧត្តមសិក្សា/ការបណ្តុះបណ្តាលការងា ជាបន្តព្រមទាំងមានការបញ្ជាក់ទទួលស្គាល់ និងការផ្តល់សញ្ញាប័ត្រដែលមានន័យដោយចងភ្ជាប់នឹងជំនាញ/សមត្ថភាព ។ ពួកយុវជនត្រូវស្វែងយល់ពីទីផ្សារ និងការរំពឹងទុករបស់ទីផ្សារ ។ និយោជកត្រូវចំណាយពេលអោយច្រើនដើម្បីស្វែងរកជំនាញដែលខ្លួនត្រូវការ ហើយសាកលវិទ្យាល័យត្រូវផ្តល់ជំនាញដែលសមស្រប និងផ្សារភ្ជាប់យុវជនទៅនឹងការងារ ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រ បានបង្ហាញភស្តុតាងថា និស្សិតភាគច្រើន មិនចូលចិត្តអានសៀវភៅទេ ហើយចង់អោយសាស្ត្រាចារ្យបង្កើតមេរៀនសង្ខេបអោយពួកគេ ។ ការកែសំរួលស្តង់ដារមិនអាចជួយអ្វីច្រើនទេ ។ ការអានគឺជាកត្តាគន្លឹះនាំទៅរកជោគជ័យ ការសរសេរបានល្អ និងចំណេះដឹងប្រសើរ ។

បច្ចុប្បន្នមានកង្វះខាតការបោះពុម្ពផ្សាយជាភាសាខ្មែរ ទាំងរឿងប្រលោមលោក និងសៀវភៅសិក្សា ។ ដូច្នេះត្រូវប្រឹងប្រែងបោះពុម្ពផ្សាយអោយបានច្រើនថែមទៀត ។ វត្តមានប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ក៏បានបន្ថយបង្អាក់ការអានសៀវភៅដែរ ។

និស្សិតជាច្រើនចូលរៀន ២-៣ មហាវិទ្យាល័យក្នុងពេលតែមួយ ដោយគិតថារៀនមួយវាមិនគ្រប់គ្រាន់ ។ ចំណុចនេះបង្ហាញថា ការអប់រំនៅឧត្តមសិក្សាមិនឆ្លើយតបនឹងតំរូវការទេ ។ និស្សិតដែលបានបញ្ចប់ការសិក្សាអាចមានសញ្ញាប័ត្រពីរ ប៉ុន្តែគ្មានចេះអ្វីសោះ ។ កម្មវិធីសិក្សាមានគុណភាពអន់ ហើយសាកលវិទ្យាល័យចំលង កម្មវិធីសិក្សាគ្នាទៅវិញទៅមក ។ ដូច្នេះមានការចាំបាច់ពិតៗដើម្បីគោរពតាមស្តង់ដារអន្តរជាតិ បំពេញតំរូវការក្នុងប្រទេស និងបន្សុីទីផ្សារនិស្សិតទៅនឹងទីផ្សារការងារ ។ និស្សិតភាគច្រើនចង់ធ្វើការផ្នែកគ្រប់គ្រង និងគណនេយ្យ ។ សព្វថ្ងៃគ្មានការសិក្សាអ្វីសោះពីទីផ្សារការងារ ។ តើកម្ពុជាត្រូវការអ្វី? ។ ជំនាញសំខាន់ៗជាច្រើនខ្វះខាតខ្លាំងណាស់ ដូចជា ជំនាញវិភាគ និងជំហរសកម្មគ្រប់គ្រង ដែលមិនចេះតែដើរតាមក្រោយការងាររហូតនោះទេ ។ជំនាញធ្វើរបាយការណ៏ និងសរសេរ ក៏សំខាន់ខ្លាំងដូចគ្នា ប៉ុន្តែសិស្សមិនចេះសរសេរពីព្រោះពួកគេមិនចូលចិត្តអាន ។ ម្យ៉ាងទៀតក៏គ្មានការសិក្សាពីការងារសង្គម និងវិស័យផ្សេងទៀតដែលកំពុងមានតំរូវការដែរ ។ ការសិក្សាខាងយ៉េនឌ័រ និងភាពជាអ្នកដឹកនាំ ក៏នៅខ្វះខាតដែរ ។

នាបច្ចុប្បន្ន មានសាកលវិទ្យាល័យ និងវិទ្យាស្ថានរដ្ឋ និងឯកជន ចំនួន ៦០ កំពុងដំណើរការ ។ គុណភាពអប់រំកំរិតឧត្តមសិក្សា ជាការព្រួយបារម្ភធំជាងគេ ។គណៈកម្មាធិការផ្តល់ការទទួលស្គាល់របស់កម្ពុជាបានតំរូវអោយមានការទាមទារកំរិតចូលរៀនដើម្បីអោយមានច្បាប់ទំលាប់ និងភាពស៊ីចង្វាក់គ្នាក្នុងវិស័យនេះ។

សាកលវិទ្យាល័យរដ្ឋ បានទទួលយកសិស្សពូកែ ហើយសាកលវិទ្យាល័យឯកជនទទួលយកសិស្សដែលនៅសល់ពីនោះ ។ កន្លងមកមានការខិតខំមួយចំនួនដើម្បីដោះស្រាយបញ្ហាគុណភាពនិស្សិតសុំចូលរៀន ដូចជាតាមរយៈការប្រលងប្រជែងចូលរៀនជាដើម ។ ម្យ៉ាងទៀត សៀវភៅមេរៀនសុទ្ធជាភាសាអង់គ្លេស ដូច្នេះសិស្សត្រូវតែរៀនភាសាបរទេស ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពិពណ៌នាពីភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការបន្សុីមុខជំនាញនៃកំលាំងពលកម្មកម្ពុជាទៅនឹងឱកាសការងារ ព្រមទាំងបង្កើតបរិយាកាសមួយដែលក្នុងនោះ ដៃគូទាំងអស់បានយល់ដឹង ទទួលយក និងអនុវត្តតួនាទីរបស់ខ្លួន ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជួយសម្របសម្រួលការប្រឹងប្រែងទូទាំងប្រទេស ដើម្បីបន្សុីមុខជំនាញទៅនឹងតំរូវការ ហើយជំរុញអោយដៃគូនានា ស្វែងរកដំណោះស្រាយអាចធ្វើបាន ដើម្បីអភិវឌ្ឍន៏ជំនាញ និងបង្កើតដៃគូថ្មីៗ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអភិវឌ្ឍការបណ្តុះបណ្តាលជំនាញផ្អែកលើសហគមន៏ (ប្រព័ន្ធបណ្តុះបណ្តាលជំនាញប្រើប័ណ្ណចុះថ្លៃ) ដែលក្នុងនោះអ្នកភូមិជាង ៦០.០០០នាក់ បានអភិវឌ្ឍជំនាញរបស់ខ្លួនដើម្បីរកចំណូលអោយបានកាន់តែច្រើននៅតំបន់ជនបទ ។ "រកចំណូលផង និងរៀនសូត្រផង" គឺជាមូលដ្ឋាននៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ/បច្ចេកទេសនៅទីក្រុង និងជាការឆ្លើយតបរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅនឹងបំរែបំរួលទីផ្សារពលកម្មនៅក្នុងសេដ្ឋកិច្ចផ្លូវការ ។

ភាពអត់ការធ្វើក្នុងចំណោមសិស្ស-និស្សិត ដែលបញ្ចប់មធ្យមសិក្សា និងឧត្តមសិក្សា គឺជាបញ្ហាគួរបារម្ភមួយទៀត ។ ប្រសិនបើអ្នកបញ្ចប់ការសិក្សាទាំងនេះមានជំនាញទីផ្សារ ក្រុមហ៊ុននឹងអាចជួលពួកគេ ។ សិស្សបញ្ចប់មធ្យមសិក្សា មាន ៩៣.៩០០នាក់ នៅឆ្នាំ២០០៧/០៨ ហើយចំនួននេះនឹងកើនដល់ ១៩០.០៥០នាក់ នៅឆ្នាំ២០១៤/១៥ ។

បច្ចុប្បន្នកម្ពុជាដល់ពេលត្រូវដោះស្រាយតំរូវការ អ្នកមានសញ្ញាប័ត្រដែលស្របតាមស្តង់ដារពាណិជ្ជកម្ម ។ មានប្រព័ន្ធល្អមួយគ្មានប្រយោជន៏អ្វីទេ បើសិនគ្មានអ្នកណាដឹងថាមានប្រព័ន្ធបែបនោះ ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានបំណងចាប់ផ្តើមធ្វើយុទ្ធនាការឃោសនាក្នុងសង្គមមួយ

(តទៅទំព័រ ២០)

# ប្រទេសកម្ពុជា ឆ្នាំ២០០៨ និងទៅអនាគតៈ ភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈ

*លោកស្រី អេង នេត្រា បានសង្ខេបពីបញ្ហាពិភាក្សាសំខាន់ៗក្នុងវគ្គទី៤នៃសន្និសីទចក្ខុវិស័យ និងលើកឡើងពីក្របខ័ណ្ឌបច្ចុប្បន្នសំរាប់ភាពជាដៃគូរវាងរដ្ឋាភិបាល-វិស័យឯកជន និងតំរូវការយន្តការឯករាជ្យមួយសំរាប់លើកកំពស់ ការសំរបសំរួល និងសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងខាងផ្នែកអាជីវកម្ម ។**

ការពិភាក្សាបានចាប់ផ្តើមពី ការពិនិត្យលើទស្សនៈរួមនៃគោលនយោបាយ និងគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល ដើម្បីសំរេចបាននូវការអភិវឌ្ឍវិស័យឯកជន តាមរយៈបទបង្ហាញរបស់ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ លោក Bretton G. Sciaroni មកពីក្លឹបអាជីវកម្មអន្តរជាតិនៃប្រទេសកម្ពុជា បានពិភាក្សាពីយន្តការសំខាន់ៗ និងមានជោគជ័យធ្វើឱ្យរដ្ឋាភិបាល និងវិស័យឯកជនជួបប្រជុំផ្លាស់ប្តូរយោបល់ និងស្វែងរកដំណោះស្រាយសំរាប់ពេលខាងមុខ ហើយលោកក៏បានផ្តល់មតិមួយចំនួនសំរាប់យន្តការនាពេលអនាគតដែរ ។ បទបង្ហាញទី៣ ដោយលោកស្រី អេង នេត្រា នៃវិទ្យាស្ថាន CDRI លើកឡើងពីបញ្ហាប្រឈមខាងអភិបាលកិច្ចសំខាន់ៗ និងឥទ្ធិពលនៃបញ្ហាទាំងនេះលើការអភិវឌ្ឍវិស័យឯកជន ព្រមទាំងវិធានការសំរាប់ដោះស្រាយ ។ ជាចុងក្រោយ លោក Tim Duffy នាយកក្រុមហ៊ុន Oxiana បានផ្តល់ឧទាហរណ៍អំពីរបៀបដែលវិស័យឯកជនធ្វើការចូលរួមចំណែក និងជះឥទ្ធិពលទៅលើសហគមន៍ និងការអភិវឌ្ឍក្នុងប្រទេសកម្ពុជា ។ ខាងក្រោមនេះជាចំណុចសំខាន់ៗនៃបទបង្ហាញទាំងបួន ។

## ភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងប្រទេសកម្ពុជានាពេលអនាគត

*ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម*

រដ្ឋាភិបាលកម្ពុជា គាំទ្រយ៉ាងខ្លាំងចំពោះការអភិវឌ្ឍវិស័យឯកជន ដោយបានដាក់អនុវត្តយន្តការមួយចំនួន ដើម្បីជួយសំរួលដល់វិស័យនេះ ។ ទីមួយ សម្តេចនាយករដ្ឋមន្ត្រី ជួបសំណេះសំណាលពីរដងក្នុងមួយឆ្នាំជាមួយអ្នកវិនិយោគទុនក្នុងស្រុក និងក្រៅស្រុក ក្នុងវេទិការដ្ឋាភិបាលនិងវិស័យឯកជន ដើម្បីដោះស្រាយបញ្ហាសំខាន់ៗមួយចំនួនទាក់ទងនឹង ផលប្រយោជន៍វិស័យឯកជន ។ យន្តការនេះបានក្លាយជាក្រឹត្យក្រមតាំងពីឆ្នាំ ២០០០ មកម្ល៉េះ ។ បន្ថែមពីលើវេទិកាខាងលើ មានក្រុមការងាររដ្ឋាភិបាល និងវិស័យឯកជនចំនួន ៨ក្រុម ជួបប្រជុំគ្នាជារៀងរាល់ខែដើម្បីដោះស្រាយបញ្ហាបន្ទាន់នានា ។ ក្រុមការងារស្រង់យកបញ្ហាសំខាន់ៗជាងគេ ដាក់ជូនសម្តេចនាយករដ្ឋមន្ត្រីពិនិត្យក្នុងអំឡុងពេលវេទិកា ។

ទីពីរ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជនមួយ និងអនុគណៈកម្មាធិការបីទៀត សំរាប់ការងារខាង ១-បរិយាកាសវិនិយោគនិងការចូលរួមរបស់វិស័យឯកជនក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ២-ការអភិវឌ្ឍពាណិជ្ជកម្មនិងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម និង ៣-សហគ្រាសធុនតូចនិងមធ្យម ។

ទីបី ប្រទេសកម្ពុជាបានអនុម័តយករបបពាណិជ្ជកម្មសេរីដើម្បីជំរុញវិនិយោគផ្ទាល់ពីបរទេស (FDI) និងជួយគាំទ្រ ក្រុមហ៊ុនបរទេសក្នុងការបង្កើតអាជីវកម្ម ។ របបនេះអនុញ្ញាតអោយក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុកដែលអាចជាសហគ្រាសចំរុះ រឺក៏ក្រុមហ៊ុនបរទេស ១០០% ធ្វើការនាំចេញនាំចូល ។ រដ្ឋាភិបាលមិនត្រួតពិនិត្យលើថ្លៃទំនិញទេ ហើយក៏គ្មានគោលការណ៍បែងចែកអ្វីដែររវាងសហគ្រាសរដ្ឋ និងក្រុមហ៊ុនឯកជន ។ រដ្ឋាភិបាលមិនអនុញ្ញាតអោយបរទេសមានកម្មសិទ្ធិដីធ្លីទេ ប៉ុន្តែអាចមានសិទ្ធិជួលរហូតដល់ ៩៩ឆ្នាំ ។

ទីបួន រដ្ឋាភិបាលបានអនុម័តវិធីសាស្ត្រធំទូលាយទូទាំងវិស័យសំរាប់ពាណិជ្ជកម្ម ដើម្បីសំរួលដល់កិច្ចប្រឹងប្រែង និងការប្រើប្រាស់ធនធានរបស់រដ្ឋាភិបាល តួអង្គក្នុងស្រុក និងដៃគូអភិវឌ្ឍន៍ នៅក្នុងយុទ្ធសាស្ត្រតែមួយនិងរួមគ្នា សំដៅអភិវឌ្ឍពាណិជ្ជកម្មកម្ពុជា ។ ខឿនទាំងបីនៃវិធីសាស្ត្រនេះគឺ កំណែទំរង់និងបញ្ហាជាប់ពាក់ព័ន្ធ ការអភិវឌ្ឍផលិតផលនិងសេវាកម្ម និងការកសាងសមត្ថភាព ។ ខឿនទីមួយៗមានក្រុមរចនារៀបចំមួយ មានសមាសភាពចំរុះមកពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ។ ខឿនទាំងនេះ កំណត់ពីបែបបទដែលត្រូវជួយជំរុញផលិតផលកម្ពុជា និងទីផ្សារ បើពុំនោះទេ ប្រជាជនផលិតតែអ្វីដែលខ្លួនធ្លាប់ផលិតពីមុនមក ហើយគ្មានទីផ្សារសំរាប់ផលិតផលទាំងនោះ ។

ទីប្រាំ នៅមានបញ្ហាប្រឈមមួយចំនួនទៀតដូចជា ការធ្វើសមាហរណកម្មទីផ្សារក្នុងតំបន់ និងការកាត់បន្ថយថ្លៃដើមផលិតកម្ម។ ក្នុងនេះ តើប្រទេសកម្ពុជាអាចប្រកួតប្រជែងបែបណា ហើយតើយើងអាចធ្វើចំរុះកម្មយ៉ាងដូចម្តេចនៅពេលដែលថ្លៃដើមផលិតកម្ម ពិសេសថ្លៃហេដ្ឋារចនាសម្ព័ន្ធ (ដូចជាអគ្គិសនី) វាខ្ពស់បែបនេះ? អគ្គិសនីសំខាន់ខ្លាំងណាស់ សំរាប់ការអប់រំ និងវិស័យឯកជន ។ រដ្ឋាភិបាលបានអនុម័តលើគំរោងអគ្គិសនីមួយចំនួនសំរាប់ទូទាំងប្រទេស ដើម្បីដោះស្រាយបញ្ហា ។ ម្យ៉ាងទៀតមានការផ្តួចផ្តើមគំនិតបង្កើតតំបន់សេដ្ឋកិច្ចពិសេស ដើម្បីធ្វើចំរុះកម្ម និងបង្កើតការងារ ព្រមទាំងទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រទេសជិតខាង ។

## បរិយាកាសអំណោយផលសំរាប់វិស័យឯកជន

*Bretton G. Sciaroni ដៃគូជាន់ខ្ពស់នៃក្រុមហ៊ុន Sciaroni និងប្រធានក្លឹបអាជីវកម្មអន្តរជាតិ*

តាមរយៈកំណើនសេដ្ឋកិច្ច និងស្ថិរភាពនយោបាយនាប៉ុន្មានឆ្នាំចុងក្រោយនេះ ការវិនិយោគទុននៅកម្ពុជាមានលក្ខណៈ វិជ្ជមានជាច្រើន ដូចជា លទ្ធភាពបង្កើតក្រុមហ៊ុនកាន់កាប់ដោយបរទេស ១០០% ការមិនដាក់កំហិតលើការផ្ទេរទុន និងការសំរាលពន្ធសំរាប់ក្រុមហ៊ុនវិនិយោគ ។

ចំណុចទាក់ទាញចំបងមួយរបស់ប្រទេសកម្ពុជា គឺភាពជាដៃគូដែលបង្កើតឡើងជិតមួយទសវត្សរ៍មកហើយ រវាងមជ្ឈដ្ឋានអាជីវករ និងរដ្ឋាភិបាល តាមរយៈ

* លោកស្រី អេង នេត្រា ជាប្រធានស្រាវជ្រាវផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទំរង់សាធារណៈ ។

វេទិការដ្ឋាភិបាល និងវិស័យឯកជន ។ គេយល់ថា វេទិកានេះជាមធ្យោបាយមួយអាចជះឥទ្ធិពលដល់ច្បាប់ គោលនយោបាយ និងសុំអោយរដ្ឋាភិបាលចាត់វិធានការ ។

ចំពោះអ្នកវិនិយោគទុនជាសក្តានុពលវិញ វេទិកានេះជាស្ថាប័នមួយដ៏សំខាន់ ព្រោះបង្ហាញច្បាស់ទែងពីជំហរវិជ្ជមានរបស់រដ្ឋាភិបាលចំពោះការវិនិយោគទុន ។ យោងតាមទស្សនាវដ្តីរបស់ International Finance Corporation (IFC: សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ) ដែលចេញផ្សាយពីឆ្នាំមុន ជោគជ័យនៃវេទិកានេះបង្ហាញពីប្រសិទ្ធភាព និងសារៈសំខាន់របស់វា សំរាប់ដំណើរការកំណែទំរង់ ។ ក្នុងចំណោមលក្ខខណ្ឌជាច្រើនដែលកំណត់ពីឥទ្ធិពលសេដ្ឋកិច្ចរបស់វេទិកា តួលេខប្រចាំឆ្នាំនៃវិភាគទានស្ម័គ្រចិត្ត (pro bono) របស់វិស័យឯកជនបង់ចូលក្នុងវេទិកាគឺ ៣៥០,០០០ដុល្លារ ធៀបនឹងមូលនិធិបានពីអ្នកផ្តល់ជំនួយត្រឹម ១៦០.០០០ដុល្លារ ។

កន្លងមកមានលទ្ធផលល្អប្រសើរក៏ពិតមែន ប៉ុន្តែវេទិកាបានឈានមកដល់ផ្លូវបំបែកហើយ ។ ពេលនេះត្រូវមាន ផែនទីនាំផ្លូវមួយដែលបង្ហាញពីវិធានការអន្តរកាលត្រូវអនុវត្ត ដើម្បីឱ្យសហគមន៍អាជីវកម្មអាចទទួលរ៉ាប់រងតួនាទីសម្របសម្រួលដែល IFC កំពុងអនុវត្តសព្វថ្ងៃនេះ ហើយលោក Sciaroni បានផ្តល់មតិពីមធ្យោបាយមួយដើម្បីសំរេចគោលដៅនេះ ។ មធ្យោបាយនោះគឺត្រូវពង្រឹងអ្នកដែលពាក់ព័ន្ធខ្លាំងជាងគេក្នុងវេទិកា ដូចជា ក្រុមការងារវិស័យឯកជន (PSWGs) និងសភាពាណិជ្ជកម្មកម្ពុជា អោយមកទទួលរ៉ាប់រងតួនាទីសម្របសម្រួលនៅពេលណាមួយនាអនាគត ។

យោងតាមដំណើរដូចខាងលើ តើវេទិកានឹងមានអនាគតយ៉ាងណា? ក្រៅពីបេសកកម្មសព្វថ្ងៃរបស់ខ្លួន ជាយន្តការសំរាប់ការផ្លាស់ប្តូរព័ត៌មានជាមួយរដ្ឋាភិបាល និងការដោះស្រាយបញ្ហា វេទិកាគួរមានបេសកកម្មថ្មីៗទៀត ដែលត្រូវអនុវត្តដោយ ក្រុមការងារវិស័យឯកជន ។ បេសកកម្មទាំងនេះមានដូចជា:

- *ការបង្កើតចំណុចស្នូលមួយនៅតាមខេត្តនីមួយៗ:* គួរមានមនុស្សម្នាក់ រឺ ការិយាល័យមួយ សំរាប់ទទួលព័ត៌មានពីបញ្ហានានាដែលសហគ្រាសអាជីវកម្មជួបប្រទះ ហើយបញ្ជូនបញ្ហាទាំងនោះបន្តទៅវេទិកា នៅឯទីក្រុងភ្នំពេញ ដើម្បីដោះស្រាយ ។ ដោយសារវេទិកាប្រារព្ធធ្វើឡើងពីរដងក្នុងមួយឆ្នាំ ហើយមានផ្សព្វផ្សាយតាមទូរទស្សន៍ទូទាំងប្រទេស ដូច្នេះប្រជាពលរដ្ឋគ្រប់គ្នានៅកម្ពុជា គួរតែបានដឹងច្បាស់ពីវេទិកានេះ ។
- *វេទិកាតំបន់:* វេទិកាអាចប្រារព្ធធ្វើនៅតាមមជ្ឈមណ្ឌលនៃតំបន់នានា ដើម្បីពង្រីកវិសាលភាពគ្របដណ្តប់ និងធ្វើអោយសហគ្រាសអាជីវកម្មតាមខេត្ត បានដឹងច្បាស់ពីវេទិកានេះ ។
- *គំនិតផ្តួចផ្តើមរបស់វិស័យឯកជន:* PSWGs គួរសកម្មគ្រប់គ្រងថែមទៀតក្នុងការលើកសំណើកែលំអបរិយាកាសអាជីវកម្ម ។ ទៅអនាគត នៅពេលមានបុគ្គលិក និងធនធានគ្រប់គ្រាន់ សហគមន៍អាជីវកម្មគួរផ្តួចផ្តើមគំនិតលើកស្នើជាគោលនយោបាយថ្មីៗ រឺ សំណើផ្សេងទៀត ដើម្បីកែលំអស្ថានភាពសេដ្ឋកិច្ច ។
- *តួនាទីប្រឹក្សារបស់វិស័យឯកជន:* PSWGs គួរតែសកម្មថែមទៀតក្នុងការផ្តល់ព័ត៌មានសំរាប់ការកសាង គោលនយោបាយសាធារណៈសំខាន់ៗ ដូចជាការដាក់ស្នើសំរាប់ គ្រោងការក្នុងវិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ជាដើម ។

## បញ្ហាប្រឈមខាងអភិបាលកិច្ច និងការអភិវឌ្ឍវិស័យឯកជន

*លោកស្រី អេង នេត្រា ប្រធានស្រាវជ្រាវផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទំរង់សាធារណៈ នៃវិទ្យាស្ថាន CDRI*

ប្រទេសកម្ពុជាសំរេចបានកំណើនសេដ្ឋកិច្ចយ៉ាងខ្ពស់ ក្នុងអំឡុងពេល ១៥ឆ្នាំចុងក្រោយនេះ ។ សន្តិភាព និងស្ថិរភាពជាបន្ត បានផ្តល់ឱកាសអោយសកម្មភាពសេដ្ឋកិច្ចរីកលូតលាស់យ៉ាងខ្លាំងក្នុងគ្រប់វិស័យ ។ ជោគជ័យនេះអាចទទួលបានថ្វីបើមាន ស្ថានភាពលំបាកមួយទាក់ទងនឹងសិទ្ធិមនុស្ស ការគ្រប់គ្រងច្បាប់ និងគុណភាពអភិបាលកិច្ចជារួមក្តី ។ អភិបាលកិច្ចកម្ពុជាងាយស្រួលធ្វើការទិះតៀន ប៉ុន្តែវាស្មុគស្មាញណាស់ និងពិបាកធ្វើកំណែទំរង់ ។ ខាងក្រោមនេះ គឺជាបញ្ហាប្រឈមសំខាន់ៗមួយចំនួន ។

ការសិក្សាពីភាពក្រីក្ររបស់វិទ្យាស្ថាន CDRI បង្ហាញថា គោលនយោបាយនៅតែពិបាកជះឥទ្ធិពលអោយដល់អ្នកក្រដែលជារឿយៗ មិនទាំងបានទទួលសេវាសាធារណៈសំខាន់ៗផងទេ ។ អ្នកក្រក៏ទទួលបានការចាត់ចែងមិនស្មើភាព ហើយរងឥទ្ធិពលយ៉ាងខ្លាំង ពីអំពើពុករលួយរបស់មន្ត្រីក្នុងជួររដ្ឋាភិបាល ។ ការសិក្សាបានបង្ហាញទៀតថា អ្នកមានឋានៈខ្ពស់ និងបណ្តាញខ្សែ-ខ្នង បានប្រើឥទ្ធិពល និងអំណាចស្រេចតែចិត្ត ដោយបានកាត់បន្ថយលទ្ធភាពរបស់អ្នកក្រ ដើម្បីប្រើប្រាស់ធនធានធម្មជាតិ និងធ្វើការសំរេចចិត្ត ។ ការសិក្សាផ្សេងទៀតរបស់វិទ្យាស្ថាន CDRI ស្តីពីគណនេយ្យភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ បង្ហាញថា ប្រព័ន្ធអភិបាលកិច្ចកម្ពុជាមានជោគជ័យតិចតួចក្នុងការគ្រប់គ្រងថវិការដ្ឋអោយមានប្រសិទ្ធភាព និងជាប់ទាក់ទងល្អ នឹងគំរោងផែនការ ហើយក៏ហាក់ដូចជាបរាជ័យដែរក្នុងការជ្រើសរើស និងផ្តល់រង្វាន់ដល់មន្ត្រីរាជការដែលមានគុណសម្បត្តិ ។

របាយការណ៍ស្តីពី "ការធ្វើអាជីវកម្មឆ្នាំ២០០៨" របស់ធនាគារពិភពលោក បានធ្វើចំណាត់ថ្នាក់អោយប្រទេសកម្ពុជាជាប់លេខ ១៤៥ ក្នុងចំណោម ១៧៨ប្រទេស ចំពោះភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម ។ របាយការណ៍បង្ហាញថា បើធៀបនឹងឆ្នាំមុន ប្រទេសកម្ពុជាបានប្រសើរឡើងបន្តិចទាក់ទិននឹងការចាប់បើកអាជីវកម្ម ការចេញអាជ្ញាប័ណ្ណ និងការជួលប្រើពលករ ប៉ុន្តែទទួលចំណាត់ថ្នាក់អន់សំរាប់ ភាពប្រាកដប្រជានៃគោលនយោបាយ អំពើពុករលួយ សិទ្ធិអចលនទ្រព្យ តុលាការ និងបទល្មើសព្រហ្មទណ្ឌ ។ ប៉ុន្តែការពិភាក្សាពេញអង្គក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨ បានមើលឃើញថា តួនាទី និងឥទ្ធិពលនៃសន្ទស្សន៍ប្រៀបធៀបគ្នាជាសកលរបស់កត្តានានា ដែលជួយរួមចំណែកបង្កើតបរិយាកាសអាជីវកម្មអំណោយផល ព្រមទាំងអង្កេតជាប់ទាក់ទិននានាស្តីពីអភិបាលកិច្ច និងអំពើពុករលួយ គឺទាំងខាងអ្នកតំណាងរដ្ឋាភិបាលកម្ពុជានិងវិស័យឯកជន មិនបានអោយតំលៃអ្វីច្រើនទេ ។ ពួកគេបានសួរថា តើអង្កេតបែបនេះអាចឆ្លុះបញ្ចាំងបានពិតជាក់ស្តែងប៉ុណ្ណាពីឱកាសល្អផ្សេងៗសំរាប់ការអភិវឌ្ឍវិស័យឯកជន និងសហគ្រិនភាព ហើយក៏បានចោទសំនួរជាច្រើនពីវិធីសាស្រ្ត និងភាពពេញសិទ្ធិរបស់វា ។

ការជំនះឧបសគ្គក្នុងការអភិវឌ្ឍវិស័យឯកជន ដើម្បីសំរេចគោលដៅកាត់បន្ថយភាពក្រីក្រ នៅតែជាបញ្ហាប្រឈម ។ ប៉ុន្តែគំនិតផ្តួចផ្តើមធ្វើកំណែទំរង់នាពេលថ្មីៗមួយចំនួន (វិមជ្ឈការ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) មានលក្ខណៈវិជ្ជមាន ហើយគួរអនុវត្តបន្តទៀត ។ វិធានការជាក់លាក់មួយចំនួន មានដូចជា:

- *រដ្ឋាភិបាលបន្តយកចិត្តទុកដាក់លើការធានាស្ថិរភាព:* ចំណុចនេះបានន័យថា រាល់កំណែទំរង់ និងការផ្លាស់ប្តូរដែលចង់បាន អាចធ្វើឡើងជាបណ្តើរៗ រីកធ្វើភ្លាមៗតាមការចាំបាច់ ។
- *ការពង្រឹងកំណែទំរង់វិមជ្ឈការ* តាមរយៈការបោះឆ្នោតជាប្រយោលបង្កើតក្រុមប្រឹក្សាខេត្ត-ស្រុក ដែលមានអំណាចនិងធនធានគ្រប់គ្រាន់ និងមានមុខងារច្រើនដូចជា ការគ្រប់គ្រងធនធានធម្មជាតិ ការគាំទ្រកសិកម្ម ការផ្តល់សេវាកម្ម ការធ្វើផែនការនិងគ្រប់គ្រងការប្រើប្រាស់ដី និងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។
- *ការពង្រីកជោគជ័យលើកំណែទំរង់ហិរញ្ញវត្ថុ* ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងទិសដៅធ្វើសនិទានកម្មថវិកា និងធ្វើអោយដំណើរការហិរញ្ញវត្ថុសាធារណៈកាន់តែមានតម្លាភាព និងប្រសិទ្ធភាព ។ ទិដ្ឋភាពសំខាន់ៗ មានជាអាទិ៍ ការដាក់បញ្ចូលចំណូលនៅគ្រប់កំរិតនៃរដ្ឋាភិបាលទៅក្នុងថវិកាជាតិ និង ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីអោយរដ្ឋាភិបាលអាចឆ្លើយតបនឹងតំរូវការសេវាសាធារណៈរបស់ប្រជាពលរដ្ឋ ។
- *ការពង្រឹងវេទិការដ្ឋាភិបាល-វិស័យឯកជន និងក្រុមការងារវិស័យឯកជនទាំង៨* ដែលកន្លងមកមានប្រសិទ្ធភាពល្អជួយបង្កើនការប្រស្រ័យទាក់ទងដោយផ្ទាល់ និងត្រង់ទៅត្រង់មក រវាងថ្នាក់ដឹកនាំរដ្ឋាភិបាល និងអាជីវករនៅកម្ពុជា ។ នេះជាមូលដ្ឋានដ៏ជាក់លាក់ និងមានសារប្រយោជន៍ ដែលអាចបង្កើតឱ្យមានគណនេយ្យភាពកាន់តែខ្លាំង និងចម្លើយតបពីសំណាក់រដ្ឋាភិបាល ចំពោះបញ្ហាប្រឈមនានារបស់វិស័យឯកជន ។
- *ការឈានឡើងរបស់អ្នកដឹកនាំសហគ្រាសអាជីវកម្ម និងអ្នកមានបំាង: ខ្ពស់ថ្មីៗ:* អស់រយៈពេលជាយូរមកហើយ តាមរយៈទំនាក់ទំនងកាន់តែជិតស្និទ្ធពីមួយឆ្នាំទៅមួយឆ្នាំរបស់អ្នកទាំងនេះជាមួយរដ្ឋាភិបាល ពួកគេប្រហែលជាអាចទាមទារកំណែទំរង់ប្រភេទខ្លះទៀតបាន ។

## អាជីវកម្មរ៉ែប្រកបដោយគុណភាព និងការអភិវឌ្ឍធនធានរ៉ែ

*លោក Tim Duffy ប្រធានគ្រប់គ្រងហិរញ្ញវត្ថុប្រចាំតំបន់អាស៊ី នៃក្រុមហ៊ុន Oxiana*

*ការរៀបរាប់ត្រួសៗពីក្រុមហ៊ុន Oxiana:* Oxiana ជាក្រុមហ៊ុនកំពុងរីកលូតលាស់ និងមានជោគជ័យ ដោយមានអណ្តូងរ៉ែកំពុងដំណើរការ គំរោងថ្មីៗកំពុងអភិវឌ្ឍ និងគំរោងរុករករ៉ែជាច្រើនទៀត ។ ក្រុមហ៊ុននេះកាន់កាប់ និងធ្វើប្រតិបត្តិការ អណ្តូងរ៉ែមាស និងទង់ដែង Sepon នៅប្រទេសឡាវ, មូលដ្ឋាន Golden Grove និងប្រតិបត្តិការលោហៈមានតំលៃនៅភាគខាងលិចប្រទេសអូស្ត្រាលី ព្រមទាំង កំពុងចូលរួមក្នុងការរុករក និងអភិវឌ្ឍន៍គំរោងនៅប្រទេសកម្ពុជា ចិន ឥណ្ឌូនេស៊ី និងថៃ ។

*ចក្ខុវិស័យ:* ចក្ខុវិស័យរបស់ក្រុមហ៊ុន Oxiana គឺបង្កើតក្រុមហ៊ុនយករ៉ែដ៏ធំមួយ ។ ក្រុមហ៊ុនមានគោលដៅអនុវត្តចក្ខុវិស័យនេះ តាមរយៈការពង្រីកមូលដ្ឋានរបស់ក្រុមហ៊ុន និងអាជីវកម្មលោហៈមានតំលៃ ក៏ដូចជាតាមរយៈការធ្វើចំរុះកម្ម ជាបណ្តើរៗ ។ ក្រុមហ៊ុនផ្តោតការងារលើទ្វីបអាស៊ីប៉ាស៊ីហ្វិក អូស្ត្រាលី ព្រមទាំងតំបន់ខ្លះទៀត ។ ទ្រព្យសកម្មរបស់ក្រុមហ៊ុនផ្តល់អត្រាចំណេញខ្ពស់ មានអាយុកាលវែង មានស្ថានភាពល្អច្រើន ហើយក្រុមហ៊ុននៅមានគំរោងអភិវឌ្ឍន៍ជាច្រើនទៀត ដែលត្រូវអនុវត្តជាបន្តបន្ទាប់ ។

*សេដ្ឋកិច្ចសកល និងឱកាសសំរាប់ការអភិវឌ្ឍធនធានរ៉ែ:* ការផ្តោតលើទ្វីបអាស៊ីពីសំណាក់ក្រុមហ៊ុន Oxiana មានន័យថា ក្រុមហ៊ុនមានស្ថានភាពល្អនៅក្នុង តំបន់ដែលមានកំណើនខ្លាំងជាងគេក្នុងពិភពលោកនេះ ។ ប៉ុន្តែកំណើនរបស់អាស៊ី មិនបានជ្រាបមកដល់វិស័យរ៉ែនោះទេ ពីព្រោះទោះបីអាស៊ីបានប្រើប្រាស់អស់ ៥១% នៃទង់ដែងក្នុងពិភពលោកក្តី ប៉ុន្តែវាផលិតបានតែ ១៥% ប៉ុណ្ណោះ ។ បណ្តាប្រទេសតាមឆ្នេរមហាសមុទ្រប៉ាស៊ីហ្វិក (Pacific Rim) ក៏មានធនធានរ៉ែច្រើនសន្ធឹកសន្ធាប់ដែរ ។ ដូច្នេះការដែល Oxiana មានប្រតិបត្តិការអាជីវកម្មរ៉ែនៅអាស៊ី មានន័យថា ក្រុមហ៊ុនអាចបញ្ជូនផលិតផលខ្លួនយ៉ាងលឿន និងអស់ថ្លៃដឹកជញ្ជូនតិច ទៅកាន់ទីផ្សារដ៏មានសន្ទុះទាំងនេះ ។

*ផលប្រយោជន៍អាជីវកម្មរ៉ែសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍:* ច្បាប់អាជីវកម្មរ៉ែ ដែលថ្លឹងថ្លែងបានល្អ អាចនាំអោយមានស្ថិរភាពកំណើន ផសស ក្នុងរយៈពេលវែង ដូចអាចពិនិត្យឃើញជាក់ស្តែងនៅប្រទេសហ្គាណា ។ ចាប់តាំងពីហ្គាណា បានដាក់អនុវត្តក្រមអាជីវកម្មរ៉ែនៅទសវត្សរ៍១៩៨០ មក លំនាំកំណើនមិនទៀងទាត់ និងរយៈពេលធ្លាក់ចុះដែលតែងកើតមានក្នុងពេលកន្លងមក ត្រូវបានលុបបំបាត់ចោលទាំងអស់ ។

*ឧទាហរណ៍នៅប្រទេសឡាវ:* នៅប្រទេសឡាវ ក្រុមហ៊ុន Oxiana អាចបង្កើតប្រតិបត្តិការយករ៉ែតាមស្តង់ដារខ្ពស់បំផុត ក្នុងពិភពលោក បានទាន់ពេលតាមផែនការ និងក្នុងរង្វង់ថវិកាកំណត់ នៅតំបន់មួយដាច់ស្រយាលបំផុតក្នុងប្រទេសនេះ ។ ប្រតិបត្តិការនៅ Sepon គឺជាគំរោងយករ៉ែដ៏ធំបំផុតមួយនៅអាស៊ីអគ្នេយ៍តំបន់ដីគោក នាបច្ចុប្បន្ន ។ វិធីសាស្ត្ររបស់ក្រុមហ៊ុនក្នុងការអភិវឌ្ឍគំរោងនេះ គឺធ្វើយ៉ាងណាអោយមានផលប្រយោជន៍ហូរទៅដល់ដៃអ្នកពាក់ព័ន្ធគ្រប់ៗគ្នា ។

*ប្រទេសកម្ពុជា:* សព្វថ្ងៃ ក្រុមហ៊ុន Oxiana កំពុងរុករកមាសក្នុងថ្មក្រានីតនៅភាគខាងកើតប្រទេសកម្ពុជា ព្រមទាំង ទង់ដែង និងលោហៈផ្សេងទៀត ។ ទីចាត់ការក្រុមហ៊ុន Oxiana ស្ថិតនៅទីក្រុងភ្នំពេញ ហើយនាបច្ចុប្បន្នមានបុគ្គលិកជាង ៦០នាក់ (រួមទាំងអ្នកជាប់កិច្ចសន្យា) ។ ក្នុងអំឡុងពេលរុករកផលប៉ះពាល់ដល់បរិស្ថានមានកំរិតទាប ប៉ុន្តែស្តង់ដារអន្តរជាតិត្រូវតែគោរពតាម ហើយប្រតិបត្តិការត្រូវតាមដានយ៉ាងជិតដល់ ។

*សន្និដ្ឋាន:* ក្រុមហ៊ុន Oxiana បានត្រៀមខ្លួនរួចរាល់សំរាប់អំឡុងពេលដ៏វែងនៃការរីកដុះដាលសេដ្ឋកិច្ចសកលលោក ដែលជំរុញដោយអាស៊ី ។ ក្រុមហ៊ុនសង្ឃឹមថានឹងមានឱកាសធ្វើការអភិវឌ្ឍធនធាន ក្នុងគោលគំនិតផ្តល់ផលចំណេញសេដ្ឋកិច្ចមានចីរភាពល្អដល់ប្រជាជាតិនានា ។

## សង្ខេបខ្លឹមសារសំខាន់ៗនៃវគ្គនេះ

ចំណុចសំខាន់ៗនៃវគ្គនេះមានដូចតទៅ:

- ក្របខ័ណ្ឌសំរាប់ការសន្ទនារវាងរដ្ឋាភិបាលនិងវិស័យឯកជន ភាពជាដៃគូ និងការធ្វើផែនការរួមគ្នា គឺមានស្រេចហើយ ដូចជា វេទិការដ្ឋាភិបាល-វិស័យឯកជន ដែលទទួលបានការគាំទ្រខ្លាំងណាស់ពីសំណាក់អាជីវករ ។

(តទៅទំព័រ ២០)

# ដីធ្លី ទ្រព្យសម្បត្តិ អចលនទ្រព្យ ការប្រើប្រាស់ដីប្រកបដោយផលិតភាព និងការអភិវឌ្ឍ

*លោកឡារី ស្រេ្តន្ធ សង្ខេបពីបញ្ហាសំខាន់ៗ បានពិនិត្យឃើញក្នុងវគ្គអាហារពេលល្ងាចពិសេសនៃសន្និសីទចក្ខុវិស័យ និងចង្អុលបង្ហាញពីសំនួរគោលនយោបាយសំខាន់ៗមួយចំនួន ដែលត្រូវឱ្យមានការយកចិត្តទុកដាក់លើជំហានបន្ទាប់នៃការអភិវឌ្ឍរបស់កម្ពុជា ។**

## សេចក្តីផ្តើម: ដីធ្លី ទ្រព្យសម្បត្តិ និងអចលនទ្រព្យនៅកម្ពុជា

ក្នុងប៉ុន្មានខែមុនពេលដំណើរការសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨ បញ្ហាដីធ្លី គឺជាប្រធានបទពិភាក្សាក្តៅគគុករវាងអ្នកនយោបាយ មន្ត្រីរាជការ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយនានា ។ កម្មសិទ្ធិ ការប្រើប្រាស់ តំលៃសេដ្ឋកិច្ចនៃដីធ្លី តួនាទីដីធ្លីក្នុងការអភិវឌ្ឍសង្គម/សេដ្ឋកិច្ច ក្នុងការរកចិញ្ចឹមជីវិតនៅជនបទ/ទីក្រុង ការអភិវឌ្ឍអាជីវកម្មក្នុងវិស័យឯកជន ការកាត់បន្ថយភាពក្រីក្រ និងជាពិសេសតួនាទីជាប្រភពទំនាស់/ការប្រកួតប្រជែងដណ្តើមធនធាន សុទ្ធតែជាបញ្ហាដ៏លេចធ្លោនៅក្នុងកិច្ចពិភាក្សាជាសាធារណៈ ។ នៅក្នុងសុន្ទរកថាបើកសន្និសីទ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃកម្មវិធីចុះបញ្ជីដីធ្លីទាំងនៅទីប្រជុំជន និងជនបទរបស់រដ្ឋាភិបាល និងតួនាទីដ៏សំខាន់នៃការធ្វើផែនទីដីរដ្ឋ និងការកំណត់ព្រំដែនតំបន់ព្រៃឈើ ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាត់បន្ថយទំនាស់ ។ សម្តេចនាយករដ្ឋមន្ត្រី ក៏បានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដើម្បីធ្វើកំណែទំរង់តំបន់ជនបទ ជាពិសេស ការបង្កើនប្រព័ន្ធធារាសាស្ត្រ និងការបែងចែកដី ដែលនឹងជួយបង្កើនផលកសិកម្ម និងការធ្វើចំរុះកម្មផលិតកម្ម ក្នុងរយៈពេលមធ្យម ។

សន្និសីទចក្ខុវិស័យ មានរួមបញ្ចូលវគ្គពិសេសមួយស្តីពីបញ្ហាដីធ្លី ក្រោមប្រធានបទ "ការទាញប្រយោជន៍អោយបានប្រសើរបំផុតពីធនធានធម្មជាតិនៅកម្ពុជា - ដីធ្លី អចលនទ្រព្យ ការប្រើប្រាស់ដីប្រកបដោយផលិតភាព និងការអភិវឌ្ឍ" ដោយមានវាគ្មិនមកពីខាងរដ្ឋាភិបាល វិស័យធនាគារ វិស័យអភិវឌ្ឍន៍អចលនទ្រព្យ និងវិទ្យាស្ថាន CDRI ។ វិស័យអចលនទ្រព្យនៅកម្ពុជាបានរីកចំរើនលឿនណាស់នាពេលថ្មីៗ ហើយសន្ទុះកំណើនដ៏ខ្លាំងនេះអាចនាំមកជាមួយទាំងគុណប្រយោជន៍ និងហានិភ័យ ។ ដីទាំងសំរាប់ការកសាងលំនៅដ្ឋាន និងតំរូវការខាងពាណិជ្ជកម្ម បានឡើងថ្លៃយ៉ាងគំហុក ជាពិសេសនៅតាមទីប្រជុំជន ។ បណ្ឌិត បេង ហុងសុជាតិខេមរ៉ូ ដែលជាមន្ត្រីជាន់ខ្ពស់ម្នាក់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានពន្យល់អង្គសន្និសីទថា រដ្ឋាភិបាលបានអនុវត្តកម្មវិធីចុះបញ្ជីដីធ្លីដ៏ធំមួយ និងកសាងឯកសារខាងគោលនយោបាយដីធ្លី ដែលមានទាំងការងារធ្វើផែនការអភិវឌ្ឍក្រុងផងដែរ ហើយក្នុងនោះមានការទទួលស្គាល់ថា ការអភិវឌ្ឍជនបទតែម្យ៉ាងមិនអាចកាត់បន្ថយភាពក្រីក្របានទេ ។ តំបន់ទីប្រជុំជនក៏មានតួនាទីសំខាន់ណាស់ដែរក្នុងការកាត់បន្ថយភាពក្រីក្រ ដោយក្នុងនោះទីប្រជុំជនខ្នាតតូច និងមធ្យម ដើរតួនាទីជាទីក្រុងដែលអាចផ្តល់នូវទីផ្សារសំរាប់ផលិតផលនិងពលកម្មដល់សហគមន៍នានានៅជុំវិញនោះ ។

លោក Rory Hunter ជាតំណាងក្រុមហ៊ុនអភិវឌ្ឍអចលនទ្រព្យ Brocon Group បានរៃកញ្ញេកថា ការអភិវឌ្ឍដីធ្លី និងអចលនទ្រព្យយ៉ាងលឿនបែបនេះ ធ្វើអោយប្រទេសកម្ពុជាជួបបញ្ហាប្រឈមខាងការធ្វើផែនការ និងការគ្រប់គ្រង ដើម្បីធានាគុណភាពនៃការអភិវឌ្ឍអចលនទ្រព្យ អោយវាអាចជួយបង្កើតទ្រព្យធន និងបំរើតំរូវការរបស់សហគមន៍ទាំងឡាយ ។ អ្នកចូលរួមក្នុងការអភិវឌ្ឍអចលនទ្រព្យនៅកម្ពុជា គេមានផលប្រយោជន៍មិនដូចគ្នាទេក្នុងការធានាគុណភាពនេះ ។ ផលប្រយោជន៍ អ្នកមានភាគហ៊ុនក្នុងក្រុមហ៊ុន គឺអតិបរមានីយកម្មប្រាក់ចំណេញក្នុងរយៈពេលវែង ការបង្កើតតំលៃ ការកសាងទំនុកចិត្តជាមួយវិនិយោគិន/អ្នកទិញ ការកសាងទំនាក់ទំនងរឹងមាំជាមួយអាជ្ញាធរ/សហគមន៍មូលដ្ឋាន និងការកសាងឈ្មោះក្រុមហ៊ុនអោយល្បី ដែលជាទស្សនៈមួយថ្មីសំរាប់ប្រជាជនកម្ពុជាភាគច្រើន ។ ផលប្រយោជន៍របស់អ្នកទិញផ្តោតលើលទ្ធភាពទទួលបានផ្ទះដែលកសាងមាំជាប់ល្អសំរាប់ស្នាក់នៅរឺធ្វើវិនិយោគ ការបង្កើតប្រាក់ចំណូលរួមទាំងកំណើនតំលៃទ្រព្យវិនិយោគ ទំនុកចិត្តថាក្រុមហ៊ុនមិនក្ស័យធន និងស្មារតីភ្លឺស្វាងមើលឃើញការសន្យាបោកប្រាស់/ការបំភ្លៃការពិត ។ ផលប្រយោជន៍របស់សហគមន៍ គឺផលប្រយោជន៍ជាទូទៅសំរាប់បរិស្ថាននៅមូលដ្ឋាន សេវាកម្មរបស់សហគមន៍ ការបង្កើតការងារ ភាពច្បាស់លាស់/ការគោរពច្បាប់ក្នុងការលក់ដូរអចលនទ្រព្យ និងការប្តេជ្ញាចិត្តធ្វើឱ្យអចលនទ្រព្យមានគុណភាពល្អរហូតដល់ ៣០ឆ្នាំ គិតចាប់ពីពេលនេះទៅ ។ ផលប្រយោជន៍របស់រដ្ឋាភិបាល គឺវត្តមានគោលការណ៍ណែនាំច្បាស់លាស់សំរាប់អ្នកអភិវឌ្ឍអចលនទ្រព្យ ជាពិសេសសំរាប់ក្រុមហ៊ុនបរទេសដែលមកបណ្តាក់ទុននៅកម្ពុជា កិច្ចការពារអ្នកទិញទប់ទល់នឹងគ្រោះថ្នាក់ក្ស័យធនរបស់ក្រុមហ៊ុន ការយកពន្ធលើការកាន់កាប់ដីល្អៗដោយគ្មានធ្វើការអភិវឌ្ឍ និងបានចំណេញអ្វីដល់សេដ្ឋកិច្ច/សហគមន៍ក្រៅតែពីការទុកលក់កេងយកចំណេញ និងការធ្វើផែនការអភិវឌ្ឍសមហេតុផល/ការកំណត់តំបន់ប្រើប្រាស់ដី ដើម្បីជំរុញការវិនិយោគទុនលើការអភិវឌ្ឍអចលទ្រព្យមានគុណភាពល្អ ។

បញ្ហាគោលនយោបាយសំខាន់ៗក្នុងការដោះស្រាយផលប្រយោជន៍ច្រើនបែបយ៉ាងនេះរួមមាន តំរូវការបទប្បញ្ញត្តិច្បាប់ល្អប្រសើរថែមទៀតច្បាប់សំណង់ដើម្បីកាត់បន្ថយជំលោះ និងមធ្យោបាយបង្កើនចំណាយកាន់កាប់ដីដោយគ្មានធ្វើការអភិវឌ្ឍ ដូចជា តាមរយៈពន្ធលើដីមិនប្រើប្រាស់ជាដើម ។ ទាក់ទិននឹងផ្នែកធនាគារ/ឥណទាន លោក Chales Vann តំណាងធនាគារកាណាឌីយ៉ា បានបញ្ជាក់ថា អ្នកទិញត្រូវការកិច្ចការពារដ៏ល្អជាងនេះទៀតនៅក្នុងបរិយាកាសមានហានិភ័យខ្ពស់ ដែលក្រុមហ៊ុនអភិវឌ្ឍសាងសង់ទាំងនោះអាចទារអោយបង់ជាមុនដល់ទៅ ៦០-៨០% នៃថ្លៃផ្ទះសរុប ។

## ការប្រើប្រាស់ដីធ្លីប្រកបដោយផលិតភាព និងការអភិវឌ្ឍប្រទេសកម្ពុជា

វិទ្យាស្ថាន CDRI ផ្តោតការងារលើ "ការប្រើប្រាស់ដីមានផលិតភាព និងការអភិវឌ្ឍប្រទេសកម្ពុជា" ក្នុងលក្ខណៈខ្លួនជាស្ថាប័នស្រាវជ្រាវខាងគោលនយោបាយអភិវឌ្ឍន៍ ដែលជាប់ទាក់ទងនឹងការបង្កើតទ្រព្យធន/ការកាត់បន្ថយភាពក្រីក្រ ។ ការស្រាវជ្រាវថ្មីៗរបស់ CDRI និងស្ថាប័នផ្សេងៗទៀតបានបង្ហាញច្បាស់ថា ការប្រើប្រាស់ដីអោយមានផលិតភាព និងការគ្រប់គ្រងដីធ្លីជាទូទៅ រួមទាំងសុវត្ថិភាពកាន់កាប់ដីទាំងនៅទីក្រុង និង

* លោកឡារី ស្រេ្តន្ធ ជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI

ជនបទ គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រទេសកម្ពុជា/ការកាត់បន្ថយភាពក្រីក្រ ។ វាក៏ជះឥទ្ធិពលដល់ការរស់នៅ ការខ្ចីឥណទាន វិនិយោគ/ការធ្វើចំរុះកម្មខាងកសិកម្ម ទីផ្សារដីធ្លី ការអភិវឌ្ឍលំនៅដ្ឋាន/ទីក្រុង និងវិនិយោគលើសហគ្រាសធុនតូច និងមធ្យម (SME) ។ ការសិក្សាថ្មីៗរបស់ CDRI បង្ហាញថាប្រជាជនក្រីក្រកាន់តែពឹងផ្អែកខ្លាំងឡើងលើដីធ្លី និងធនធានធម្មជាតិខាងជលផល ដើម្បីទ្រទ្រង់ជីវភាពដ៏ តឹងតែងរបស់ខ្លួន ។ ខណៈដែលគ្រួសារនៅជនបទជាអ្នកធូរធារ រឹកំពុងឈានឡើង មានកាន់កាប់ដីធំៗជាងទទួលបានទិន្នផលនិងប្រាក់ចំណេញច្រើនជាង គ្រួសារក្រីក្រជាច្រើនកាន់តែពិបាកនឹងរកចំណូលពីការធ្វើស្រែ ហើយក៏ត្រូវលក់ដីធ្លី និងពឹងផ្អែកលើការលក់កំលាំងពលកម្មវិញ ។ វិនិយោគកាន់តែច្រើន និងផ្តោតកាន់តែខ្លាំងលើការបង្កើនផលិតភាព/ការធ្វើចំរុះកម្មផលដំណាំក្នុងកសិដ្ឋានតូចៗ ដែលមានដីតិច ដូចមានគូសបញ្ជាក់ក្នុងគោលនយោបាយបច្ចុប្បន្នរបស់រដ្ឋាភិបាល និងការយល់ដឹងកាន់តែច្បាស់ពីឥទ្ធិពលនៃចំណងទាក់ទងទីក្រុង-ជនបទ ទៅលើគោលនយោបាយ/ការគ្រប់គ្រងដីធ្លី វានឹងផ្តល់ផលល្អសំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។

កត្តាធម្មជាតិដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ ព្រមទាំងដីគ្មានជីវជាតិ និងកង្វះសមត្ថភាពគ្រប់គ្រងទឹក បានកាត់បន្ថយផលិតភាពកសិកម្មនៅក្នុងតំបន់ខ្លះ ហើយលទ្ធភាពជាប្រពៃណីក្នុងការប្រមូលផលព្រៃឈើ និងការនេសាទ ក៏កំពុងទទួលសំពាធកាន់តែខ្លាំងពីកំណើនប្រជាជន និងទំនាស់ជាមួយតួអង្គមានអំណាច និងមានឋានៈខ្ពស់ដែលមកពីក្រៅតំបន់ជនបទ ។ ជាលទ្ធផល នៅតំបន់ខ្លះ អ្នកគ្មានដីធ្លីកំពុងកើនឡើង ទោះដោយចេតនារឺបង្ខំចិត្តក្តី ហើយវិសមភាពកាន់កាប់ដីធ្លី ក៏រីកធំ ក្នុងនេះមានអ្នកក្រកាន់តែច្រើនត្រូវលក់ពលកម្មក្នុងមូលដ្ឋាន រឺធ្វើចំណាកស្រុកទៅតំបន់ផ្សេងៗនៅកម្ពុជា រឺឆ្លងដែនទៅថៃ រឺម៉ាឡេស៊ី ដើម្បីរកការងារធ្វើ ។

ការស្រាវជ្រាវរបស់យើងបានបញ្ជាក់គាំទ្រទស្សនៈថា ជោគជ័យដ៏ធំនៃកម្មវិធីចុះបញ្ជីដីធ្លីនៅកម្ពុជា បានរួមចំណែកច្រើនណាស់ដល់ការពង្រឹងស្ថាប័ននានាដែលជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ឱ្យកាន់តែមានសន្ទុះ ។ វាក៏បង្ហាញដែរថា ការចុះបញ្ជីដីធ្លីតែមួយមុខមិនគ្រប់គ្រាន់ទេ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចអោយកាន់តែមានសមធម៌ និងជួយកាត់បន្ថយភាពក្រីក្រ ។ សំរាប់តំបន់ជនបទ ប័ណ្ណកម្មសិទ្ធិគ្រាន់តែជាធាតុផ្សំសំខាន់មួយប៉ុណ្ណោះនៃអន្តរាគមន៍ដ៏ចាំបាច់នានាខាងអភិវឌ្ឍន៍ ដូចជា លទ្ធភាពទទួលបានឥណទានមានតំលៃសមរម្យ ចំណេះដឹង និងព័ត៌មានតាមរយៈសេវាផ្សព្វផ្សាយបច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធកាន់តែល្អ ដូចជា ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រជាដើម ។

ពិតហើយ គោលនយោបាយជាតិគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិត្រូវបានតាក់តែងឡើង ដើម្បីជំរុញការគ្រប់គ្រងទ្រព្យទាំងនេះអោយមានចីរភាព ប៉ុន្តែការអនុវត្ត និងការពង្រឹងការអនុវត្តមិនស្មើដៃគ្នានៅតាមមូលដ្ឋានកំពុងជំរុញទៅរកការហិនហោចយ៉ាងឆាប់រហ័សនៃធនធានធម្មជាតិ កំណើនភាពគ្មានដីធ្លី និងក្នុងករណីខ្លះកំពុងធ្វើអោយសហគមន៍លែងសូវគោរពដល់បណ្តាស្ថាប័នមានសមត្ថកិច្ច ។ ម្យ៉ាងទៀត គេត្រូវពិចារណាជាបន្ទាន់ពីវិធីទប់ស្កាត់/កាត់បន្ថយទំនាស់ស្តីពីធនធានធម្មជាតិ ជាពិសេសនៅពេលមានការរំលោភយកដី/ធនធានធម្មជាតិពីសំណាក់អ្នកមានឋានៈខ្ពស់ ដើម្បីជួយអោយអ្នកក្រីក្រទទួលបានដំណោះស្រាយយុត្តិធម៌ មិនប្រកាន់បក្សពួក ទាំងសំរាប់ទំនាស់ក្នុងភូមិ និងទំនាស់មានជាប់ពាក់ព័ន្ធនឹងអ្នកមានទ្រព្យសម្បត្តិ/អ្នកមានអំណាច ។

ការស្រាវជ្រាវរបស់យើង បានបង្ហាញច្បាស់ពីតំរូវការបែងចែកធនធានច្រើនថែមទៀត តំរង់ទិសធនធានអភិវឌ្ឍកសិកម្ម/ជនបទអោយកាន់តែប្រសើរ និងពង្រឹងថែមទៀតដោយគ្មានប្រកាន់បក្សពួកនូវ ការអនុវត្តច្បាប់គ្រប់គ្រងការប្រើប្រាស់/ត្រួតត្រាលើទ្រព្យជាធនធានធម្មជាតិ ។ វិធានការនេះនឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើផលិតភាពកសិកម្ម ការកាត់បន្ថយភាពក្រីក្រ និងសុខមាលភាពប្រជាជន ប្រសិនបើមានវិធានការបំពេញបន្ថែមនៅក្នុងមូលដ្ឋានដូចជា សុវត្ថិភាពកាន់កាប់ដី ប្រព័ន្ធធារាសាស្ត្រ សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងឥណទានថោកសមរម្យអាចទទួលយកបាន ។

បទពិសោធន៍ក្នុងប្រទេសកំពុងអភិវឌ្ឍ ដែលពឹងផ្អែកលើកសិកម្មប្រហាក់ប្រហែលគ្នា បានបង្ហាញច្បាស់ថា ប្រសិនបើគ្មានការប្រើប្រាស់ដីប្រកបដោយសមធម៌ ផលិតភាព និងលក្ខណៈចំរុះទេ វានឹងមានការអភិវឌ្ឍកសិកម្មទន់ខ្សោយ ការធ្វើចំរុះកម្មកសិកម្មក៏រឹតទាប និងផលចំណេញតិចតួចសំរាប់កសិករតូចៗភាគច្រើន ។ នៅប្រទេសខ្លះ កត្តានេះនាំអោយមានរបប "សក្តិភូមិបែបថ្មី" ដែលក្នុងនោះកម្មសិទ្ធិ និងការប្រើប្រាស់ដី វាប្រមូលផ្តុំនៅក្នុងដៃអ្នកមានឋានៈខ្ពស់មួយចំនួនតូចដែលរស់នៅទីក្រុង ហើយការរំលោភយកដី/ធនធានធម្មជាតិ ពីសំណាក់ពួកអ្នកមានឋានៈខ្ពស់គឺជារឿងធម្មតា ។ ក្នុងសេណារីយ៉ូបែបនេះ ការអភិវឌ្ឍគឺអាចសំរេចបានមួយក៏រិត ប៉ុន្តែវានឹងលែងកើនថែមទៀត ហើយផ្តល់ជំរើសតិចតួចណាស់សំរាប់ការអភិវឌ្ឍមានចីរភាព/ការកាត់បន្ថយភាពក្រីក្រ ។ នៅពេលមានរឿងដូចខាងលើ គេពិបាកកែតំរូវវិញណាស់ ហើយប្រទេសកម្ពុជាអាចរៀនសូត្រពីបទពិសោធន៍នេះដើម្បីចៀសវាងបញ្ហា ។

ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺជាបញ្ហាស្មុគស្មាញ និងចំរូងចំរាស់នៅកម្ពុជា ដែលនាំអោយមានផុសសំនួរជាច្រើនពីតម្លាភាព/លក្ខណៈមិនប្រកាន់បក្សពួកក្នុងការផ្តល់សម្បទាន និងពីមុខសញ្ញាបំរើសេដ្ឋកិច្ចពិតមែន រឺយ៉ាងណា ។ សម្បទានដីសេដ្ឋកិច្ចសំរាប់ដាំដំណាំលក់យកប្រាក់ និងធ្វើចំការធំៗ អាចផ្តល់ផលចំណេញបានច្រើន និងភ្លាមៗដល់សេដ្ឋកិច្ចក៏ពិតមែន ប៉ុន្តែវាអាចជួយបានតិចតួចណាស់ដល់ផលិតភាពកសិកម្មក្នុងរយៈពេលវែង ក៏រឹតជីវភាពនៅជនបទ និងការកាត់បន្ថយភាពក្រីក្រ ។ ប្រសិនបើគ្រប់គ្រងមិនបានល្អទេ វាអាចក្លាយជាការប្រមូលទិញដីសំរាប់ទុកលក់កេញយកចំណេញ និងគេចវេសពីការបង់ពន្ធ ។ កន្លងមកមានការធ្វើរបងព័ទ្ធយកដីធំៗ ដែលបានបន្ទុចបង្អាក់ដល់សហគមន៍នានាដែលត្រូវធ្វើការអភិវឌ្ឍជនបទ និងកសិកម្មដោយខ្លួនឯង ។ ម្យ៉ាងវិញទៀត សម្បទានដីសង្គមកិច្ច ក៏អាចជាយន្តការមួយដ៏សំខាន់សំរាប់ផ្តល់ដីទៅអោយអ្នកគ្មានដីធ្លី ហើយក៏អាចក្លាយជាគោលការណ៍ណែនាំខាងគោលនយោបាយ និងជាប្រព័ន្ធមួយសំរាប់កែប្រែដីព្រៃរបស់រដ្ឋអោយទៅបំរើតំរូវការផលិតកម្មកសិកម្មវិញ ។ ប៉ុន្តែកន្លងមក ដំណើរការផ្តល់សម្បទានដីសង្គមកិច្ចវាយឺតយ៉ាវខ្លាំងណាស់ ហើយត្រូវតែពន្លឿនថែមទៀត ។

ក្នុងដំណាក់កាលខាងមុខនៃការអភិវឌ្ឍប្រទេសកម្ពុជា មានបញ្ហាខាងគោលនយោបាយធំៗមួយចំនួនដែលត្រូវយកចិត្តទុកដាក់:

១. តើប្រទេសកម្ពុជាត្រូវធ្វើដូចម្តេច ដើម្បីសំរេចបានតុល្យភាពល្អរវាងគោលនយោបាយ/ការគ្រប់គ្រងដីធ្លី ដែលជួយជំរុញការប្រើប្រាស់ដីអោយមានផលិតភាព/ការបង្កើតទ្រព្យធន ហើយនិងការធ្វើអោយប្រាកដថានៅតំបន់ជនបទ គឺមានដីធ្លីសំរាប់ធ្វើការអភិវឌ្ឍជនបទ/កាត់បន្ថយភាពក្រីក្រអោយបានសំរេច ?

២. តើគេអាចពង្រីកព្រំដែនកសិកម្មយ៉ាងណាបាន តាមរយៈការយកដីរដ្ឋមកបំរើផលិតកម្មកសិកម្ម? តើរដ្ឋគួរព្យាយាមរក្សាទុកដីធ្លី ឬក៏យល់ព្រមផ្ទេរវាទៅអោយវិស័យឯកជនដើម្បីអភិវឌ្ឍកសិកម្ម? បើយល់ព្រមផ្ទេរ តើគួរ

(តទៅទំព័រ ១៧)

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

អត្ថបទនេះ បកស្រាយពីដំណើរការសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចខ្លាំងៗក្នុងពិភពលោក និងប្រទេសកំពុងអភិវឌ្ឍមួយចំនួនក្នុងតំបន់ ព្រមទាំងបង្ហាញពីនិន្នាការថ្លៃទំនិញកសិកម្មខ្លះៗក្នុងទីផ្សារអន្តរជាតិ នៅត្រីមាសទី៤ ២០០៧ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៤ ឆ្នាំ២០០៧ ផសស ពិត របស់សហរដ្ឋអាមេរិក កើន ២,៥% ធៀបនឹងមួយឆ្នាំមុន ដោយសារមានការចូលរួមចំណែកជាវិជ្ជមានអំពីចំណាយប្រើប្រាស់ផ្ទាល់ខ្លួន ការនាំចេញ ខ្ទង់អនិវាសជន ចំណាយរបស់រដ្ឋនិងអាជ្ញាធរមូលដ្ឋាន បរិក្ខារ និងសូហ្វវែរ ។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំ មានកំរិតទាបជាងនៅត្រីមាសមុន និងត្រីមាសទី៤ ឆ្នាំ២០០៦ ដែលបង្ហាញពីការថយចុះវិនិយោគលើស្តុកទំនិញ ការនាំចេញ និងការចំណាយរបស់រដ្ឋាភិបាលសហព័ន្ធ។ កំណើន ផសស ពិត នៅតំបន់អឺរ៉ូ ក្នុងរយៈពេល១ឆ្នាំមានកំរិត ២,២% គឺទាបជាងកំណើន ២,៧% នៅត្រីមាសទី៣ ឆ្នាំ២០០៧ និងកំណើន ៣,១% នៅត្រីមាសទី៤ ឆ្នាំ២០០៦ ។ នៅប្រទេសជប៉ុន នៅត្រីមាសទី៤ ផសស កើនបាន ២,0% ធៀបនឹងមួយឆ្នាំមុន ។

ផសស ពិត នៅចិន កើន ១១,២% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំមុន ប៉ុន្តែវាមានកំណើនយឺតបន្តិចធៀបនឹងត្រីមាសមុន ។ កំណើនខ្ពស់នេះបានមកពីកំណើនដ៏មាំទាំ និងមានស្ថិរភាពនៃផលិតកម្មឧស្សាហកម្ម និងការនាំចេញ ។ ក្នុងរយៈមួយឆ្នាំ ដល់ត្រីមាសទី៤ ផសស ពិត នៅកូរ៉េខាងត្បូង កើន ៥,៧% ធៀបនឹងកំណើន ៥,២% សំរាប់ត្រីមាសមុន។ កំណើនទទួលបានជាសំខាន់មកពីកំណើនវិនិយោគលើទ្រព្យសកម្មជាប់លាប់ ១,៦% និងកំណើនការនាំចេញ ៧,0% ។ ក្នុងរយៈមួយឆ្នាំ ផសស ពិត នៅតៃវ៉ាន់ និង ហុងកុង កើន ៦,៤% និង ៦,៧% ។ កំណើននៅហុងកុងខ្ពស់ជាងត្រីមាសមុន រីឯកំណើននៅតៃវ៉ាន់ទាបជាងត្រីមាសមុន ។

កំណើន ផសស នៅម៉ាឡេស៊ី សំរាប់រយៈពេល ១២ខែ នៅតែខ្លាំងដោយឡើងដល់ ៧,៣% ធៀបនឹងកំណើន ៦,៧% នៅត្រីមាសមុន ហើយកត្តាជំរុញសំខាន់គឺ អត្រាកំណើនខ្ពស់ក្នុងផលិតកម្ម (៥,៦%) និងសេវាកម្ម (៩,១%)។ សំរាប់ឆ្នាំ២០០៧ នៅសិង្ហបុរី កំណើន ផសស ពិត ថយចុះមកត្រឹម ៦,0% ធៀបនឹងកំណើន ៨,៩% នៅត្រីមាសមុន និងកំណើន ៧,៧% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី៤ ឆ្នាំ២០០៦ ។ ការថយចុះកំណើននេះ បណ្តាលមកពីការធ្លាក់ចុះកំណើនយ៉ាងខ្លាំងក្នុងផលិតកម្ម សំណង់ និងសេវាកម្មហិរញ្ញវត្ថុ ។ ផសស ពិត នៅថៃ កើន ៥,៧% ធៀបនឹងមួយឆ្នាំមុន គឺខ្ពស់ជាងកំណើន ៤,៨% ក្នុងរយៈពេលមួយឆ្នាំដល់ត្រីមាសមុន ។ កំណើនដ៏ខ្លាំងនេះ បានមកពីការកើនឡើងគួរឱ្យកត់សំគាល់ក្នុងចំណាយប្រើប្រាស់រដ្ឋាភិបាល (១៦%) និងកំណើនយ៉ាងច្រើនក្នុងផលិតកម្ម ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០០៧ ថ្លៃទំនិញប្រើប្រាស់នៅសហរដ្ឋអាមេរិក កើន ៣,៩% ធៀបនឹងមួយឆ្នាំមុន និងកើនខ្លាំងជាងត្រីមាសមុនដែលមានអត្រា ២,៤% ដោយសារអស្ថិរភាពទីផ្សារទំនិញក្នុងសាកលលោក ជាពិសេសម្ហូបអាហារ និងថាមពល ។ អត្រាអតិផរណាប្រចាំឆ្នាំនៅតំបន់អឺរ៉ូមានកំរិត ២,៩% គឺខ្ពស់ជាងកាលពីមួយឆ្នាំមុន និងត្រីមាសមុនដែលមានអត្រា ១,៩% ។ នៅជប៉ុន អតិផរណាប្រចាំឆ្នាំគ្មានការប្រែប្រួលបើធៀបនឹងឆ្នាំមុន ប៉ុន្តែវាខ្ពស់ជាងត្រីមាសមុន (-0,១%)។ ការឡើងថ្លៃទំនិញប្រើប្រាស់អាចបណ្តាលមកពីថ្លៃប្រេង និងទំនិញមួយចំនួនទៀត។

នៅត្រីមាសទី៤ ឆ្នាំ២០០៧ នៅទីផ្សារប្តូរប្រាក់បរទេស ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗ លើកលែងតែទល់នឹងប្រាក់បាតថៃ ។ ដុល្លារប្តូរបាន ១១៣,0៧យ៉េន/ដុល្លារUS ធៀបនឹងត្រីមាសមុនដែលបានដល់ ១១៧,៧ យ៉េន/ដុល្លារUS ហើយដុល្លារក៏ធ្លាក់ថ្លៃដែរទល់នឹងប្រាក់អឺរ៉ូ ប្រាក់យ៉ុនចិន និងប្រាក់វ៉ុនកូរ៉េខាងត្បូង ដោយប្តូរបាន 0,៦៩អឺរ៉ូ/ដុល្លារUS ៧,៤៣យ៉ុន/ដុល្លារUS និង ៩២១,២៣វ៉ុន/ដុល្លារUS ។

## ថ្លៃទំនិញនៅទីផ្សារពិភពលោក

នៅត្រីមាសទី៤ ឆ្នាំ២០០៧ ផលិតផលកសិកម្មហាក់មានដំណើរការល្អ ដោយថ្លៃទំនិញដូចជាពោត ប្រេងឆា អង្ករ និងសណ្តែកសៀង កើនឡើង ។ ថ្លៃពោតកើន ១២% ប្រេងឆា ១៣% និងសណ្តែកសៀង ២២% រីឯថ្លៃអង្ករThai 100% B កើន ៦% ។ ថ្លៃប្រេងឆៅ សាំង និងម៉ាស៊ូត ក៏កើនឡើងដែរក្នុងត្រីមាសនេះ។ ថ្លៃប្រេងឆៅកើនដល់ ៨២,៨៨ ដុល្លារ/ធុង រីឯសាំងកើន ៧% ដល់ ៥៩,៤៨ សេន/លីត្រ និងម៉ាស៊ូតកើន ១៨% ដល់៦៦,៥៤សេន/លីត្រ ។

*រៀបរៀងដោយលោក សាំង ច័ន្ទហង្ស*

---

## តពីទំព័រ ១៦ ដីធ្លី ទ្រព្យសម្បត្តិ អចលនទ្រព្យ ...

អនុវត្តតាមគោលនយោបាយមានផែនការជាក់លាក់ រឺក៏ដើរតាមសេណារីយ៉ូអវិជ្ជមាននៃការផ្លាស់កន្លែង/ចំណាកស្រុករបស់ម្ចាស់ដីតូចៗ ការទន្ទ្រានយកដីធ្វើពាណិជ្ជកម្ម និងការរំលោភយកដីពីសំណាក់ក្រុមហ៊ុន/អ្នកមានឋានៈខ្ពស់?

៣. តើត្រូវគ្រប់គ្រង/ប្រើប្រាស់ដីសម្បទានសេដ្ឋកិច្ច និងដីសម្បទានសង្គមកិច្ចយ៉ាងដូចម្តេច ដើម្បីជួយជំរុញវិនិយោគមានផលិតភាពលើដីធ្លី ដើម្បីផ្តល់ផលប្រយោជន៏ដល់ទាំងអ្នកមាន និងអ្នកក្រ? តើត្រូវកែលំអការគ្រប់គ្រងដីធ្លីយ៉ាងណាទៀតដើម្បីអោយមានតម្លាភាព និងអភិបាលកិច្ចល្អក្នុងការបែងចែកធនធាន កំណត់តំបន់ កំណត់តំលៃ និងបង្កើនចំណូលពន្ធ?

៤. តើរដ្ឋាភិបាល និងវិស័យឯកជន អាចធ្វើយ៉ាងណាដើម្បីជំរុញការអភិវឌ្ឍអចលនទ្រព្យ/ការប្រើប្រាស់ដី ដែលមានផលប្រយោជន៏ដល់សេដ្ឋកិច្ចជួយបំពេញតំរូវការក្នុងសហគមន៏ទាំងសំរាប់អ្នកមាន និងអ្នកក្រ និងគោរពដល់បរិស្ថាន នឹងសីលធម៌ជាកេរ្តិ៍ដំណែលរបស់កម្ពុជា?

ប្រជាពលរដ្ឋកម្ពុជា ត្រូវធ្វើការរួមគ្នាដើម្បីរកដំណោះស្រាយខាងគោលនយោបាយ និងកំណត់សកម្មភាពពាក់ព័ន្ធនឹងបញ្ហាទាំងឡាយដូចខាងលើ ។ ដីធ្លីជាធនធានសេដ្ឋកិច្ចដ៏សំខាន់ ជាប្រភពនៃសន្តិសុខ សុខមាលភាព និងអត្តសញ្ញាណ ។ ក្រៅពីនេះ ដីធ្លីនៅមានផលប្រយោជន៏ជាក់ស្តែងជាច្រើនទៀត ទោះបីជាលក្ខណៈអរូបីក្តី វាមានសារៈសំខាន់ជាខ្លាំងសំរាប់គ្រប់សហគមន៏ និងគ្រប់ប្រជាជាតិ ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០២-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 4.8 | 7 | 7.7 | 13.4 | 10.6 | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 3.8 | 4.9 | 5.1 | 5.6 | 5.4 | 6.1 | - | - | - | 6.3 |
| ម៉ាឡេស៊ី | 5.6 | 5.4 | 7 | 5.2 | 5.9 | 5.7 | 5.3 | 5.7 | 6.7 | 7.3 |
| សិង្ហបុរី | 2.6 | 1.4 | 8.5 | 5.7 | 7.7 | 7.0 | 6.0 | 8.2 | 8.9 | 6.0 |
| ថៃ | 6.1 | 6.9 | 6 | 4.5 | 4.8 | 4.2 | 4.3 | 4.4 | 4.8 | 5.7 |
| វៀតណាម | 6.7 | 7 | 7.5 | 8.4 | 8.1 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.1 | 9.9 | 9.5 | 9.6 | 10.5 | 10.7 | 11.1 | 11.5 | 11.4 | 11.2 |
| ហុងកុង | 5.0 | 3.2 | 8.3 | 6.5 | 6.6 | 7.0 | 5.6 | 6.9 | 6.2 | 6.7 |
| កូរ៉េខាងត្បូង | 6.1 | 3 | 4.7 | 4.7 | 5.0 | 5.0 | 4.0 | 4.5 | 5.2 | 5.7 |
| តៃវ៉ាន់ | 4.2 | 3.1 | 5.7 | 4.1 | 4.6 | 4.0 | 4.1 | 5.07 | 6.9 | 6.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.7 | 0.5 | 1.8 | 1.5 | 2.7 | 3.3 | 3.0 | 2.5 | 2.7 | 2.2 |
| ជប៉ុន | 0.4 | 2.6 | 3.4 | 2.5 | 2.1 | 2.3 | 2.2 | 2.3 | 1.9 | 2.0 |
| សហរដ្ឋអាមេរិក | 2.4 | 3.1 | 4.4 | 3.7 | 3.3 | 3.1 | 1.5 | 3.8 | 4.9 | 2.5 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០២-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | 2007 | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 3.2 | 1.2 | 4.0 | 5.8 | 4.7 | 3.4 | 3.0 | 4.6 | 6.0 | 9.6 |
| ឥណ្ឌូនេស៊ី | 13.2 | 8.3 | 8.3 | 10.5 | 13.4 | 6.1 | 6.4 | 6.0 | 6.5 | 6.7 |
| ម៉ាឡេស៊ី | 1.8 | 1.1 | 1.6 | 3.1 | 3.7 | 3.1 | 2.6 | 1.4 | 1.8 | 2.2 |
| សិង្ហបុរី | -0.4 | 0.5 | 1.7 | 0.5 | 1.0 | 0.6 | 0.5 | 1.0 | 2.7 | 4.1 |
| ថៃ | 0.6 | 1.8 | 2.7 | 4.5 | 4.7 | 3.3 | 2.4 | 1.9 | 1.7 | 2.9 |
| វៀតណាម | 3.8 | 3.1 | 7.8 | 8.2 | 7.7 | - | 6.6 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | -0.7 | 1.2 | 3.9 | 1.8 | 1.5 | 1.8 | 2.6 | 3.6 | 6.1 | 6.6 |
| ហុងកុង | -3.0 | -2.6 | -0.4 | 1.1 | 2.2 | 2.2 | 1.7 | 1.3 | 1.6 | 3.5 |
| កូរ៉េខាងត្បូង | 2.7 | 3.5 | 3.5 | 2.8 | 2.4 | 2.4 | 2.0 | 2.4 | 2.3 | 3.3 |
| តៃវ៉ាន់ | -0.2 | -0.3 | 1.6 | 2.3 | 0.6 | -0.1 | 1.0 | 0.3 | 1.4 | 4.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | 0.0 | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.1 | 2.2 | 2.2 | 2.1 | 1.8 | 1.9 | 1.9 | 1.9 | 2.9 |
| ជប៉ុន | -0.9 | -0.3 | Nil | -0.3 | 0.5 | 0.3 | -0.1 | -0.1 | -0.1 | 0.5 |
| សហរដ្ឋអាមេរិក | 1.6 | 2.3 | 2.7 | 3.4 | 3.2 | 1.9 | 2.4 | 2.7 | 2.4 | 3.9 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០២-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | 2007 | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3912.1 | 3973 | 4016.3 | 4092.5 | 4103.2 | 4111.3 | 4046.7 | 4065.7 | 4078 | 4026 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9311 | 8577 | 8938 | 9705 | 9134 | 9125 | 9107 | 8968.3 | 9257.8 | 9240.2 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.79 | 3.67 | 3.62 | 3.50 | 3.43 | 3.46 | 3.35 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.74 | 1.69 | 1.66 | 1.59 | 1.56 | 1.53 | 1.52 | 1.52 | 1.45 |
| ថៃ (បាត) | 42.9 | 41.5 | 40.2 | 40.2 | 37.9 | 36.5 | 33.9 | 32.5 | 31.4 | 33.87 |
| វៀតណាម (ដុង) | 15,280 | 15,510 | - | 15,859 | 15,994 | 16,077 | 16,356 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.19 | 7.97 | 7.86 | 7.76 | 7.68 | 7.55 | 7.43 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.78 | 7.79 | 7.78 | 7.77 | 7.78 | 7.81 | 7.82 | 7.81 | 7.77 |
| កូរ៉េខាងត្បូង (វ៉ុន) | 1251 | 1192 | 1145 | 1024 | 955 | 938 | 939 | 929 | 927 | 921.23 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 34.5 | 34.4 | 33.6 | 32.1 | 32.5 | 32.8 | 32.9 | 33.1 | 32.9 | 32.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.06 | 0.89 | 0.80 | 0.80 | 0.80 | 0.78 | 0.76 | 0.74 | 0.73 | 0.69 |
| ជប៉ុន (យ៉េន) | 125.4 | 115.9 | 108.2 | 110.2 | 116.4 | 117.8 | 119.4 | 120.8 | 117.7 | 113.07 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០២-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No. 2) - US ($/តោន) | 89.98 | 95.42 | 110.65 | 89.19 | 111.04 | 140.18 | 154.33 | 146.10 | 139.81 | 156.9 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 353.91 | 402.03 | 427.47 | 381.32 | 433.85 | 494.92 | 552.06 | 691.44 | 745.86 | 841.39 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 178.59 | 182.22 | 221.67 | 262.88 | 282.00 | 279.10 | 294.17 | 283.89 | 304.75 | 323.92 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 182.58 | 218.86 | 262.03 | 224.25 | 213.88 | 230.17 | 255.33 | 259.95 | 299.99 | 366.59 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 23.9 | 26.8 | 33.5 | 50.14 | 61.58 | 56.39 | 54.21 | 65.41 | 72.48 | 82.88 |
| សាំង - US Gulf Coast (សេន/លីត្រ) | 19.1 | 23 | 30.9 | 42.19 | 47.70 | 41.02 | 41.71 | 57.93 | 55.49 | 59.48 |
| មាស៊ូត (ស្តង់ដារតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 17.85 | 21.63 | 29.48 | 44.35 | 51.35 | 46.11 | 45.61 | 53.90 | 56.62 | 66.54 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៤ ឆ្នាំ២០០៧ វិនិយោគនៅកម្ពុជាធ្លាក់ចុះប្រហែល ៤០% ធៀបនឹងត្រីមាសមុន មកត្រឹម ៧៤១,៥លានដុល្លារ ។ អនុមតិលើកសិកម្មមានតំលៃ ១០២,៤លានដុល្លារ រឺច្រើនជាងត្រីមាសមុន ៨ដង ។ អនុមតិលើវិស័យឧស្សាហកម្ម កើនឡើងជិតមួយជាពីរ ដល់ ៣២៨,០លានដុល្លារ រីឯអនុមតិលើសេវាកម្មមានតំលៃ ៣១១,១លានដុល្លារ រឺថយចុះ ៦៨% ។ ក្នុងអនុមតិសំរាប់ឧស្សាហកម្មទាំងអស់ មាន ៦៣% ខាងកែច្នៃម្ហូបអាហារ និង ២១% ខាងកាត់ដេរ ។ អនុមតិខាងកាត់ដេរគិតជាទ្រព្យសកម្មជាប់លាប់ កើន ៧០% ធៀបនឹងត្រីមាសមុន ។ ក្នុងគំរោងអនុម័តនៅត្រីមាសទី៤ អនុវិស័យកាត់ដេរ បង្កើតការងារថ្មីបានច្រើនជាងគេ គឺសំរាប់ ៣១.៤៩២នាក់ ។ ចំពោះវិស័យសេវាកម្ម អនុមតិទេសចរណ៏ មានតំលៃ ១១១,៨លានដុល្លារ រឺថយចុះ ៧០% ធៀបនឹងត្រីមាសមុន ។ គំរោងទេសចរណ៏ដែលបានអនុម័ត នឹងត្រូវការបុគ្គលិកថ្មី ៤៦៨៥នាក់ រីឯអនុមតិលើវិស័យកសិកម្មនឹងប្រើប្រាស់ពលករដល់ទៅ ៤២៨១នាក់ ។

នៅត្រីមាសទី៤ ឆ្នាំ២០០៧ អនុមតិសាងសង់មានតំលៃ ១៧២,២លានដុល្លារ រឺថយចុះ ៤,២% ធៀបនឹងត្រីមាសមុន ។ អនុមតិភូមិគ្រឹះនិងផ្ទះ ធ្លាក់ចុះ ៦,៨% មកត្រឹម ២០,២លានដុល្លារ ហើយអនុមតិសំណង់ផ្ទះល្វែង ថយចុះ ៥១% មកត្រឹម ៥៧,៦លានដុល្លារ ។ ផ្ទុយទៅវិញ ក្នុងឆ្នាំ២០០៧ អនុមតិសាងសាង់ទាំងអស់ បានកើនឡើងជិតមួយជាពីរ ធៀបនឹងឆ្នាំ២០០៦ ដល់ ៦៣៥,៨លានដុល្លារ ។ សំណង់ភូមិគ្រឹះ និងផ្ទះ កើនឡើងជាងពីរដងដល់ ៧៥,១លានដុល្លារ ហើយសំណង់ផ្ទះល្វែង កើន ៤៥% ធៀបនឹងឆ្នាំមុន ដល់ ២៩៧,២លានដុល្លារ ។

នៅត្រីមាសទី៤ ឆ្នាំ២០០៧ អតិរេកពាណិជ្ជកម្មកើនខ្ពស់ជាងត្រីមាសមុន ដោយឡើងដល់ ១៨៩,៣លានដុល្លារ ។ ការនាំចេញសរុប ធ្លាក់ចុះ ១១% មកត្រឹម ៧៩៣,៤លានដុល្លារ ។ ការនាំចេញសំលៀកបំពាក់ ថយចុះ ១៤% មកត្រឹម ៧២៧,១លានដុល្លារ ។ ការនាំចេញត្រី ថយចុះ ២១% មកត្រឹម ០,៩លានដុល្លារ រីឯការនាំចេញកៅស៊ូ កើន ២៥% ដល់ ១៤,៦លានដុល្លារ ។ បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០០៦ ការនាំចេញសរុប កើន ៧,៧% ។ ការនាំចូលកើន ៦,៣% ធៀបនឹងត្រីមាសមុន ដល់ ៥៨២,៧លានដុល្លារ ។ ក្នុងនេះការនាំចូលបារី ថយចុះ ១,៥% មកត្រឹម ២៧,៥លានដុល្លារ រីឯការនាំចូលគ្រឿងសំណង់ ថយចុះ ៦,៩% មកត្រឹម ៣២,៥លានដុល្លារ ។ ការនាំចូលស៊ីម៉ង់ត៍ ធ្លាក់ចុះ ១៨% មកត្រឹម ១២,១លានដុល្លារ ហើយការនាំចូលដែក ថយចុះ ២២% មកត្រឹម ៩,៣លានដុល្លារ ។ ការនាំចូលផលិតផលប្រេង ថយចុះ ១៨% មកត្រឹម ៥៨,៩លានដុល្លារ ប៉ុន្តែកើន ០,៣% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០០៦ ។

នៅត្រីមាសទី៤ ឆ្នាំ២០០៧ ភ្ញៀវទេសចរមកដល់កម្ពុជា កើនឡើង ៤២% ធៀបនឹងត្រីមាសមុន ដល់ ៦០៧.៥៦៤នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាសមាន ៦១% នៃចំនួនភ្ញៀវមកដល់សរុប ហើយក្នុងនោះអាកាសយានដ្ឋានភ្នំពេញទទួលបាន ១៥៣.៧៤៣នាក់ ។ ភ្ញៀវមកដល់តាមផ្លូវគោកតំណាងអោយ ៣៧% នៃភ្ញៀវមកដល់សរុប ហើយនៅសល់ពីនោះគឺមកដល់តាមផ្លូវទឹក ។ ភ្ញៀវមកសំរាកលំហែ កើន ៣២% ដល់ ៤៨០.៥៦៣នាក់ រឺ កើន ១៣% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០០៦ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ ឆ្នាំ២០០៧ ប្រតិបត្តិការថវិកាជាតិ មានឱនភាព ២០៤,០ពាន់លានរៀល គឺខ្ពស់ជាងត្រីមាសមុន ដែលមានត្រឹម៧៨,៧ពាន់លានរៀល ។ ចំណូលសរុប កើនឡើង ១១% ដល់ ១១៤១,៨ពាន់លានរៀល ដោយបានជាសំខាន់មកពីចំណូលពន្ធ ដែលកើនឡើង ១៤% ដល់ ៩៦៣,៧ពាន់លានរៀល ។ ចំណូលពន្ធក្នុងស្រុកមាន ៦៩% នៃចំណូលពន្ធសរុប រីឯចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសមាន ៣១% ។ ចំណូលមិនមែនពន្ធ ថយចុះ ៧,២% មកត្រឹម ១៧៣,៥ពាន់លានរៀល ។ ចំណូលបានពីអចលទ្រព្យដូចជា ការជួលដីរដ្ឋ និងចំណូលពីសហគ្រាសរដ្ឋ ធ្លាក់ចុះ ៨,១% មកត្រឹម ១៣,៦ពាន់លានរៀល ។ ការលក់ទំនិញ និងសេវា (ដូចជា ការអនុញ្ញាតអោយលក់ដូរ កំរៃរដ្ឋបាល ចំណូលបានមកពីវិនិយោគ និងពន្ធព្រលានយន្តហោះ) កើនឡើង ២២% ដល់ ១២២,៦ពាន់លានរៀល ។ ចំណូលមូលធន បានមកពីការវិនិយោគហិរញ្ញវត្ថុគឺ ៤,៥ពាន់លានរៀល ប្រៀបធៀបនឹងចំណូលសូន្យនៅត្រីមាសមុន ។

ចំណាយសរុប កើនឡើងប្រហែល ២០% ធៀបនឹងត្រីមាសមុន ដល់ ១៣៤៥,៨ពាន់លានរៀល ។ ចំណាយលើប្រាក់បៀវត្សរ៍ កើនឡើង ៤៣% ដល់៣៦២,៦ពាន់លានរៀល ហើយឧបត្ថម្ភធនរបស់រដ្ឋាភិបាល និងជំនួយសង្គមកិច្ច កើនឡើង ៦៥% ដល់ ១៩៤,២ពាន់លានរៀល ។ ការយកកំរៃខាងហិរញ្ញវត្ថុគឺ ២៧,០ពាន់លានរៀល ក្នុងនោះ ការប្រាក់លើបំណុលក្រៅប្រទេសមានចំនួន ១៦,០ពាន់លានរៀល ។ ចំណាយមូលធន កើនឡើង ៣០% ដល់ ៤៦៣,៤ពាន់លានរៀល ។ ការផ្តល់ហិរញ្ញប្បទានក្នុងស្រុកមាន ១៦០,២ពាន់លានរៀល ហើយការផ្តល់ហិរញ្ញប្បទានពីក្រៅប្រទេសមានចំនួន ៣០៣,២ពាន់លានរៀល ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០០៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុប កើន ១៥,៩% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០០៦ ។ ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រាមាន ៥៨,០៤% នៃចំណាយលើការរស់នៅសរុប និងកើនឡើង ២១,៧% ។ ចំណាយលើការស្នាក់នៅ ទឹកភ្លើង ឧស្ម័ន និងឥន្ទនៈផ្សេងៗទៀត កើន ១១,៥% ការថែទាំសុខភាព កើន ១០,៨% ការដឹកជញ្ជូន កើន ៥,៣% រីឯចំណាយលើទូរគមនាគមន៍ ធ្លាក់ចុះ ១៦,៨% ។

នៅពេលដែលថ្លៃទំនិញស្ទើរតែគ្រប់មុខកើនឡើង ប្រាក់រៀលបានឡើងថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ៤០៣០,១ រៀល/ដុល្លារUS រឺឡើងថ្លៃ ១,៣% ធៀបនឹងត្រីមាសមុន និងឡើងថ្លៃ ២,៤% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០០៦ ។ ទល់នឹងប្រាក់បាតថៃ ប្រាក់រៀលឡើងថ្លៃ ០,៥% ដល់ ១២៥,៣រៀល/បាត ហើយទល់នឹងប្រាក់ដុងវៀតណាម វាប្តូរបាន ២៥,២ រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

នៅចុងខែធ្នូ ២០០៧ រូបិយវត្ថុទូទៅ (M2) មាន ១១៣១០,៧ពាន់លានរៀល រឺកើនជិត ៦៣% ធៀបនឹងចុងខែធ្នូ ២០០៦ ។ រូបិយវត្ថុ (M1) កើនដល់ ២០៥២,០ពាន់លានរៀល ក្នុងនោះប្រាក់រៀលចរាចរមាន ៩៧% និង

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ប្រាក់បញ្ញើចរន្ត ៣% ។ រូបិយវត្ថុផ្សេងៗ ដែលរួមមាន ប្រាក់បញ្ញើសន្សំ ប្រាក់បញ្ញើមានកាលកំណត់ និងប្រាក់បញ្ញើជារូបិយវត្ថុបរទេស កើន ៧៥% ដល់ ៩២៥៨,៧ពាន់លានរៀល ។ ក្នុងពេលជាមួយគ្នា ប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ៧៦% ដល់ ៩១៣៧,៧ពាន់លានរៀល ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធ បានរួមចំណែកដល់កំណើនរូបិយវត្ថុទូទៅ ។ នៅខែធ្នូ ២០០៧ ទ្រព្យសកម្មក្នុងស្រុកសុទ្ធមានតួលេខវិជ្ជមាន ៩៧៦,០ពាន់លានរៀល ។ ឥណទានក្នុងស្រុកមាន ៤៩៧០,០ពាន់លានរៀល រឺកើន ៧១% ធៀបនឹងពេលដូចគ្នាឆ្នាំ២០០៦ ។ ឥណទានរដ្ឋាភិបាលកើន ៣,៦% ដល់ ២៩៧,០ពាន់លានរៀល ហើយ ឥណទានដល់វិស័យឯកជនកើន ៧៦% ដល់ ៦៣៨៦,០ពាន់លានរៀល ។ ម្យ៉ាងទៀត ប្រាក់បញ្ញើរដ្ឋាភិបាល កើន ៧០% ដល់ ២១១២,៩ពាន់លានរៀល និងបំណុលធនាគារផ្សេងៗ កើន ៣៥% ដល់ ៣៩៩៤,១ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៤៥% ដល់ ១០៧៣៤,៧ពាន់លានរៀល នៅចុងខែធ្នូ ២០០៧ ។

*រៀបរៀងដោយ*
*ផាន់ ដាលីស និងប៉ុន ដូរីណា*

*តពីទំព័រ ១១* **ការទាញយកប្រយោជន៍ ...**

ដើម្បីផ្ដល់ព័ត៌មានអោយសិស្ស-និស្សិត ក្រុមគ្រួសារ និងនិយោជកព្រមទាំងផ្លាស់ប្ដូរទស្សនៈសាធារណជនដែលថាសញ្ញាប័ត្រឧត្តមសិក្សា ជាមធ្យោបាយតែមួយដើម្បីរកបានការងារល្អ ហើយការអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ/បច្ចេកទេស គឺសំរាប់តែការងារថ្នាក់ទាប ។ អ្នកបច្ចេកទេស និងវិស្វករ គឺជាកំលាំងពលកម្មជំនាញ ជំរុញសេដ្ឋកិច្ចសិង្ហបុរី និងកូរ៉េខាងត្បូង ហើយពលករទាំងនោះអាចរកប្រាក់ចំណូលបានយ៉ាងច្រើន និងមានអនាគតការងារល្អទៀតផង ។

ដើម្បីឆ្លើយតបនឹងបំរែបំរួលតំរូវការទីផ្សារពលកម្ម ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចង់ជួយក្នុងការងារសំរបតាមការផ្លាស់ប្ដូរ ការកសាងភាពជាដៃគូជាមួយសហគ្រាសនិងអ្នកសិក្សា (ការបែងចែកបន្ទុកចំណាយ) និងការបន្តប្រើប្រាស់ការអភិវឌ្ឍជំនាញដើម្បីកាត់បន្ថយភាពក្រីក្រ។ ម្យ៉ាងទៀត ក្រសួងជួយកែលំអផលិតភាព/ការគ្រប់គ្រង តាមរយៈការអភិវឌ្ឍជំនាញ ការបង្កើនកំរិតប្រើប្រាស់សមត្ថភាព និងការកាត់បន្ថយថ្លៃដើមជាមធ្យមក្នុងរោងចក្រ ។ ក្រសួងក៏នឹងបង្កើតស្តង់ដារសមត្ថភាពស្របតាមតំរូវការសហគ្រាស (ការបណ្ដុះបណ្ដាលដែលនាំអោយមានការងារធ្វើ និងការទទួលស្គាល់) និងបង្កើតទីភ្នាក់ងាររកការងារអោយធ្វើថ្នាក់ជាតិមួយ (ដើម្បីកែលំអដំណើរការទីផ្សារពលកម្ម) ព្រមទាំងបង្កើនសកម្មភាពវិស័យសាធារណៈក្នុងការអប់រំនិងបណ្ដុះបណ្ដាលជំនាញ/បច្ចេកទេស ដើម្បីបណ្ដុះបណ្ដាលអ្នកបច្ចេកទេស និងវិស្វករ ។ ម្យ៉ាងទៀត ក្រសួងនឹងជំរុញអោយនិយោជកផ្ដល់ការអប់រំនិងបណ្ដុះបណ្ដាលជំនាញ/បច្ចេកទេស កាន់តែច្រើន ផ្ដល់ការគាំទ្រ ដើម្បីបង្កើនគុណភាពវិទ្យាស្ថានបណ្ដុះបណ្ដាលឯកជន តាមរយៈបណ្ដាញជាតិមួយនៃអ្នកអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ/បច្ចេកទេស ព្រមទាំងផ្លាស់ប្ដូរការយល់ឃើញរបស់យុវជន និងអាណាព្យាបាលពួកគេ លើការអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ/បច្ចេកទេស ។

*តពីទំព័រ ១៤* **ប្រទេសកម្ពុជា ឆ្នាំ២០០៨ និង ...**

- យន្តការជំរុញការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងអាជីវករ និងរដ្ឋាភិបាល មិនអាចបន្តដឹកនាំដោយអ្នកផ្ដល់ជំនួយទេ គឺចាំបាច់ត្រូវតែឯករាជ្យ ។ ជំរើសមួយដែលបានលើកឡើង គឺការពង្រឹងសភាពាណិជ្ជកម្មកម្ពុជា ទោះបីនាពេលសព្វថ្ងៃ សភាពាណិជ្ជកម្មកម្ពុជាមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញតួនាទីជាអ្នកដឹកនាំបែបនេះក្ដី ។ ជំរើសលើកស្នើមួយទៀត គឺការពង្រឹងក្រុមការងារវិស័យឯកជនទាំង៨ ដោយមានគោលដៅយូរអង្វែង ដាក់គួបបញ្ចូលគ្នាទាំងអស់អោយក្លាយជាការិយាល័យឯករាជ្យមួយ ។
- វិសហមជ្ឈការចំពោះថ្នាក់ខេត្ត ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរវាងរដ្ឋ-អាជីវករ ហើយការបង្កើតវេទិកាថ្នាក់តំបន់ ដែលសំខាន់ណាស់ដែរ សំរាប់បរិយាកាសអាជីវកម្មតាមតំបន់កាន់តែរឹងមាំ ។
- បញ្ហាប្រឈមចំពោះការអភិវឌ្ឍវិស័យឯកជន ត្រូវបានដោះស្រាយលើទិដ្ឋភាពពីរផ្សេងគ្នា ។ ទិដ្ឋភាពទីមួយផ្ដោតលើ រង្វាស់ជាក់ស្តែងមួយចំនួនដូចជា សមាហរណកម្មទីផ្សារក្នុងតំបន់ និងការកាត់បន្ថយថ្លៃដើមផលិតកម្ម ។ ទិដ្ឋភាពទីពីរ ការនៅសេសសល់បញ្ហាប្រឈមខាងអភិបាលកិច្ចដែលប៉ះពាល់ដល់វិស័យឯកជន និងសមត្ថភាពធ្វើអាជីវកម្មរបស់វិស័យនេះ ។
- បញ្ហាប្រឈមខាងអភិបាលកិច្ចសំរាប់ការអភិវឌ្ឍវិស័យឯកជន រួមមានការលំបាកផ្សេងៗ ទាក់ទិននឹងសិទ្ធិកាន់កាប់អចលនទ្រព្យ និងការពង្រឹងអនុវត្តន៍កិច្ចសន្យា ។ ការវិវត្តជាវិជ្ជមានក៏មានមួយចំនួនដែរ ដូចជាវិមជ្ឈការនិងការផ្ទេរអំណាចធ្វើផែនការ កំណែទំរង់ហិរញ្ញវត្ថុសាធារណៈ និង របៀបរបបធ្វើជាដៃគូរវាងវិស័យឯកជននិងរដ្ឋ ។និន្នាការសំខាន់មួយដែលទើបផុសឡើង គឺកំណើនអ្នកដឹកនាំសហគ្រាសអាជីវកម្ម និងអ្នកឋានៈខ្ពស់ថ្មីៗដែលទំនងជានឹងស្នើសុំកំណែទំរង់ប្រភេទខ្លះទៀត ហើយអាចជួយរួមចំណែកដល់អភិបាលកិច្ចល្អ ។
- ឱកាសល្អទើបផុសឡើងមួយដែលមិនទាន់បានស្រាវជ្រាវច្រើន គឺការយករ៉ែ ។ បច្ចុប្បន្នទ្វីបអាស៊ីកំពុងជំរុញឡើងនូវតំរូវការរ៉ែ ហើយក៏មានឱកាសល្អច្រើនដែរ ដើម្បីបង្កើតអណ្ដូងរ៉ែ និងផ្គត់ផ្គង់ផលិតផលរ៉ែដល់ប្រទេសនានានៅអាស៊ី ។ ប្រសិនបើគំរោងនានាអនុវត្តឡើងដោយមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខាងសង្គមកិច្ច និងបរិស្ថាន កម្ពុជាពិតជាមានសក្ដានុពលច្រើន ដើម្បីទទួលបានផលចំណេញជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការកសាងសមត្ថភាព និងការកាត់បន្ថយភាពក្រីក្រ ។ ប៉ុន្តែទាំងអស់នេះកំពុងស្ថិតក្នុងដំណាក់កាលស្រាវជ្រាវនៅឡើយទេ ។

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០២-២០០៧

| | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 40.3 | 3.7 | 12.3 | 26.8 | 126.5 | 216.9 | 0.0 | 154.6 | 19.1 | 2.1 | 12.0 | 102.4 |
| ឧស្សាហកម្ម | 67.7 | 137.2 | 187.9 | 914.6 | 40.1 | 76.9 | 171.7 | 76.6 | 142.7 | 51.2 | 187.2 | 328.0 |
| *កាត់ដេរ* | *27.2* | *68.1* | *132.6* | *174.4* | *30.5* | *9.6* | *23.2* | *26.1* | *36.6* | *24.3* | *40.7* | *69.1* |
| សេវាកម្ម | 145.3 | 168.4 | 91.8 | 155.5 | 60.7 | 2,043.2 | 94.5 | 740.7 | 335.7 | 138.0 | 957.7 | 311.1 |
| *សណ្ឋាគារ និងទេសចរណ៍* | *47.1* | *124.1* | *55.9* | *102.6* | *0.0* | *26.2* | *3.5* | *315.3* | *140.3* | *55.0* | *653.8* | 199.2 |
| សរុប | 253.3 | 309.3 | 292.0 | 1096.9 | 227.3 | 2,337.0 | 266.2 | 971.9 | 497.5 | 191.3 | 1156.9 | 741.5 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 90.7 | 928.1 | -88.6 | 265.1 | -48.8 | -61.6 | 504.7 | -35.9 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 13.1 | 22.1 | -5.6 | 275.6 | -52.2 | 2331.2 | -34.1 | 715.4 | 118.9 | 91.8 | 334.6 | -23.7 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០២-២០០៧

| | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 23.4 | 20.0 | 30.3 | 45.5 | 10.1 | 5.7 | 7.6 | 9.7 | 14.4 | 22.8 | 21.7 | 20.2 |
| ផ្ទះល្វែង | 179.9 | 91.6 | 167.6 | 204.2 | 39.9 | 51.8 | 67.1 | 54.5 | 88.9 | 33.2 | 117.5 | 57.6 |
| ផ្សេងៗ | 16.6 | 87.3 | 65.6 | 109.1 | 17.4 | 24.7 | 20.8 | 13.9 | 35.9 | 88.8 | 40.6 | 94.3 |
| សរុប | 219.9 | 198.9 | 263.5 | 358.8 | 67.4 | 82.2 | 95.5 | 78.2 | 139.2 | 144.7 | 179.7 | 172.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -6.2 | 22.2 | 16.1 | -18.1 | 78.0 | 3.9 | 24.2 | -4.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 12.0 | -9.5 | 32.5 | 36.2 | -36.5 | -21.2 | 24.8 | 8.9 | 106.5 | 76.0 | 88.2 | 120.2 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ២០០២-២០០៧

| | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 1453.2 | 1708.1 | 2108.1 | 2352.8 | 603.2 | 652.5 | 807.5 | 736.7 | 707.8 | 705.0 | 890.8 | 793.4 |
| រួមមាន: សំលៀកបំពាក់ | 1355.8 | 1628.4 | 2027 | 2253.3 | 568.5 | 632.4 | 782.0 | 716.0 | 677.5 | 688.2 | 846.1 | 727.1 |
| *- ទៅសហរដ្ឋអាមេរិក* | *943.4* | *1099.8* | *1270.9* | *1546.1* | *402.5* | *438.6* | *522.8* | *483.2* | *499.1* | *451.2* | - | - |
| *- ទៅសហគមន៍អ៊ឺរ៉ុប* | *356.3* | *414.7* | *590.8* | *503.1* | *110.6* | *142.2* | *188.1* | *160.1* | *106.3* | *163.1* | - | - |
| *- ប្រទេសផ្សេងទៀត* | *56.1* | *113.8* | *165.3* | *204.1* | *55.3* | *51.6* | *71.0* | *72.8* | *72.0* | *73.8* | - | - |
| កសិកម្ម | 97.3 | 79.7 | 81.2 | 99.5 | 34.7 | 20.2 | 25.5 | 20.7 | 30.3 | 16.8 | - | - |
| *- កៅស៊ូ* | *29.7* | *35.1* | *38.3* | 36.7 | 7.8 | 9.8 | 13.6 | 10.2 | 8.4 | 6.9 | 11.7 | 14.6 |
| *- ឈើ* | *16.0* | *10.2* | *11.1* | 10.3 | 2.1 | 2.3 | 2.5 | 1.7 | 2.1 | 2.0 | 0.0 | 0.0 |
| *- ត្រី* | *4.3* | *2.8* | *10.6* | 10.1 | 1.9 | 1.0 | 1.6 | 1.4 | 0.7 | 0.4 | 1.2 | 0.9 |
| *- ផ្សេងៗ* | *47.4* | *31.6* | *21.3* | 42.6 | 22.9 | 7.0 | 7.7 | 7.5 | 19.0 | 7.5 | - | - |
| ការនាំចូលសរុប | 1707.8 | 1824.9 | 2149.0 | 2513 | 690.7 | 774.9 | 784.3 | 807.1 | 790.9 | 911.6 | 924.5 | 982.7 |
| រួមមាន: ផលិតផលប្រេងកាត | 157.5 | 191.6 | 187.0 | 184.8 | 57.6 | 59.8 | 62.4 | 58.7 | 66.5 | 68.5 | 71.0 | 58.9 |
| សាំង | *25.9* | *33.2* | *30.2* | *40.2* | *10.9* | *12.4* | *13.1* | *13.2* | *15.7* | *20.2* | - | - |
| ម៉ាស៊ូត | *100.8* | *109.6* | *109.4* | *93.1* | *32.5* | *32.2* | *30.1* | *27.2* | *31.9* | *36.6* | - | - |
| សំភារៈសំណង់ | 12.9 | 80.8 | 95.3 | 134.7 | 37.0 | 39.1 | 42.5 | 35.8 | 44.1 | 31.6* | 34.9 | 32.5 |
| ផ្សេងៗ | 1568.2 | 1601.3 | 1914.0 | 2245 | 610.3 | 691.2 | 698.5 | 731.0 | 699.2 | 807.5 | 818.6 | 891.3 |
| ជញ្ជីងពាណិជ្ជកម្ម | -254.6 | -116.8 | -40.9 | -160.1 | -87.5 | -122.4 | 23.2 | -70.4 | -83.1 | -208.1 | -30.7 | -189.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | -5.4 | 39.8 | -118.9 | -403.4 | 18.0 | 150.4 | -85.2 | -14.1 |
| ការនាំចេញសរុប | - | - | - | - | -6.4 | 8.2 | 23.7 | -8.8 | -3.9 | 0.4 | 26.4 | -10.9 |
| ការនាំចូលសរុប | - | - | - | - | -0.03 | 12.2 | 1.2 | 2.9 | -2.0 | 15.3 | 1.4 | 6.3 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 9.2 | -54.1 | -64.9 | 291.4 | 51.1 | -19.5 | -76.2 | 52.0 | -5.0 | 70.0 | -232.3 | 1.6 |
| ការនាំចេញសរុប | 14.6 | 17.5 | 23.4 | 11.6 | 30.3 | 26.7 | 10.6 | 14.3 | 17.3 | 8.0 | 10.3 | 7.7 |
| ការនាំចូលសរុប | 13.7 | 6.9 | 17.8 | 16.9 | 32.6 | 16.2 | 24.0 | 16.8 | 14.5 | 17.6 | 17.9 | 21.7 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by NBC*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០២-២០០៧

| | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 523.0 | 456.0 | 626.1 | 856.5 | 275.4 | 204.4 | 224.2 | 325.0 | 373.6 | 275.6 | 278.5 | 368.8 |
| តាមផ្លូវគោក និងទឹក | 263.5 | 245.0 | 428.9 | 565.1 | 181.9 | 153.6 | 146.4 | 191.0 | 177.2 | 148.9 | 153.3 | 239.2 |
| សរុប | 786.5 | 701.1 | 1055.0 | 1421.6 | 457.3 | 358.0 | 370.6 | 516.0 | 550.8 | 424.5 | 431.8 | 608.0 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 9.9 | -21.7 | 4.1 | 39.2 | 6.7 | -22.9 | 1.7 | 40.8 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 30.0 | -10.9 | 50.5 | 34.7 | 20.2 | 21.2 | 14.7 | 24.1 | 20.4 | 19.2 | 16.5 | 17.8 |

*Source: Ministry of Tourism*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០២-២០០៧ (ពាន់លានរៀល)

| | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1744 | 1764 | 2126 | 2625 | 595.9 | 731.5 | 732.2 | 1199.6 | 824.9 | 1016.8 | 1031.4 | 1141.8 |
| ចំណូលចរន្ត | 1728 | 1733 | 2107 | 2474 | 593.2 | 726.9 | 716.8 | 844.9 | 824.9 | 1012.4 | 1031.4 | 1110.3 |
| ចំណូលពន្ធ | 1227 | 1220 | 1577 | 1911 | 484.7 | 558.6 | 565.8 | 661.8 | 699.9 | 887.7 | 844.6 | 963.7 |
| ពន្ធគយ | 424 | 395 | 513 | 573 | 135.5 | 151.7 | 157.2 | 200.0 | - | - | - | - |
| ពន្ធក្នុងស្រុក | - | - | - | - | - | - | - | - | 487.9 | 642.1 | 584.8 | 660.7 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | - | - | 212.1 | 245.6 | 259.8 | 303.0 |
| ចំណូលមិនមែនពន្ធ | 501 | 513 | 530 | 563 | 108.5 | 168.3 | 151.0 | 183.1 | 125.0 | 124.7 | 186.9 | 173.5 |
| អាជីវកម្មព្រៃឈើ | 15 | 7 | 2 | 3 | 0.5 | 0.7 | 0.3 | 0.9 | - | - | - | - |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 123 | 120 | 94 | 123 | 11.4 | 30.0 | 11.7 | 30.0 | - | - | - | - |
| ចំណូលលើអចលនទ្រព្យ | - | - | - | - | - | - | - | - | 27.9 | 15.5 | 14.8 | 13.6 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | - | - | 88.8 | 93.0 | 100.1 | 122.6 |
| ចំណូលជាមូលធន | 16 | 31 | 19 | 152 | 2.7 | 4.6 | 15.4 | 354.7 | 0.0 | 4.5 | 0.0 | 4.5 |
| ចំណាយសរុប | 2948 | 2757 | 2932 | 3295 | 932.1 | 1020.1 | 1030.6 | 1191.9 | 923.9 | 1098.7 | 1126.1 | 1345.8 |
| ចំណាយជាមូលធន | 1388 | 1171 | 1163 | 1328 | 390.5 | 394.7 | 423.8 | 429.1 | 367.1 | 408.1 | 355.1 | 463.3 |
| ចំណាយចរន្ត | 1560 | 1586 | 1769 | 1967 | 541.7 | 625.4 | 606.9 | 762.8 | 556.8 | 681.6 | 771.0 | 882.5 |
| អប់រំ និងសុខាភិបាល | 454 | 473 | 518 | 351 | 80.3 | 202.3 | 150.1 | 281.3 | - | - | - | - |
| ការពារជាតិ និងសន្តិសុខជាតិ | 438 | 411 | 423 | 451 | 78.1 | 116.7 | 155.3 | 170.1 | - | - | - | - |
| ក្រសួងផ្សេងៗទៀត | 668 | 702 | 828 | 1165 | 383.2 | 306.4 | 301.5 | 311.4 | - | - | - | - |
| បៀវត្សរ៍ | 587 | 615 | 640 | 711 | 140.5 | 210.3 | 230.6 | 240.6 | 199.7 | 242.7 | 253.4 | 362.6 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | - | - | - | - | - | - | 61.9 | 184.0 | 115.0 | 194.2 |
| សមតុល្យជាទូទៅ | -1204 | -993 | -806 | -706 | -336.3 | -288.5 | -298.5 | 7.7 | -99.0 | -81.9 | -78.7 | -204.0 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1249 | 886 | 864 | 1127 | 308.0 | 341.3 | 335.2 | 376.2 | 344.0 | 313.9 | 290.3 | 383.2 |
| ហិរញ្ញប្បទានក្នុងស្រុក | -45 | 106 | 148 | -396 | 28.3 | -52.8 | -36.7 | -383.9 | -245.0 | -213.0 | -148.0 | -140.6 |

*Provisional for 2007. The third quarter data are not yet available. Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០២-២០០៧

| (October-December 2006:100) | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | - | - | - | - | - | - | - | 5.9 | 9.0 | 14.4 | 16.6 |
| ភ្នំពេញ | - | - | - | - | - | - | - | - | 4.7 | 5.8 | 7.7 | 12.4 |
| កម្ពុជា - ទំនិញគ្រប់ប្រភេទ | - | - | - | - | - | - | - | - | 5.7 | 8.5 | 11.9 | 15.9 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | - | - | - | - | - | - | - | - | 8.3 | 12.0 | 16.9 | 21.7 |
| - ដឹកជញ្ជូន | - | - | - | - | - | - | - | - | -3.4 | 1.1 | 2.0 | 5.3 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3912.1 | 3973.3 | 4016.3 | 4119.7 | 4,094.8 | 4106.6 | 4145.3 | 4129.4 | 4063.0 | 4075.4 | 4082.3 | 4030.1 |
| រៀលក្នុង ១ បាតថៃ | 91.1 | 95.8 | 99.9 | 102.6 | 103.5 | 108.0 | 110.3 | 113.0 | 113.7 | 118.0 | 130.0 | 129.3 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.6 | 25.5 | 25.8 | 25.4 | 25.0 | 24.9 | 25.0 | 24.6 | 24.7 | 25.3 | 25.2 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 36.8 | 41.4 | 46.3 | 54.0 | 64.2 | 72.2 | 73.0 | 72.8 | 77.7 | 79.8 | 80.8 | 94.4 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1521 | 1508 | 2088 | 2633 | 2867 | 3110 | 3333 | 3250 | 3067 | 3100 | 3203 | 3679 |
| ថ្លៃសាំង (រៀល/លីត្រ) | 2084 | 2150 | 2833 | 3442 | 3767 | 4000 | 4200 | 4050 | 3750 | 3900 | 4002 | 4368 |

*Sources: NIS, NBC & CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០២-២០០៧ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 3737 | 4027 | 4797 | 5475 | 6410 | 6682 | 6958 | 7224 | 8056 | 9048 | 9768 | 10735 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -849 | -698 | -467 | -450 | -699 | -637 | -497 | -282 | -263 | -172 | 140 | 576 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -119 | -128 | -209 | -421 | -755 | -831 | -892 | -953 | -1176 | -1403 | -1547 | -1816 |
| ឥណទានដល់ផ្នែកឯកជន | 1059 | 1337 | 1817 | 2394 | 2,778 | 2997 | 3288 | 3628 | 4066 | 4537 | 5376 | 6386 |
| រូបិយវត្ថុទូទៅ M2 | 2888 | 3329 | 4330 | 5025 | 5711 | 6045 | 6461 | 6942 | 7793 | 8876 | 9908 | 11311 |
| រូបិយវត្ថុ M1 | 813 | 937 | 1153 | 1323 | 1449 | 1512 | 1563 | 1658 | 1794 | 1748 | 1750 | 2052 |
| រូបិយវត្ថុផ្សេងៗ | 2075 | 2392 | 3177 | 3702 | 4262 | 4533 | 4898 | 5285 | 5999 | 7128 | 8158 | 9259 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 31.0 | 15.2 | 30.0 | 16.1 | 27.0 | 30.6 | 29.4 | 38.2 | 36.5 | 46.8 | 53.4 | 62.9 |
| រូបិយវត្ថុ M1 | 33.5 | 15.3 | 23.0 | 14.7 | 20.9 | 24.4 | 22.2 | 25.3 | 23.9 | 15.7 | 12.0 | 23.8 |
| រូបិយវត្ថុផ្សេងៗ | 30.0 | 15.2 | 32.8 | 16.6 | 33.6 | 32.8 | 31.9 | 42.7 | 40.7 | 57.3 | 66.5 | 75.2 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 វិច្ឆិកា | 2003 | 2004 | 2005 | 2006 វិច្ឆិកា | 2007 កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | 2007 ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7393 | 6534 | 9245 | 7126 | 9393 | 8 | 18 | 27 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7045 | 6010 | 9798 | 7704 | 8852 | 33 | 47 | 26 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6125 | 6125 | 8951 | 9116 | 8303 | 38 | 75 | 36 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 3903 | 4530 | 5533 | 6038 | 5560 | 23 | 42 | 42 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4498 | 4078 | 5150 | 4193 | 4508 | 21 | -2 | 0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4653 | 4126 | 4531 | 4561 | 4790 | 0 | 10 | 3 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 8957 | 11146 | 8347 | 9033 | 8207 | 6 | -2 | -8 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8386 | 9144 | 12,886 | 8979 | 13,060 | 47 | 33 | 37 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6028 | 5263 | 6075 | 5901 | 7550 | -5 | -2 | 43 |
| កម្មករសំណង់មានជំនាញ | 13,127 | 13,111 | 12,679 | 10,316 | 9466 | 10,215 | 11,892 | 11,723 | 10,956 | 21 | 24 | 7 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

តពីទំព័រ ២៤ **ព័ត៌មានថ្មីពី ...**

## ផ្នែកស្រាវជ្រាវ

ផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទំរង់វិស័យសាធារណៈ ទើបតែបញ្ចប់ការស្រាវជ្រាវដល់កន្លែងជុំទីមួយ នៃការចុះអង្កេតសំរាប់ការសិក្សាពីថ្នាក់ដឹកនាំក្នុងនយោបាយនៅមូលដ្ឋាន ហើយនឹងចាប់ផ្តើមវិភាគ និងសរសេរឯកសារពិភាក្សាទីមួយ សំរាប់ដាក់ជូនអ្នកពិនិត្យឡើងវិញនៅខែកញ្ញាខាងមុខ ។ ការចុះស្រាវជ្រាវដល់កន្លែង និងការសិក្សាឯកសារសំរាប់ការសិក្សាពីអភិបាលកិច្ចធនធាន កំពុងជឿនលឿនទៅមុខយ៉ាងល្អ ។ នៅដើមខែមិថុនា ផ្នែកនេះបានរៀបចំការបណ្តុះបណ្តាលលើបញ្ហាទូទៅរយៈពេលមួយសប្តាហ៍ដល់អ្នកចូលរួមចំនួន ១០នាក់ មកពី CDRI និងដៃគូខាងក្រៅមួយចំនួនទៀត ។ ការបណ្តុះបណ្តាលនេះដឹកនាំដោយលោកសាស្ត្រាចារ្យ Phil Hirsch និងសហសេវិករបស់លោក នៅមជ្ឈមណ្ឌលធនធានមេគង្គនៃសាកលវិទ្យាល័យស៊ីដនី ។

ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ ទទួលបានគំរោងស្រាវជ្រាវតូចៗជាច្រើន ពីបណ្តាញស្រាវជ្រាវនិងបណ្តុះបណ្តាលអាស៊ី-ប៉ាស៊ីហ្វិកខាងពាណិជ្ជកម្ម (Asia-Pacific Research and Training Network on Trade: ARTNet) គឺមាន សេវាកម្មនិងកំណើន ការសិក្សាពីភាពប្រកួតប្រជែង និងសេដ្ឋកិច្ចនយោបាយនៃសមាហរណកម្មមហាអនុតំបន់មេគង្គ (GMS) ។ ផ្នែកនេះបានបញ្ចប់ការចុះអង្កេតដល់កន្លែង សំរាប់ការសិក្សាដែលទទួលមូលនិធិពីទីភ្នាក់ងារចំរុះ ស្តីពីផលប៉ះពាល់នៃម្ហូបអាហារមានថ្លៃខ្ពស់ទៅលើជីវភាព ជាពិសេសជីវភាពអ្នកក្រនៅកម្ពុជា ។ ផ្នែកនេះក៏បានចាប់ផ្តើមការងារលើការស្រាវជ្រាវថ្មីមួយស្តីពីការនាំចេញសេវាកម្មកម្ពុជា ដែលឧបត្ថម្ភដោយមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិនៃក្រុងហ្សឺណែវ ។ម្យ៉ាងទៀតផ្នែកនេះបានរៀបចំសិក្ខាសាលាមួយចំនួន ក្នុងនេះមានពីរបានធ្វើឡើងនៅខែមេសា គឺមានមួយធ្វើនៅក្រុងហាណូយ ដើម្បីពិភាក្សាពីការរកឃើញដំបូងៗរបស់បណ្តាញវិភាគដើម្បីអភិវឌ្ឍន៍(DAN) លើពលករចំណាកស្រុកក្នុង GMS និងមួយទៀតនៅក្រុងKunming នៃខេត្តយុនណាន់ ប្រទេសចិន ដើម្បីពិភាក្សាពីការរកឃើញដំបូងៗរបស់DAN លើពាណិជ្ជកម្មផលិតផលកសិកម្មក្នុងGMS ។ នៅខែមិថុនា បានធ្វើសិក្ខាសាលា មួយដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់នៃពាណិជ្ជកម្មសេរី ទៅលើបរិស្ថានក្នុងតំបន់ GMS ។

រហូតមកទល់ពេលថ្មីៗនេះ ផ្នែកសន្តិសុខមនុស្ស ការកសាងសន្តិភាព និងការបំប្លែងទំនាស់ មិនទាន់ចូលរួមក្នុងការស្រាវជ្រាវនៅឡើយ ។ប៉ុន្តែឥឡូវនេះបានផ្លាស់ប្តូរហើយ ដោយធ្វើការស្រាវជ្រាវយ៉ាងសកម្មពីបញ្ហាអភិវឌ្ឍន៍សង្គម ដូចជាខាងសុខភាព អប់រំ និងសន្តិសុខមនុស្ស ជាដើម ។ ផ្នែកនេះទាក់ទាញបានការជួយឧបត្ថម្ភរបស់ UNICEF សំរាប់គំរោងពីរ គឺមួយស្តីពីភាពក្រីក្ររបស់កុមារនិងវិសមភាពនៅកម្ពុជា និងមួយទៀតស្តីពីការវិភាគពីស្ថានភាពយុវជន ។ ផ្នែកនេះបានកសាង និងបង្ហាញឯកសារលើប្រធានបទទាំងនេះទាំងនៅក្នុង និងនៅក្រៅ CDRI ។

ផ្នែកធនធានធម្មជាតិ និងបរិស្ថាន បានបោះពុម្ពផ្សាយ និងចែកចាយរបាយការណ៍សិក្សាឯកសារលើ ការកំណត់ក្របខ័ណ្ឌស្រាវជ្រាវពីការគ្រប់គ្រងធនធានទឹក និងអភិបាលកិច្ចនៅកម្ពុជា ។ ផ្នែកនេះបានបញ្ចប់ការវាយតំលៃសង្គមកិច្ចពីការគ្រប់គ្រងទឹកនៅកម្ពុជា ហើយរំពឹងថានឹងចេញរបាយការណ៍នៅខែកក្កដា ឆ្នាំ២០០៨ ។ ផ្នែកនេះ បានរៀបចំការប្រជុំគណៈកម្មាធិការពិគ្រោះយោបល់សំរាប់គំរោងទឹក ដែលមានការចូលរួមពីតំណាងអង្គការដៃគូស្ថាប័នរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។ ផ្នែកនេះកំពុងបញ្ចប់របាយការណ៍ វិភាគចំណាយនិងផលចំណេញនៃការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជា និងបានបង្ហើយការចុះអង្កេតដល់កន្លែងលើកទីពីរ សំរាប់គំរោងរួមគ្នាមួយពីព្រៃតំបន់ត្រូពិក ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងប្រទេសចំនួន ៥ ដោយវិភាគតាំងពីទិន្នន័យគ្រួសាររហូតដល់កំរិតសាកល ។ តាមការរួមសហប្រតិបត្តិការជាមួយវិទ្យាស្ថានគ្រប់គ្រងទឹកអន្តរជាតិ ផ្នែកនេះបានរៀបចំសំណើអនុវត្តគំរោងមួយអំពីតំលៃបន្ថែមខាងកសិកម្ម គឺជាផ្លូវមួយឆ្ពោះទៅរកការគ្រប់គ្រងធារាសាស្ត្រល្អប្រសើរនៅមហាអនុតំបន់មេគង្គ (GMS) ។ នៅខែមេសា គំរោងនេះបានដាក់ស្នើឡើង ដល់ក្រសួងសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសអាល្លឺម៉ង់ ។

ផ្នែកកសិកម្ម អភិវឌ្ឍន៍ជនបទ និងភាពក្រីក្រ បានចុះកិច្ចសន្យាជាផ្លូវការជាមួយធនាគារ ADB ដើម្បីដើរតួជាទីភ្នាក់ងារអនុវត្តគំរោងការផ្តួចផ្តើមគំនិតកសាងសមត្ថភាពសហគមន៍ ដើម្បីកាត់បន្ថយភាពក្រីក្រនៅអាងទន្លេសាប។ គំរោងនេះបានដាក់ស្នើឡើងជាផ្លូវការនៅខែឧសភា ក្រោមការជួយឧបត្ថម្ភពីក្រុមប្រឹក្សាសំរាប់ការអភិវឌ្ឍកសិកម្មនិងជនបទ និងទទួលបានមូលនិធិពីប្រទេសជប៉ុនសំរាប់ការកាត់បន្ថយភាពក្រីក្រ ។ ផ្នែកនេះកំពុងចរចាជាមួយធនាគារពិភពលោក អោយបន្តជំនួយហិរញ្ញវត្ថុសំរាប់ជុំទីបីនៃការសិក្សាពីការចាកផុតពីភាពក្រីក្រ ដែលជាការសិក្សាពីឌីណាមិកនៃភាពក្រីក្រ ។ ការចុះអង្កេតដល់កន្លែង និងសកម្មភាពជាច្រើនទៀតសំរាប់ការសិក្សានេះកំពុងដំណើរការទៅមុខ ហើយរំពឹងថានឹងកាន់តែមមាញឹកនៅខែកញ្ញា ។

ចាប់ពីឆ្នាំ២០០៧ មក CDRI មានធ្វើសិក្ខាសាលាស្រាវជ្រាវពីរដងក្នុងមួយខែលើបញ្ហាអភិវឌ្ឍន៍ ដើម្បីចែករំលែកលទ្ធផលរកឃើញ និងពង្រឹងគុណភាពស្រាវជ្រាវ ដោយពិភាក្សានិងចែករំលែករបកគំហើញ កែលំអវិធីសាស្ត្រ ព្រមទាំងស្វែងយល់និងវិភាគពីប្រធានបទស្រាវជ្រាវ ។ អ្នកធ្វើបទបង្ហាញក្នុងសិក្ខាសាលាទាំងនេះ មកពី CDRI ស្ថាប័នផ្សេងៗទៀត និង NGOs នៅភ្នំពេញ ។ ចាប់ពីខែមករា ២០០៨ មក អ្នកធ្វើបទបង្ហាញមកពីខាងក្រៅមានដូចជា បណ្ឌិត Stephane Guimert សេដ្ឋកិច្ចវិទូជាន់ខ្ពស់នៃការិយាល័យធនាគារពិភពលោកនៅភ្នំពេញ បណ្ឌិត John MacAndrew អ្នកស្រាវជ្រាវនៅ ADI/CCC កម្ពុជា និងលោក មែន និមិត្ត នាយកមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅកម្ពុជា ។ អ្នកធ្វើបទបង្ហាញមកពី CDRI មានដូចជា លោកស្រី អេង នេត្រា កញ្ញា ធន់ វិមាលា លោក ច័ន្ទ សុផល លោក លឹម សុវណ្ណារ៉ា លោក ហ៊ីង វុត្ថា បណ្ឌិត ហ៊ាន ភូមិន្ទ បណ្ឌិត Brett Ballard និង លោក សូ សុវណ្ណារិទ្ធិ ។ បទបង្ហាញជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ អភិបាលកិច្ច ពាណិជ្ជកម្ម ធនធានធម្មជាតិ និងកសិកម្ម ។

# ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

របាយការណ៍ប្រចាំឆ្នាំ២០០៧-២០០៨ របស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ឈានដល់ដំណាក់កាលចុងក្រោយនៃការរៀបចំ ហើយនឹងបោះពុម្ពផ្សាយ និងដាក់លើគេហទំព័រនៅខែកក្កដា ។ ស្របតាមស្មារតីការប្រជុំបូកសរុបលទ្ធផលពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថាន CDRI ឆ្នាំ២០០៦-២០១០ ហើយដើម្បីឆ្លើយតបនឹងតំរូវការក្នុងស្រុកនូវលទ្ធផលស្រាវជ្រាវរបស់ CDRI វិទ្យាស្ថាន CDRI កំពុងរៀបចំផ្តល់ដោយឥតគិតថ្លៃរាល់របាយការណ៍ស្រាវជ្រាវ និងរបកគំហើញរបស់ខ្លួន ទាំងជាភាសាខ្មែរ និងអង់គ្លេស តាមរយៈការផ្សព្វផ្សាយក្នុងវេបសាយ ។ CDRI ក៏បន្តចេញផ្សាយនូវឯកសារបោះពុម្ពប្រកបដោយគុណភាពផងដែរ ។

ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) និងនាយកដ្ឋានសំរាប់ការអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (DFID) បានបញ្ជាក់ពីការបង្កើនរយៈពេល និងពង្រីកជំនួយគាំទ្រដល់ CDRI ពីឆ្នាំ២០០៨-២០១០ ទាំងសំរាប់កម្មវិធី អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនិងកំណែទំរង់វិស័យសាធារណៈ និងមូលនិធិស្នូលសំរាប់ប្រតិបត្តិការ ការកសាងសមត្ថភាព និងការពង្រឹងស្ថាប័ន ។ Sida នឹងបូកសរុបពាក់កណ្តាលអាណត្តិលើលទ្ធផលជំនួយគាំទ្ររបស់ខ្លួននៅចុងឆ្នាំ២០០៨ ។ Sida និង DFID គាំទ្រ CDRI យ៉ាងខ្លាំងក្នុងសំណើអនុវត្តគំរូនៃភាពជាដៃគូខាងធនធាននេះជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត ។

នៅដើមខែមិថុនា CDRI និងវិទ្យាស្ថានសិក្សាពីការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ (CBNRMLI) បានរួមគ្នារៀបចំការប្រជុំបំផុសគំនិតសំរាប់ការបង្កើតវេទិកាស្រាវជ្រាវអភិវឌ្ឍន៍នៅកម្ពុជា ដែលជាសម្ព័ន្ធដៃគូគ្នានៃបណ្តាអង្គការទទួលការគាំទ្រពី IDRC ។ សម្ព័ន្ធនេះនឹងជួយជំរុញសហប្រតិបត្តិការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយ ការចែកចាយព័ត៌មាន និងការកសាងបណ្តាញ ។ម្យ៉ាងទៀតក៏មានការផ្តល់ធនធានសំរាប់បង្កើនសមត្ថភាពបណ្តាអង្គការជាដៃគូដែរ ។ តាមរយៈគំនិតផ្តួចផ្តើមនេះ IDRC បានរួមចំណែកយ៉ាងច្រើន ដើម្បីលើកកំពស់ដល់ការស្រាវជ្រាវខាងគោលនយោបាយ ដោយផ្អែកលើភស្តុតាង ព្រមទាំងការចែកចាយ និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវនេះ ។

នៅក្រោយសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៨ CDRI និង ធនាគារ ANZ Royal បានចុះកិច្ចព្រមព្រៀងរៀបចំរួមគ្នានូវសន្និសីទប្រចាំឆ្នាំសំរាប់ឆ្នាំ២០០៩ ២០១០ និង ២០១១ ក្នុងនេះ ធនាគារ ANZ Royal គឺជាដៃគូឧបត្ថម្ភគាំទ្រ និងជួយរៀបចំផ្តាច់មុខ ។

នាបច្ចុប្បន្ន CDRI កំពុងបូកសរុបលទ្ធផលពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០០៦-២០១០ ។ ដំណើរការនេះរួមមានការវាយតំលៃពីលទ្ធផលសំរេចបានធៀបនឹងផែនការបច្ចុបន្ន ការធ្វើបច្ចុប្បន្នភាព និងកែតំរូវផែនការនេះ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរផ្សេងៗដែលកើតមានឡើងនៅក្រោយពេលអនុម័ត ។ ការពិនិត្យឡើងវិញពីការគ្រប់គ្រងធនធានមនុស្សក៏កំពុងអនុវត្តដែរ ក្នុងនេះគឺមាន អង្កេតពីឥរិយាបថ/ការពេញចិត្តរបស់បុគ្គលិក ការពិនិត្យឡើងវិញពីប្រព័ន្ធធ្វើចំណាត់ថ្នាក់បុគ្គលិក បៀវត្សរ៍/អត្ថប្រយោជន៍របស់បុគ្គលិក ព្រមទាំងតួនាទី រចនាសម្ព័ន្ធ និងតំរូវការអភិវឌ្ឍន៍វិជ្ជាជីវៈនៃអ្នកគ្រប់គ្រងថ្នាក់កណ្តាលរបស់ CDRI ។

(តទៅទំព័រ ២៣)

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១២ លេខ២ ខែមេសា-មិថុនា ឆ្នាំ២០០៨

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdrimail@online.com.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធីរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង គីម ចិត្រ្តា
ជំនួយការកែសំរួល: យេន សុផានី
រោងពុម្ពដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០០៨ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។